ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jun-2013, 16:15
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៨:៣៣នាទី**

**សវនាការលើកទី១៨៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា មីរាម ម៉ាហ្វេសសាន់ទិ

*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារាស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោកឃីត រេយ៍ន័រ

*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក ឡៅ ជុនធី

លោក ប៉ាស្កាល់ អូប៊ីង

*(Mr. Pascal AUBOIN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោកស្រី នូស៊ីន សាការ៉ាទី

*(Ms. Nushin SAKARATI)*

លោកស្រី កាទ្រីណា ម៉ារី ណាតាលី

*(Ms. Katrina Marie Natale)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| កញ្ញា អង់តា ហ្គិសសេ | បារាំង |
| លោក ស៊ីដនី ស្ពេនប៊ឹក (TCW-624) | អង់គ្លេស |
| លោក ឈឹម សុធារ៉ា (TCE-12) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ស៊ីដនី ស្កេនប៊ឺក** (TCW-624)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ........ ទំព័រ ២
សួរដោយលោក វ៉េង ហ៊ាត់ ផ្ដើមពី៖ ........ ទំព័រ ៥
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖ ........ ទំព័រ ១១


**ការសួរសំណួរទៅអ្នកជំនាញ÷ លោក ឈឹម សុធារ៉ា** (TCE-12)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ........ ទំព័រ ៥០
សួរដោយលោក ពេជ អង្គ ផ្ដើមពី៖ ........ ទំព័រ ៥១
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី៖ ........ ទំព័រ ៦៧
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី៖ ........ ទំព័រ ៨៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៣៣:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីមួយរូបគឺលោក ស៊ីដនី ស្កេនប៊ឹក តាមរយៈមធ្យោបាយប្រព័ន្ធសោតទស្សន៍ពីទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់នូវសក្ខីកម្មអ្នកជំនាញ TCE-12។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីមានវត្តមាន។ សូមកត់សម្គាល់ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ តាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

តាមកាលវិភាគសម្រាប់សវនាការថ្ងៃនេះ នឹងស្ដាប់សក្ខីកម្មសាក្សី និងអ្នកជំនាញចំនួនពីររូប។ នៅពេលព្រឹកស្ដាប់សក្ខីកម្មសាក្សី TCW-624 តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។

[០៨:៣៥:៣០]

សាក្សីរូបនេះ បានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនេះនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះមុនពេលផ្ដល់សក្ខីកម្ម។

ប្រព័ន្ធបច្ចេកទេសសោតទស្សន៍បានរៀបចំរួចរាល់ហើយ រីឯសាក្សីក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្ដល់សក្ខីកម្មផងដែរ។ ចំណែកនៅពេលរសៀលនឹងស្ដាប់សក្ខីកម្មអ្នកជំនាញ TCE-12។ អ្នកជំនាញរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ចំណងញាតិ

លោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ ហើយអ្នកជំនាញនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅពេលព្រឹកនេះ។

នៅថ្ងៃនេះមានសាក្សីបម្រុងមួយរូប គឺសាក្សីដែលមានរហស្សនាម TCW-665។

សូមអរគុណលោកប្រធាន។

[០៨:៣៦:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោក ស៊ីដនី ស្កេនប៊ឹក!

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** សួស្តីលោកប្រធាន នេះគឺជា -- ខ្ញុំឈ្មោះ ស៊ីដនី ស្កេនប៊ឹក។ អរុណសួស្តីលោកប្រធាន។

**ស៖** អរគុណលោក ស្កេនប៊ឹក។ តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** លោកប្រធាន សូមលោកប្រធានសួរបញ្ជាក់ឡើងវិញ ខ្ញុំស្តាប់អត់បាន។

**ស៖** តើលោកមានអាយុប៉ុន្មាន?

**ឆ៖** ខ្ញុំមានអាយុ៧៩ឆ្នាំ។

**ស៖** អរគុណលោក ហើយសព្វថ្ងៃនេះ តើលោករស់នៅទីកន្លែងណា?

**ឆ៖** អាសយដ្ឋានរបស់ខ្ញុំគឺ នូផល នៅអាប់ស្ទេត បុរីញូវយ៉ក។

**ស៖** អរគុណ។ ចុះលោកប្រកបមុខរបរស៊ីធ្វើអ្វី?

[០៨:៣៨:០០]

**ឆ៖** ជាការពិត ខ្ញុំមានអាជីវកម្មខ្លួនឯង ខ្ញុំជាអ្នកសរសេរសៀវភៅ ខ្ញុំអ្នកនិពន្ធសៀវភៅទៅលើប្រធានបទផ្សេងៗ។

**ស៖** បាទ អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ ចេន, ចេន ប្រាយមិន។ ខ្ញុំមានកូនស្រីពីរនាក់ ចេស៊ីកា និង រ៉ូប៊ែកា

ឈ្មោះរបស់ពួកគេ ហើយមានចៅបីនាក់។

**ស៖** បាទ អរគុណលោក។ ហើយតើលោកមានសញ្ជាតិអ្វី?

**ឆ៖** ខ្ញុំជាពលរដ្ឋអាមេរិក។

**ស៖** បាទ អរគុណ។ លោក ស៊ីដនី ស្កេនប៊ឹក ក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថ ឬសច្ចាតាមជំនឿសាសនារបស់លោក នៅចំពោះមុខអង្គជំនុំជម្រះ។ តើលោកយល់ព្រមដែរឬទេ?

[០៨:៣៩:២៩]

**ឆ៖** ខ្ញុំយល់ព្រម។ បាទ ខ្ញុំយល់ព្រមទៅតាមការស្នើសុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្រឡាបញ្ជី កញ្ញា មីរាម ណែនាំលោក ស៊ីដនី ស្កេនប៊ឹក ឲ្យធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះតាមជំនឿសាសនារបស់គាត់។

**ក្រឡាបញ្ជី៖**

សូមលោកសាក្សីថាតាមខ្ញុំ ខ្ញុំសូមសន្យានឹងធ្វើសម្បថថា ខ្ញុំនឹងនិយាយតែការពិតគ្មានអ្វីក្រៅតែពីការពិត។

**លោក ស៊ីដនី ស្កេនប៊ឹក៖**

ខ្ញុំសូមសន្យាសម្បថថា ខ្ញុំនឹងនិយាយតែការពិត ការពិតគ្មានអ្វីក្រៅតែពីការពិត។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទអរគុណ ហើយលោក ស៊ីដនី ស្កេនប៊ឹក តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការនៅពេលមុននេះបន្តិច ថាតាមសមត្ថភាពដែលលោកអាចដឹងគឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែរ។ តើពិតមែនដែរឬទេ?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** ពិតជាត្រឹមត្រូវ លោក លោកស្រីចៅក្រម។

[០៨:៤១:០០]

**ស៖** បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សី ដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សូមឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងនាមលោកជាសាក្សីត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការនេះ ត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលចៅក្រម ឬភាគីនៃរឿងក្តីសួរចំពោះលោក។ ហើយលោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ?

**ឆ៖** ខ្ញុំយល់លោកប្រធាន។ សូមអរគុណ។

**ស៖** បាទ អរគុណ។ ហើយលោក ស៊ីដនី ស្កេនប៊ឺក តើលោកធ្លាប់ដែលផ្តល់សក្ខីកម្ម ឬក៏កិច្ចសម្ភាសណាមួយជាមួយនឹងសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងរយៈពេលកន្លងប៉ុន្មានឆ្នាំមុននេះដែរឬទេ?

**ឆ៖** លោកប្រធានមានន័យថា ការសាកស្តាប់ចម្លើយដែលធ្វើឡើងដោយចៅក្រមនៅតុលាការរបស់លោកប្រធាន ឬក៏យ៉ាងម៉េចលោកប្រធាន? ខ្ញុំសូមបញ្ជាក់។

**ស៖** បាទ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅអ.វ.ត.ក នេះតើមានដែលលោកដែលផ្តល់សក្ខីកម្មទេ?

**ឆ៖** មិនដែលធ្លាប់ទេលោកប្រធាន ទើបតែថ្ងៃនេះ។

[០៨:៤៣:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនថា ក្រុមមេធាវីការពារក្តីលោក នួន ជា ថានៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃ

រឿងក្តី។ ហើយពេលវេលាគឺមួយវគ្គសវនាការក្នុងការសួរ ហើយបន្ទាប់មកអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា រួមនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ប្រហែលជាមានការយល់ច្រឡំ។ យើងខ្ញុំយល់ឃើញថាតំណាងសហព្រះរាជ-អាជ្ញាចាប់ផ្តើមមុន។ ហើយគឺមានការជូនដំណឹងដូច្នេះហើយ ហើយតាមព័ត៌មានដែលទទួលបានពីក្រឡាបញ្ជី។ ខ្ញុំឃើញខាងសហព្រះរាជអាជ្ញាគាត់ងក់ក្បាល ដូច្នេះខ្ញុំជឿថាគឺសាក្សីនេះចាប់ផ្តើមតាំងសំណួរដោយសហព្រះរាជអាជ្ញាមុន ដោយសារមាននៅក្នុងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា។ នេះក៏ជាសំណើពីខ្ញុំផងដែរលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៨:៤៤:៣២]

**ប្រធានអង្គជំនុំ៖**

បាទ បើអ៊ីចឹងមិនអីទេ បាទបើអ៊ីចឹងបើសិនជាភាគីយល់ឃើញថា សួរដូច្នេះសមស្រប អង្គជំនុំជម្រះក៏សម្រេចតាមនោះដែរ គឺអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី ដោយរួមទាំងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផង ដែលមានរយៈពេលពីរវគ្គនៃដំណើរការសវនាការ។ សូមអញ្ជើញ!

**លោក វេង ហ៊ត់៖**

សូមគោរពលោកប្រធាន សូមគោរពក្រុមប្រឹក្សាចៅក្រម និងសូមស្វាគមន៍លោក លោកស្រីទាំងអស់ដែលមាននៅក្នុងអង្គសវនាការនេះ។

[០៨:៤៥:៤៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វេង ហ៊ត់៖**

**ស៖** សួស្តីលោក ស្តេនប៊ីត។ ខ្ញុំឈ្មោះ វេង ហ៊ត់ រួមជាមួយនឹងសហការីរបស់ខ្ញុំគឺលោក ថារីក អាប់ឌុលហាក់ នឹងសួរសំណួរទៅកាន់លោកមួយចំនួន ក្នុងនាមការិយាល័យរបស់សហព្រះរាជអាជ្ញា។ ខ្ញុំនឹងសួរលោកអំពីការជម្លៀសទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ហើយសហការីរបស់ខ្ញុំនឹងសួរលោកអំពីព្រឹត្តិការណ៍ផ្សេងៗដែលលោកបានជួបប្រទះ នាសម័យការនោះ។ ខ្ញុំ

នឹងអានសម្រង់ចេញពីកំណត់ហេតុប្រចាំថ្ងៃរបស់លោក ដែលមានលេខឯកសារ E236/1/4/3.1 ដែលមានចំណងជើងថា *"ឌឹ ខេមបូឌា ដាយរី ណានធីនសេវេនធីហ្វាយ អ៊ី ហ្សីណាលីស ដេបាយដេ ណូត អន ដឹ ហ្វល អហ្វ ខេមបូឌា ធូ ឌឹ ខ្មែររូស្ស"* *(ភាសាអង់គ្លេស)*។

អត្ថបទនេះនៅក្នុងទំព័រ៧១ ERN ជាភាសាអង់គ្លេស 00898279 ដែលរៀបរាប់ពីអ្វីដែលលោកបានឃើញនៅម៉ោងប្រាំល្ងាចថ្ងៃទី១៧ មេសា ១៩៧៥។ ខ្ញុំនឹង អានអត្ថបទទាំងស្រុងបន្ទាប់មកខ្ញុំនឹងសួរសំណួរខ្លះៗ។

[០៨:៤៧:០៦]

អត្ថបទទាំងនេះខ្ញុំអានដូចតទៅ "យើងបានធ្វើដំណើរតម្រង់ទៅកាន់អូតែល ហើយពេលនេះជាលើកដំបូងដែលយើងឃើញច្បាស់នូវការជម្លៀសដោយបង្ខំ ក្រុមទាហានបដិវត្តន៍ដោយមានគ្រឿងកាំភ្លើងខ្លី កាំភ្លើងវែង ខ្លះស្រែកខ្លាំងៗ ខ្លះទៀតស្រែកតាម ឧគ្ឃោសនសព្ទបញ្ជាឲ្យប្រជាជនចាកចេញជាបន្ទាន់ពីផ្ទះរបស់ពួកគេ ហើយប្រាប់ឲ្យធ្វើដំណើរទៅកាន់ទីជនបទ។ ប្រជាជនត្រូវបានប្រាប់ថា ពួកគេនឹងត្រូវបានគេប្រាប់ទិសដៅថាត្រូវទៅណានៅពេលដែលពួកគេចេញផុតពីទីក្រុង។ នៅពេលដែលគ្រួសារណាធ្វើដំណើរដោយយឺតយ៉ាវ មិនទាន់ចិត្តពួកទាហានបដិវត្តន៍ ពួកទាហានទាំងនោះនឹងបាញ់ឡើងលើ ដើម្បីបង្ហាញថា ពួកគេមិននិយាយលេងទេ។ ផ្លូវនានាពោរពេញទៅដោយស៊ីក្លូដែលសំពឹងសំពោង និងឡានហើយនិងមនុស្សដើរដោយជើង ខណៈដែលមនុស្ស ក្រុមមនុស្សដែលកំពុងចាកចេញកាន់តែច្រើនឡើងៗប្រមូលផ្តុំគ្នា។ ហើយមានអ្នករបួសរាប់ពាន់នាក់ចេញពីមន្ទីរពេទ្យនានា ខ្លះដើរប៉ុងខ្ញើច ខ្លះដើរឈើច្រត់ខ្លះរួមមានជនពិការដៃជើង ខ្លះទៀតអូសរុញ ដោយបងប្អូនញាតិមិត្តក្នុងរទេះកង់រុញ រទេះសម្រាប់ជនពិការ និងទើបចាកចេញពីមន្ទីរពេទ្យដោយមានព្យួរសេរ៉ូមនៅជាប់នឹងដៃគេនៅឡើយ"។ បញ្ចប់ការដកស្រង់។

ឥឡូវនេះដំបូងខ្ញុំសួរទៅកាន់លោក តើលោកអាចជម្រាបតុលាការបានទេ តើឃើញប្រជាជនទាំងនោះនៅកន្លែងណា?

[០៨:៤៩:២៣]

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** ខ្ញុំឃើញពួកគេនៅកន្លែងមួយចំនួននៅក្នុងក្រុង។ កន្លែងដំបូងនោះគឺខ្ញុំឃើញនៅមន្ទីរពេទ្យព្រះកេតុមាលា។ គ្រូពេទ្យនៅទីនោះគឺគាត់មិនអាច -- យើងមិនឃើញមានគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យ

នោះទេ ឃើញតែគិលានុបដ្ឋាយិកា។ អ្នកជំងឺ អ្នករបួស សាច់ញាតិមួយចំនួននោះបានស្លាប់នៅកន្លែងកូនក្មេងដែលស្នាក់នៅ។ ឃើញមានឈាមតាមជណ្តើរ នៅពេលដែលក្រុមតូចមួយចេញមកពីមន្ទីរពេទ្យនោះ គឺនៅពេលដែលក្រុមតូចមួយរបស់ខ្ញុំចេញពីមន្ទីរពេទ្យនោះ គឺថាគេចាប់ខ្លួនពួកយើង។ គេដាក់យើងខ្ញុំនៅលើកន្លែងមួយដូចជាឡានអ៊ីចឹង ហើយគេក៏បើកដឹកយើងចេញទៅកន្លែងមួយនៅក្បែរទន្លេមេគង្គ។ នៅទីនោះគឺយើងឃើញមានមន្ទីររបស់ពួកគេ ហើយបន្ទាប់មកគឺយើងចាកចុះចេញពីរថយន្ត។ នៅពេលដែលយើងចេញពីរថយន្តនោះ គឺថាយើងជួបនឹងពួកគេមួយក្រុមនោះមានកាំភ្លើង។ សំណួររបស់លោកនោះ គឺលោកបានសួរយើងខ្ញុំ យើងខ្ញុំមិនត្រូវបានគេសម្លាប់ចោលនោះទេ។ ក៏ប៉ុន្តែនៅតាមផ្លូវនោះ គឺយើងឃើញមនុស្សដើរចាកចេញទៅ យើងឃើញមនុស្សត្រូវបានគេរុញច្រាន ហើយក៏ឃើញមានគេរុញមនុស្សដេកលើគ្រែផងដែរ គឺឃើញមនុស្សគ្រប់រូបភាព។

[០៨:៥១:៤៨]

ហើយក៏ឃើញមានអ្នកខ្លះនោះមានព្យួរសេរ៉ូម នៅលើគ្រែហ្នឹងដាក់ព្យួរសេរ៉ូមតាមគ្រែរុញចេញទៅផងដែរ។ ពួកគេត្រូវបានបង្ខំឲ្យចាកចេញពីក្រុង។ តាមមហាវិថីដែលយើងដើរចាកចេញទៅនោះ គឺយើងឃើញមានភាពរប៉ាត់រប៉ាយ មានស្បែកជើងរប៉ាត់រប៉ាយ ហើយនិងស្បែកជើងផ្ទាត់ផងដែរដែលប្រជាជននោះ គេរបូតតាមផ្លូវនៅពេលដែលគេ ប្រជាជនទាំងអស់តម្រូវឲ្យរត់ និងដើរឲ្យលឿន។ យើងឃើញមានហ្វូងមនុស្សច្រើនណាស់នៅក្នុងទីក្រុងស្ទើរតែគ្រប់កន្លែងផ្សេងៗ--

**សៈ** សូមអធ្យាស្រ័យលោក ស្កេនប៊ឹក ខ្ញុំមានសំណួរតទៅទៀតលើចំណុចសំខាន់ៗទេ។ អ៊ីចឹងសូមលោកអធ្យាស្រ័យ ពីព្រោះពេលវេលាខ្ញុំមានកំណត់ដែរ។ បន្ទាប់មកខ្ញុំចង់សួរអំពីហេតុការណ៍ដែលលោកបានឃើញជាក់ស្តែងនោះ តើលោកចំណាយពេល រយៈពេលយូរដែរទេក្នុងការត្រួតពិនិត្យរាល់ហេតុការណ៍នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ?

**ឆៈ** ខ្ញុំឃើញស្ទើរតែពេញ១ថ្ងៃ ខ្ញុំឃើញក្នុង១ថ្ងៃនោះតែម្តង។ នៅពេលដែលខ្ញុំទៅជ្រកកោននៅទូតបារាំង រួមជាមួយនឹងអ្នករាយការណ៍ អ្នកកាសែតរាយការណ៍ផ្សេងទៀត រួមទាំងពលរដ្ឋសាមញ្ញដទៃទៀតដែលឡើងតាមជញ្ជាំងចូលទៅក្នុងទូតបារាំង។ ខ្ញុំបានឃើញហេតុការណ៍នេះពេញ១ថ្ងៃ ខ្ញុំឃើញហ្វូងមនុស្សត្រូវបានគេរុញច្រានចេញពីទីក្រុង មិនមែនគេរុញច្រានដូចនៅក្នុងឡាននោះទេ។ បានន័យថា គេរុញដូចគោក្របីអ៊ីចឹង ដោយសារតែគេប្រាប់ថាអាមេរិកាំងនឹងមកទម្លាក់គ្រប់បែកក្នុងក្រុង។ ដូច្នេះហើយ គឺប្រជាជននោះមានអារម្មណ៍ភ័យខ្លាច និងរន្ធត់ដោយសារបញ្ហានេះឯង។

[០៨:៥៤:២២]

**ស៖** លោក ស្តេនប៊ីក ខ្ញុំនឹងបន្តសំណួរបន្តិចៗទេ ចាំលោកជួយឆ្លើយខ្លីៗបន្តិច។ លោកបានប្រាប់អង្គសវនាការអម្បាញ់មិញថា លោកបានឃើញទុក្ខវេទនាអ្នកជម្លៀស និងមនុស្សដែលចេញពីមន្ទីរពេទ្យ ហើយលោកបានពិនិត្យឃើញហេតុការណ៍នោះ គឺពេញ១ថ្ងៃ។ ខ្ញុំចង់សួរលោកថា តើលោកអាចប៉ាន់ស្មានបានទេថា មនុស្សប្រហែលជាប៉ុន្មាននាក់ដែលលោកបានឃើញនោះបាទ?

**ឆ៖** គឺយើងឃើញមានរាប់រយនាក់នៅពេលនោះ បានន័យថាមនុស្សហ្នឹងនៅពេញផ្លូវតែម្តង គឺពីម្ខាងទៅម្ខាងសុទ្ធតែមនុស្ស។

**ស៖** អរគុណ ស្តេនប៊ីក ខ្ញុំចង់សួរសំណួរតទៅទៀត។ នៅពេលដែលមនុស្សពេញផ្លូវទាំងនោះពេញផ្លូវ តើលោកឃើញមនុស្សចាស់ កូនក្មេងមានរួមទាំងបុរសស្ត្រី ឬកុមារដែរទេនៅពេលនោះបាទ?

**ឆ៖** ខ្ញុំឃើញស្ត្រី កុមារ ឃើញមនុស្សគ្រប់ប្រភេទ។

**ស៖** អរគុណលោក។ តើអ្នកជម្លៀសទាំងអស់នោះ សុទ្ធតែជាប្រជាជនស៊ីវិល ឬក៏ជាកងទ័ព ឬក៏មានទាំងកងទ័ព និងជនស៊ីវិលផងដែរ?

[០៨:៥៦:១៦]

**ឆ៖** ប្រជាជនភាគច្រើនគឺប្រជាជនស៊ីវិល ហើយមានប្រជាជនខ្លះគឺជាបុរសដែលបានដោះសម្លៀកបំពាក់ទាហានចេញ ហើយត្រូវបានគេបណ្តើរចេញទៅក្រៅក្រុង។

**ស៖** អរគុណលោក ស្តេនប៊ីក។ នៅក្នុងសម្រង់ដែលខ្ញុំបានដកស្រង់អម្បាញ់មិញនេះ លោកបានសរសេរថា "មានក្រុមទាហានបដិវត្តន៍ដែលគ្រវីកាំភ្លើងវែង កាំភ្លើងខ្លីហើយស្រែក"។ តើលោកអាចរៀបរាប់ប្រាប់យើងបានទេ លោកឃើញមានប៉ុន្មានក្រុម? ហើយក្រុមទាហានប៉ុន្មាននាក់ក្នុងមួយក្រុមៗនោះបាទ?

**ឆ៖** ខ្ញុំឃើញពួកគេ ឃើញមានការបាញ់កាំភ្លើងឡើងទៅលើនៅពីរ ឬក៏បីកន្លែងនៅក្នុងក្រុង។ គឺបានន័យថាបាញ់កាំភ្លើងនេះដោយបង្ហាញនូវសញ្ញាថាជាការនូវប្រារព្ធពិធីជ័យជម្នះ។

**ស៖** បាទ ខ្ញុំបន្តសំណួរ។ នៅក្នុងឃ្លាខាងលើដដែល តើលោកចង់មានន័យយ៉ាងម៉េចដែរ ដែលលោកប្រើពាក្យថា "ទាហានបដិវត្តន៍"? តើទាហានបដិវត្តន៍នេះជាក្រុមទាហានរបស់ខាងណាដែរ ដែលលោកបានឃើញនោះ?

[០៨:៥៨:០៥]

**ឆ៖** តាមខ្ញុំអាចដឹងនោះ អ្នកទាំងអស់ហ្នឹង ទាហានបដិវត្តន៍ទាំងអស់ហ្នឹង គឺជាកងទ័ពរបស់ខ្មែរក្រហម។ ពួកគេស្លៀកពាក់សម្លៀកបំពាក់ខ្មែរក្រហមនោះឯង។

**ស៖** អរគុណលោក។ នៅពេលដែលប្រជាជនកំពុងជម្លៀស ឬក៏ភៀសជាច្រើននៅតាមដងផ្លូវ តើលោកបានសម្គាល់ឃើញថាមានមន្ត្រីខ្មែរក្រហមណានៅកន្លែងនោះដែរទេ?

**ឆ៖** ខ្ញុំបានឃើញ ឃើញមានមន្ត្រីខ្មែរក្រហមនៅពេលដែលយើងចាកចេញពីមន្ទីរពេទ្យទៅដល់ជិតទន្លេមេគង្គ។ យើងឃើញមានមន្ត្រីកងខ្មែរក្រហមមួយចំនួន ស័ក្តិ៥ ឬក៏ស័ក្តិ៣។ ពួកគេមិនមានស្លាកឈ្មោះដាក់លើខោអាវនោះទេ ពាក់លើខោអាវនោះទេ ក៏ប៉ុន្តែយើង ខ្ញុំដឹងថាពួកគាត់គឺជាមន្ត្រីខ្មែរក្រហម។

**ស៖** តទៅនេះ ខ្ញុំដកស្រង់ចេញពីអ្វីដែលលោកបានសរសេរ លោកប្រាប់ថាចេញពីនៅក្នុងលោកបាននិយាយថា "មានមនុស្សរាប់ពាន់នាក់ចេញពីមន្ទីរពេទ្យនានា រួមមានជនពិការដៃ ជើង ខ្លះទៀតកំពុងត្រូវបានអូសរុញដោយបងប្អូនញាតិមិត្តក្នុងរទេះកង់រុញ។ រទេះសម្រាប់ជនពិការ និងទើបចេញពីមន្ទីរពេទ្យ ដោយសេរ៉ូមនៅជាប់នឹងដៃពួកគេនៅឡើយ"។

[០៩:០០:១២]

**ឆ៖** ជាការពិត ខ្ញុំឃើញរូបភាពទាំងអស់នុ៎ង។

**ស៖** បាទ ខ្ញុំមានសំណួរថាតើនៅពេលដែលលោកបានឃើញនោះ អ្នកដែលចេញពីមន្ទីរពេទ្យ ឬក៏ជម្លៀសនោះ តើពួកគេ ប្រជាជនទាំងអស់នោះមានជំនួយពេទ្យណាមួយដែលបានផ្តល់ឲ្យពួកគេទាំងអស់នោះដែរឬទេ?

**ឆ៖** ខ្ញុំពុំឃើញមានការថែទាំផ្នែកសុខភាពដល់ពួកគេដោយគ្រូពេទ្យ ឬក៏គិលានុបដ្ឋាយិកានោះទេ។ មានហេតុការណ៍មួយនោះគឺអ្នកជំងឺបានត្រូវបានគេប្រាប់ថា ពួកគេត្រូវយកទៅកន្លែងពេទ្យ ឬក៏មន្ទីរពេទ្យនៅទៅតាមផ្លូវខាងត្បូងក្រុងភ្នំពេញ។ ខ្ញុំបានទៅពេទ្យនោះច្រើនដងដែរគឺជាពេទ្យ កន្លែងពេទ្យឆ្កួត ហើយមានតែគ្រូពេទ្យម្នាក់តែប៉ុណ្ណោះ។

[០៩:០១:២៣]

នៅពេទ្យទីនោះគឺគ្មានវិធីសាស្ត្រទំនើបណាមួយសម្រាប់ព្យាបាលអ្នករបួសនោះទេ ជាពិសេសសម្រាប់ព្យាបាលអ្នកជំងឺដែលចាកចេញពីមន្ទីរពេទ្យព្រះកេតុមាលា។ ដូច្នេះបានន័យថាមន្ទីរពេទ្យនៅខាងត្បូងក្រុងភ្នំពេញនោះមិនអាចថែទាំអ្នកជំងឺដែលចាកចេញពីមន្ទីរព្រះកេតុមាលានោះទេ។

**ស៖** បាទ អរគុណលោក ស្មេនប៊ឹក។ ខ្ញុំនឹងបន្តសំណួរនៅពេលដែលទាហានខ្មែរក្រហមបានផ្តល់ការ -- បានបញ្ជូនប្រជាជន ឬក៏ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តើពួកគេមានបានផ្តល់ចំណីអាហារ ទឹកទៅឲ្យអ្នកជម្លៀសទាំងនោះដែរឬទេ?

**ឆ៖** គ្មានម្ហូបអាហារ ឬក៏ទឹក ឬក៏អ្វីនោះទេ ខ្ញុំមិនបានឃើញទេ។ គឺគេបណ្តេញប្រជាជនចេញទៅដូចសត្វធាតុអ៊ីចឹង គ្មានអ្វីទេ។

**ស៖** បាទ ខ្ញុំបន្តសំណួរទៀត។ នៅពេលដែលលោកឃើញទុក្ខសោករបស់ប្រជាជនដែលត្រូវជម្លៀសមានទាំងអ្នកជំងឺ ព្យួរសេរ៉ូមផង តើខ្មែរក្រហមអនុញ្ញាតឲ្យពួកគេស្នាក់នៅ នៅពេលដែលពួកគេឈឺ ឬក៏ខ្សោយពេកមិនអាចបន្តដំណើរទៅបាន តើគេអនុញ្ញាតឲ្យស្នាក់ដែរឬទេបាទ?

[០៩:០៣:៣៦]

**ឆ៖** គេមិនឲ្យទេ គឺគេឲ្យអ្នកជំងឺនោះចេញពីមន្ទីរពេទ្យ គឺមន្ទីរពេទ្យនោះត្រូវតែគេបណ្តេញមនុស្សចេញទាំងអស់មិនឲ្យនៅសល់ទេ។

**ស៖** តើមានហេតុការណ៍អ្វីកើតឡើង នៅពេលដែលអ្នកជំងឺមិនអាចបន្តដំណើរទៅមុខទៀត ហើយគាត់មិនព្រមចាកចេញនោះ? តើលោកបានដឹងហេតុការណ៍នេះទេ?

**ឆ៖** ខ្ញុំគ្រាន់តែអាចស្មានតែប៉ុណ្ណោះ ក៏ប៉ុន្តែ២សប្តាហ៍ក្រោយមកនៅពេលដែលគេយកយើងចេញពីក្រុងភ្នំពេញនោះ យើងឃើញមានសាកសពនៅតាមផ្លូវ សាកសពមនុស្សដែលត្រូវបានគេបណ្តេញចេញ។ ខ្ញុំសន្និតថា អ្នកខ្លះនោះ គឺសាកសពខ្លះនោះគឺជាអ្នកដែលចាកចេញពីក្រុងភ្នំពេញនេះដែលត្រូវគេបណ្តេញចេញនោះ មានអ្នកខ្លះគឺស្លាប់បាទ។

[០៩:០៥:០៥]

**ស៖** ខ្ញុំមានសំណួរបន្តិចទៀតជូនលោក។ នៅក្នុងអំឡុងពេលដែលលោកបានឃើញ និងឮ តើខ្មែរក្រហមបានផ្តល់ហេតុផលចំពោះការជម្លៀសដែរឬទេ? នៅពេលអម្បាញ់មិញនេះ មុននេះបន្តិចលោកបានប្រាប់ថា ខ្មែរក្រហមគេប្រកាសថា ដោយសារសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក។ ខ្ញុំចង់ចំណុចនេះ ខ្ញុំចង់ឲ្យលម្អិតបន្ថែមទៀតបាទ។

**ឆ៖** ខ្ញុំបានឮអំពីព័ត៌មាននេះ ពីអ្នកដទៃដែលបានឃើញហេតុការណ៍នេះ។ ខ្ញុំខ្លួនឯងគឺមិនដែលឮគេនិយាយថា អាមេរិកនឹងមកទម្លាក់គ្រាប់នោះទេ ដូចយើងមិនឃើញការទម្លាក់គ្រាប់បែកដូច្នេះ។ ដូច្នេះបានន័យថា វាមិនមែនជាព័ត៌មានពិតនោះឡើយ។

**ស៖** កន្លែងនេះខ្ញុំចង់សួរបញ្ជាក់លោកបន្តិច ទាក់ទងនឹងព័ត៌មានដែលថាមិនពិតនេះ ប្រជាជននិយាយមិនពិត ឬក៏អាមេរិកមិនបានទម្លាក់គ្រាប់បែក បាទ?

[០៩:០៦:៤៩]

**ឆ៖** ខ្ញុំចង់និយាយថា អ្វីដែលគេប្រាប់ប្រជាជននោះ គឺមិនពិតទេ។ ហើយដោយសារតែខ្ញុំ និងអ្នកដទៃទៀតដែលស្នាក់នៅក្នុងស្ថានទូតរយៈពេល២សប្តាហ៍ គឺមិនមានការទម្លាក់គ្រាប់បែកទេ។

**ស៖** អរគុណ ស្តេនប៊ឹក ឥឡូវនេះ ខ្ញុំមានសំណួរមួយទៀតទេ។ បន្ទាប់ពីថ្ងៃទី១៧ មេសា ៧៥ ដែលលោកបានពិនិត្យឃើញអស់រយៈ១ថ្ងៃនោះ តើបន្ទាប់មក ថ្ងៃបន្តបន្ទាប់មកហ្នឹងមានប្រជាជនដែលជម្លៀសចេញជាបន្តបន្ទាប់ពីទីក្រុងភ្នំពេញទៀតដែរឬទេបាទ?

**ឆ៖** អត់ទេ។ អ្វីដែលអាចកើតឡើង គឺថាប្រជាពលរដ្ឋស្ទើរតែទាំងអស់ គឺជិត២លាន ត្រូវគេបណ្តេញពីទីក្រុងនៅថ្ងៃដំបូង។

**លោក វ៉េង ហ៊ត់៖**

អរគុណ ស្តេនប៊ឹក ខ្ញុំអស់សំណួរហើយ ប៉ុន្តែសហការីរបស់ខ្ញុំ ថារីក អាប់ឌុលឡាក់ នឹងមានសំណួរទៅលោកទាក់ទងនឹងព្រឹត្តិការណ៍ផ្សេងៗ។

អរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:០៩:០៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ជម្រាបសួរលោក ស្តេនប៊ឹក។ ដូចបានលោកបានឮហើយឈ្មោះខ្ញុំគឺ ថារីក អាប់ឌុលឡាក់ ជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងព្រឹត្តិការណ៍នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដោយសារតែលោកស្ថិតនៅទីក្រុងភ្នំពេញនៅពេលនោះ។

ខ្ញុំសូមចាប់ផ្តើមស្រង់យកចម្លើយដែលលោកទើបផ្តល់អម្បាញ់មិញ ហើយដើម្បីសួរលម្អិតបន្តទៅទៀត។ លោកទើបតែជម្រាបជូនសហការីរបស់យើងខ្ញុំថា ការអះអាងថា អាមេរិកាំងនឹងទម្លាក់គ្រាប់បែកភ្លាមៗនោះ គឺថាមិនពិតទេ។ ហើយជាការពិតហើយ គឺថាមិនមានការទម្លាក់គ្រាប់បែកនោះទេ ដោយសារតែលោកបានឃើញដោយផ្ទាល់ភ្នែក។

ខ្ញុំសូមវិលត្រឡប់ទៅក្រោយ ប្រហែលជារយៈពេលពីរបីសប្តាហ៍ក្រោយពីការដួលរលំទីក្រុងភ្នំពេញ ដោយសារលោកជាអ្នកកាសែតគ្របដណ្តប់ព័ត៌មាននៅក្នុងប្រទេសទាំងមូល។ តើលោកមានបានជួបប្រទះរបាយការណ៍ ឬការបញ្ជាក់ណាមួយថា ការទម្លាក់គ្រាប់បែកដោយអាមេរិកាំង គឺថានឹងទម្លាក់ក្រោយទីក្រុងភ្នំពេញដួលរលំទៅនោះ?

[០៩:១០:២៧]

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** ខ្ញុំមិនមានព័ត៌មានណាបញ្ជាក់យ៉ាងដូច្នោះទេ ដែលថាអាមេរិកាំងមានផែនការទម្លាក់គ្រាប់បែកនោះទេ។ ការទម្លាក់គ្រាប់បែករបស់អាមេរិកគឺថាបានចាប់ផ្តើមនៅឆ្នាំ១៩៧០ នោះគឺថាក៏ត្រូវបានកាត់ផ្តាច់ទៅវិញនៅក្នុងឆ្នាំ១៩៧៣។ ខ្ញុំគិតថាប្រហែលជានៅក្នុងខែកក្កដា ឬខែសីហា ចាប់តាំងពីពេលនោះមកមិនមានការទម្លាក់គ្រាប់បែកទៀតទេ។ តាមខ្ញុំគត់សម្គាល់ឃើញមិនមានទេ ហើយខ្ញុំក៏មិនបានឮពីអ្នកណាអំពីការទម្លាក់គ្រាប់បែកបន្តទៅទៀតដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅបញ្ហាដែលលោកបានឆ្លើយជូនសហការីរបស់ខ្ញុំអម្បាញ់មិញ។ ចំណុចនេះគឺពាក់ព័ន្ធទៅនឹងកម្លាំងដែលចូលមកក្នុងក្រុងភ្នំពេញ ហើយដែលបាញ់ទៅលើមេឃនោះ។ លោកបាននិយាយថា កងទ័ពខ្លះគឺថាគេបានរៀបចំអបអរសាទរ ចំណុចនេះបញ្ជាក់ថានៅពេលដែលក្រុមគ្រួសារខ្លះនោះធ្វើដំណើរយឺតពេក ពួកកងទ័ពខ្មែរក្រហមហ្នឹងបានបាញ់ទៅលើដើម្បីគំរាមកំហែង។ តើមានការបាញ់បែបនេះទេ?

[០៩:១២:១៥]

**ឆ៖** ខ្ញុំបានឃើញមែន ច្បាស់ណាស់ថាពួកខ្មែរក្រហមចង់ឲ្យប្រជាជនចេញទៅលើផ្លូវឲ្យបានចាប់រហ័ស ហើយចាកចេញពីទីក្រុង។

**ស៖** សូមអរគុណ។ ប្រហែលជាយើងខ្ញុំនឹងចូលមកចំណុចនេះបន្តិចទៀត ខ្ញុំសូមនិយាយបញ្ហា ១៧ មេសា ៧៥ ដូចលោកឆ្លើយជូនសហការីរបស់ខ្ញុំដែរ គឺថាវាទាក់ទងទៅនឹងអ្វីដែលលោករៀបរាប់ព្រឹត្តិការណ៍មួយ ដែលអ្នកជំងឺត្រូវបានគេបញ្ជូនចេញទៅភាគខាងត្បូងនៃទីក្រុងភ្នំពេញ យកទៅ -- គឺថាព្រឹត្តិការណ៍មួយដែលលោកបានស្តាប់ឮនោះ គឺថាមិនមានការរៀបចំចាត់ចែងអីដើម្បីដឹកអ្នកជំងឺចេញពីមន្ទីរពេទ្យទេ។

**ឆ៖** គឺមិនមែនគ្រប់ទាំងអស់នោះទេ ក៏ប៉ុន្តែខ្ញុំចាំថាខ្ញុំបានឃើញរបាយការណ៍មួយក្រោយពេល

នុំង។ របាយការណ៍ពីជនជាតិអាមេរិកាំងម្នាក់ដែលថាគាត់នៅទីនោះ ដែលអ្នកជំងឺគេយកទៅទីនោះ។ ទីនោះគឺជាមន្ទីរពេទ្យមួយដ៏សកម្មមែនទែន ខ្ញុំស្គាល់ជនជាតិអាមេរិកាំងហ្នឹង។ គាត់បានប្រាប់មកដល់ពួកយើងខ្ញុំ ថានេះគឺជាបដិវត្តន៍កសិករ មិនមានអនាគតអីសម្រាប់កម្ពុជាទេ។

[០៩:១៥:០៥]

ខ្ញុំមិនដឹងទេនូវអ្វីដែលគាត់សរសេរនោះ មិនដឹងថាតើគាត់បានទៅកន្លែងនោះ ឬក៏បានឃើញមន្ទីរពេទ្យនោះដោយផ្ទាល់នៅពេលគាត់សរសេរអត្ថបទនោះ ឬក៏យ៉ាងណាទេ។ ដូច្នេះបើតាមខ្ញុំយល់ថា ទោះបីជាជួរ ឬក៏ខ្សែនៃប្រជាជនដែលធ្វើដំណើរឆ្ពោះទៅទិសខាងត្បូងនោះ មិនត្រូវបានរៀបចំចាត់ចែងដែលដោយមន្ទីរពេទ្យនៅទីនោះក៏ដោយ។

**ស៖** តើលោកបានឃើញអ្នករបួស អ្នកជំងឺនៅក្នុងមន្ទីរពេទ្យឃើញធ្វើដំណើរទៅទិសណាក្រៅផ្សេងដទៃទៀតក្រៅពីទិសខាងត្បូងទេ?

**ឆ៖** គឺថាចេញដំណើរគ្រប់ទិសទាំងអស់ចេញពីទីក្រុង មានតាមផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៥ ខ្ញុំឃើញ មនុស្សរាប់រយរាប់ពាន់នាក់ធ្វើដំណើរតាមផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ខេត្តសៀមរាប។

**ស៖** សូមអរគុណ ខ្ញុំសូមទុកបញ្ហានេះមួយអន្លើសិន។ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ផ្សេងៗ ទៀតនៅ១៧ មេសា ៧៥ ខ្ញុំសូមសួរសំណួរខ្លីអំពីស្ថានភាពនៅក្នុងទីក្រុងភ្នំពេញក្នុងរយៈពេល ប៉ុន្មានសប្តាហ៍ប៉ុន្មានខែក្រោយពីទីក្រុងនេះដួលរលំទៅ។

[០៩:១៥:៥៨]

តាមកំណត់ដៃរបស់លោកនោះ ដែលលោកសរសេរពីខាងដើមមកនោះ ដើម្បីប្រតិចារឹកគឺនេះគឺជាឯកសារ E236/1/4/3.1។ គឺខ្ញុំនឹងបង្ហាញនៅត្រង់ទំព័រ៩២១២, ERN 00898217 ហើយខ្ញុំសូមអានជូនតែម្តងលោក ស្កេនប៊ឺក។ នេះគឺជាចុះនៅថ្ងៃទី២១ មេសា ហើយក៏ដាក់កាលបរិច្ឆេទឡើងមកថ្ងៃទី០៩ មករា។ លោកបានឃើញឡានធំៗដែលផ្គត់ផ្គង់សម្ភារៈបរិក្ខាមកទីក្រុងភ្នំពេញ សូមដកស្រង់ “ឡានធំៗដែលដឹកសម្ភារៈបរិក្ខាផ្សេងៗបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាមកកាន់ស្ទឹង។ ខ្ញុំត្រឡប់មកទីក្រុងភ្នំពេញវិញគឺនៅថ្ងៃទី២៩ មករា នៅពេល-- ដោយសារខ្ញុំមិនបានឃើញនៅពេលនោះគឺថានៅថ្ងៃទី០២ មករា, ឡានបីទៀតនៅថ្ងៃ២៦ មករា, ហើយមួយឡានទៀតនៅ -- ហើយក៏មានកប៉ាល់មួយចំនួនទៀតធ្វើដំណើរមកភ្នំពេញដែរ។ គឺថាមានការបាញ់ផ្លោងសំដៅទៅទីនោះ។ មានរបាយការណ៍ថាកប៉ាល់ពីរត្រូវបានលិច ហើយមធ្យោបាយដឹកចំនួនមួយនេះគឺបង្ខំឲ្យទៅកាន់វៀតណាមខាងត្បូងវិញ”។

នៅទំព័របន្តបន្ទាប់មកទៀត លោកក៏បាននិយាយអំពីក្បួនរថយន្តមួយចំនួនទៀត។ តើខ្ញុំសូមសួរលោកបានទេ ថាតើហេតុអ្វីបានជាលោកអាចកត់សម្គាល់ឃើញបញ្ហានេះ ក៏ទទួលព័ត៌មាន? ហេតុអ្វីក៏បានជាខ្សែរថយន្តធំៗនេះវាជាការចាំបាច់នោះ?

[០៩:១៨:១៣]

**ធ៖** បានជាវាចាំបាច់នេះគឺដោយសារថា សង្គ្រាមបានរីករាលដាលយ៉ាងឆាប់រហ័ស។ ហើយប្រជាជននាំគ្នាសម្រុកចេញពីជនបទ ចូលមករស់នៅក្នុងទីក្រុងភ្នំពេញមិនមានស្រូវអង្ករគ្រប់គ្រាន់ទេ។ ហើយក៏ខ្វះខាតនូវសម្ភារៈដទៃទៀត ខ្វះប្រេងឥន្ធនៈ រថយន្តចំណីអាហារគឺថាជាចំណុចមួយដែលខ្វះខាតមែនទែនមិនអាចបំពេញតម្រូវការបាននាពេលនោះ។

នៅក្នុងខែមករា គឺនៅទូទាំងផ្ទៃប្រទេសរហូត ដល់ប្រទេសនោះធ្លាក់ចូលក្នុងដៃខ្មែរក្រហមតែម្តងនៅថ្ងៃ ១៧ មេសា។ នៅតាមផ្លូវគឺយើងអាចឃើញ ឬក៏នៅទៅតាមទីធ្លាខាងក្រោយ ខ្មែរហ្នឹងកើតជំងឺហើម ស្លឹក ឬក៏អត់ឃ្លាន ហើយមានតម្រូវការចាំបាច់បំផុត ប្រេងឥន្ធនៈជារឿងចាំបាច់បំផុតដើម្បីធ្វើម៉េចឲ្យមានភ្លើងអគ្គីសនីនេះ។ ហើយរហូតមកដល់ចុងបញ្ចប់គឺមិនមានប្រេងឥន្ធនៈដើម្បីអាចអុជបំភ្លឺ ឬក៏ផ្តល់ផ្គត់ផ្គង់ចរន្តអគ្គិសនីបានទេ។

**ស៖** សូមអរគុណ ខ្ញុំសូមកាត់ផ្តាច់លោកត្រង់នេះបន្តិច។ នៅក្នុងអត្ថបទដែលយើងកំពុងពិនិត្យមើលទាំងអស់គ្នានេះ។ លោកបាននិយាយថាខ្សែរថយន្តនោះ គឺថាចាកចេញភ្លាមៗ ហើយនៅពេលកប៉ាល់នេះចូលមកដល់ ក៏មានការបាញ់ផ្លោងគ្រាប់រ៉ុក្កែតកម្ទេចដែរ។ តើលោកបញ្ជាក់អះអាងអំពីការសម្ភាស ឬក៏ការកត់សម្គាល់របស់លោកបានទេ អ្នកណាជាអ្នកបាញ់ទៅលើក្បួនរថយន្តទាំងនុ៎ង?

[០៩:២០:៤២]

**ធ៖** ប្រជាជនទាំងអស់ដែលរាយការណ៍ពីបញ្ហានេះ ឬក៏បានសម្ភាសអំពីបញ្ហានេះថាគឺខ្មែរក្រហមជាអ្នកបាញ់ មិនមែនកងទ័ពវៀតណាមទេ ហើយឯកសណ្ឋាននោះក៏វាខុសគ្នាផងដែរ។ ខ្ញុំមិនមានហេតុផងស្អីដែលគួរឲ្យសង្ស័យទេនូវអ្វីដែលគេបានប្រាប់មកខ្ញុំនោះ។

**ស៖** បាទសូមមើលសេចក្តីសង្ខេប ការរៀបរាប់សង្ខេបមួយទៀតដែលលោកបានលើកឡើងហ្នឹង គឺឯកសារផ្សេងគ្នា ឯកសារដែលខ្ញុំបានផ្ញើជូនទៅលោក ដោយមានការអនុញ្ញាតពីតុលាការរួចហើយគឺជាសៀវភៅហៅថា វាលពិឃាត។ គឺការពិតបង្ហាញពីខ្សែភាពយន្តឯកសារដែលគឺ E3243.2។ អ្វីដែលខ្ញុំចាប់អារម្មណ៍គឺអត្ថបទកាសែត ដែលត្រូវបានចុះផ្សាយឡើងវិញ នៅក្នុងសៀវភៅនេះសរសេរ

ឡើងវិញ គឺត្រង់ទំព័រ៣៨ ចំណងនោះគឺថា “សង្គ្រាមនៅមេគង្គមុនការដួលរលំទីក្រុងភ្នំពេញ”។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសូមការអនុញ្ញាតដើម្បីបញ្ចាំងឯកសារនេះលើអេក្រង់កំព្យូទ័រ។

[០៩:២២:១៣]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បាទអត្ថបទនេះច្បាស់ណាស់ ខ្ញុំសូមអានត្រង់ទំព័រ៣៨ ERN អង់គ្លេស 00862586 អត់មានការបកប្រែទៅជាភាសាខ្មែរ ភាសាបារាំងទេ គឺសង្គ្រាមនៅមេគង្គ គឺជារឿងគ្រោះថ្នាក់មួយសម្រាប់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ដែលអ្នកសរសេរគឺលោកតែម្តង។

បាទសូមលើកអត្ថបទខ្លីទេ សូមដកស្រង់ “ពួកបះបោរកម្ពុជាដោយមានដាក់មីននៅក្នុងទន្លេមេគង្គជាលើកដំបូង ហើយដោយមានការបាញ់ផ្លោងនៅច្រាំងមាត់ទន្លេយ៉ាងធ្ងន់ធ្ងរនៅក្នុងរយៈពេល១០ថ្ងៃចុងក្រោយ ហើយធ្វើឱ្យមាន ដើម្បីកាត់ផ្តាច់ចរាចរណ៍ផ្លូវទឹក”។

តើត្រឹមត្រូវទេលោក ស្កេនប៊ឹក បើសិនណាជាខ្ញុំសូមសួរឱ្យបានទូលាយបន្តិចទៅលើអ្វីដែលលោកបានយល់ឃើញ រកឃើញគេនេះ ហៅថា ការផ្គត់ផ្គង់នោះ គឺថាត្រូវបាញ់ពន្លិចនៅក្នុងទន្លេមេគង្គរយៈពេល១០ថ្ងៃ ដើម្បីកាត់ផ្តាច់ចរាចរណ៍ផ្លូវទឹកនេះ?

[០៩:២៣:៤៥]

**ឆ៖** ព័ត៌មាននេះ គឺបានមកពីសៀវភៅមួយចំនួន គឺមកពីនាវិកតែម្តង។ ខ្ញុំមិនមានហេតុផលអីទេ ពីព្រោះយើងបានទទួលពីប្រភពផ្សេងៗទៀត ថាតើកប៉ាល់ប៉ុន្មានបានចាកចេញពីសៃហ្គនឆ្ពោះមកកាន់ទន្លេមេគង្គ ហើយស្ថានភាពនៅពេលនោះ គឺថាធ្ងន់ធ្ងរណាស់។ មេគង្គពេលហ្នឹង គឺថាត្រូវកាត់ផ្តាច់គឺថាគ្មានអ្នកណាម្នាក់អាចធ្វើដំណើរតាមទូក ឬម៉ារីនបានទេ ធ្វើដំណើរដើម្បីចូលមកភ្នំពេញបានទេ។ ហើយនៅចុងបញ្ចប់ អាមេរិកកាំងមានផែនការប្រើប្រាស់យន្តហោះ ដើម្បីទម្លាក់អាហារ គឺទម្លាក់អាហារពីលើអាកាសមកវិញ តាមរយៈកប៉ាល់ហោះនេះតែម្តង។ ដោយសារតែបញ្ហាទន្លេមេគង្គវាមានគ្រោះថ្នាក់មែនទែនសម្រាប់មធ្យោបាយផ្គត់ផ្គង់ស្បៀងអាហារនេះ។ ហើយនៅពេលនោះរដ្ឋាភិបាលលន់ នល់ នៃប្រទេសកម្ពុជាមិនអាចរុញច្រានពួកខ្មែរក្រហមបានទេ។

**ស៖** ខ្ញុំសូមសួរសំណួរដើម្បីភ្ជាប់ទៅនឹងចំណុច ទាក់ទងទៅនឹងខ្សែរថយន្តធំៗក៏បានបញ្ចប់ការផ្គត់ផ្គង់ ហើយក៏ផ្តល់ការផ្គត់ផ្គង់តាមរយៈការផ្តល់មធ្យោបាយតាមយន្តហោះទៅវិញ។ ក្រោយពីការដួលរំលំទីក្រុងភ្នំពេញ តាមដែលលោកដឹងនោះ តើមានគោលបំណងណាមួយដែលត្រូវធ្វើឡើងដោយពួកខ្មែរក្រហមដើម្បីសម្របសម្រួលក្នុងការផ្គត់ផ្គង់ជំនួយមនុស្សធម៌ ដើម្បីដោះស្រាយបញ្ហាខ្វះខាតដូចដែលលោករៀបរាប់ទេ?

[០៩:២៦:១៧]

**ឆ៖** ផ្ទុយគ្នាស្រឡះលោក គឺមិនដូច្នេះទេ។ ខ្មែរក្រហមដែលមកពីកើតមកពីប្រជាជននៅតាមទីជនបទ គឺគេចង់ឲ្យប្រជាជនទីក្រុងចូលរួមជាមួយគេ។ គេចង់កសាងម៉ាស៊ីនបញ្ចោះសង្គ្រាមរបស់ពួកគេ គេគ្មានគោលបំណងអីដើម្បីយកស្បៀងអាហារចូលមកផ្តល់ឲ្យប្រជាជននោះទេ។ នៅពេលដែលខ្ញុំចេញទៅតាមតំបន់មួយចំនួន ដែលថានៅពេលនោះ គឺនៅពេលយប់ គឺថាមិនមានការចង់ផ្គត់ផ្គង់បែបនេះទេ។

**ស៖** យើងខ្ញុំនឹងសួរលម្អិតទៅលើចំណុចនេះនៅពេលក្រោយបន្តិចនេះ។ ចំណុចមួយទៀតយើងនិយាយអំពីរយៈពេលតែប៉ុន្មានសប្តាហ៍ ឬប៉ុន្មានខែក្រោយពីការដួលរំលំទីក្រុងភ្នំពេញ។ ចំណុចមួយវាគួរឲ្យចាប់អារម្មណ៍នេះ គឺការបាញ់ផ្លោងចូលមកទីក្រុងដែលលោកបានសរសេរនៅក្នុងកំណត់ត្រាប្រចាំថ្ងៃរបស់គេ ហើយនៅក្នុងអត្ថបទដែលលោកសរសេរ អត្ថបទព័ត៌មានដែលលោកសរសេរ។ មានឧទាហរណ៍មួយចំនួន ប៉ុន្តែខ្ញុំជ្រើសរើសយកតែឧទាហរណ៍មួយ ឬក៏ពីរ ដើម្បីឲ្យលោកអាចនឹងពន្យល់ឲ្យបានទូលំទូលាយបន្តិចដល់អង្គជំនុំជម្រះ។ នៅទំព័រ៣៨ នៃកំណត់ដៃប្រចាំថ្ងៃរបស់លោកគឺចុះថ្ងៃទី០៦ កុម្ភៈ ERN 00898221។

[០៩:២៨:១៤]

លោកបានសរសេរដូចតទៅ សូមដកស្រង់ “នៅមុនម៉ោងដប់ព្រឹក គឺគ្រាប់រ៉ុក្កែតបាញ់សម្រុកចូលមកទីក្រុងភ្នំពេញ គឺសំដៅមកដល់សាលារៀនដែលមានសុទ្ធតែសិស្សនៅសាលាបឋមសិក្សា និងទិដ្ឋភាពទីក្រុងភ្នំពេញ គឺថាគួរឲ្យរន្ធត់បំផុត។ កុមារត្រូវរបួសឈាមក្នុងថ្លុកឈាម ហើយរស់នៅជីវិតប៉ុន្តែមិនអាចរស់រានបានយូរទេ”។ កថាខណ្ឌបន្ទាប់គឺថា “យ៉ាងហោចណាស់កុមារ១០នាក់បានស្លាប់ភ្លាមៗ ហើយមាន២៥ ឬក៏៣០នាក់ កុមារផ្សេង២៥-៣០នាក់ទៀតរងរបួស”។ បានខ្ញុំបងញ្ចប់ត្រឹមនេះ។

ខ្ញុំសូមឲ្យលោករៀបរាប់ជូនអង្គជំនុំជម្រះ ថាតើនេះការកើតឡើងញឹកញាប់ ឬក៏យ៉ាងណាការ

បាញ់ផ្លោងនេះ ដែលបាញ់ផ្លោងសំដៅមកលើគោលដៅជនស៊ីវិលរស់នៅទីក្រុងភ្នំពេញនៅក្នុងអំឡុងខែកុម្ភៈ មីនា មេសា ៧៥នោះ?

[០៩:២៩:២៧]

**ឆៈ** ពិតហើយ រ៉ុក្កែតនេះ ជាគ្រាប់រ៉ុក្កែតធ្វើឡើងដោយប្រទេសចិន។ ខ្មែរក្រហមបានប្រើប្រាស់គ្រាប់រ៉ុក្កែតទាំងនេះ។ ហើយគេគ្មានមធ្យោបាយពិតប្រាកដ ឬក៏គឺឬក៏ហៅថាកាណុងរ៉ុក្កែតពិតប្រាកដដើម្បីបាញ់ទៅក្នុងអាកាសនោះទេ ប៉ុន្តែគេភ្ជាប់ជាមួយនឹងឈើ ដើម្បីបាញ់ផ្លោងមកគោលដៅជាក់លាក់ណាមួយ។ ដូច្នេះគ្រាប់រំសេវទាំងនេះគឺថាជាការបាញ់ផ្លោងនេះគឺជាការបាញ់ផ្លោងមួយដែលអសីលធម៌មែនទែនតែម្តង។ គ្រាប់រ៉ុក្កែតមួយគឺធ្លាក់មកខាងក្រៅសណ្ឋាគារមួយដែលខ្ញុំស្នាក់នៅ ហើយវាផ្ទុះដែលមានអំបែងហ្នឹងរីករាលដាលប៉ះពាល់ទៅដល់ប្រជាជន ហើយគេអត់មានការឈប់បាញ់បែបនេះទេ នៅតែបាញ់ផ្លោងមករហូតដល់ថ្ងៃដែលគេជម្លៀសប្រជាជនហ្នឹងចេញពីស្ថានទូតអាមេរិកឯណោះ។

**សៈ** សូមបន្តពីចំណុចនេះតទៅទៀត នៅក្នុងការដែលលោករៀបរាប់អំពីការបាញ់ផ្លោងនេះ ខ្ញុំទៅចូលទៅទំព័រ២០ នៃកំណត់ដៃរបស់លោក ERN អង់គ្លេស 00898228 ដែលលោករៀបរាប់ព្រឹត្តិការណ៍នៅខែមីនា រហូតមកដល់ថ្ងៃទី០៥ ខែមីនា។

[០៩:៣១:០១]

បាទ មានចំណុចមួយចំនួននៅក្នុងនេះសូមដកស្រង់ "រ៉ុក្កែតបានបាញ់ផ្លោងមកជាយក្រុង ដោយសុទ្ធតែមានមនុស្សនៅទល់មុខសណ្ឋាគារមនោរម្យ។ ប្រជាជនប្រាំនាក់បានស្លាប់ភ្លាម ប្រាំបីនាក់ផ្សេងទៀតបានរងរបួស។ ផ្លូវទាំងអស់គឺថាមានពោរពេញទៅដោយមនុស្សដែលស្លាប់ គឺហាក់បីដូចជាកន្លែងដែល កន្លែងសត្តឃាតអ៊ីចឹង"។

ខាងក្រោមនេះបន្តិចនៅទំព័រដដែលនៅខែមីនា ថ្ងៃទី០៥ លោកបាននិយាយថា "ពួកបះបោរបានប្រើគ្រាប់កាំភ្លើងធំរហូតមកទល់ពេលនេះគេបានប្រើប្រាស់តែរ៉ុក្កែតដែលគេហៅថា បាញ់មិនចំទិសដៅណានោះទេ"។ ខ្ញុំសូមឲ្យលោកពន្យល់បន្តិច ថាតើលោកកត់សម្គាល់ឃើញថាម៉េច ដែលថាតើមានគ្រាប់រ៉ុក្កែត ឬអាល់តេរីហ្នឹងបែបណាដែលបាញ់ចំទិសដៅនោះ?

**ឆៈ** ពួកខ្មែរក្រហមបានប្រើ គេហៅថា "ម៉កជេរ"--

**ប្រធានអង្គជំនុំៈ**

កុំអាលទាន់ឆ្លើយតបលោកសាក្សី! មានការជំទាស់តវ៉ាពីមេធាវីការពារក្តីលោក ខៀវ សំផន។

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទៅលើការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិកន្លងមកនេះ។ ខ្ញុំពិនិត្យឃើញថារយៈពេលប្រហែល១ម៉ោងកន្លងផុតទៅហើយ ហើយតំណាងសហព្រះរាជអាជ្ញាសាកសួរទៅលើសំណួរទាំងឡាយដែលមិនជាប់ទាក់ទងទៅនឹងយុត្តាធិការរបស់តុលាការនៅឡើយទេ។ គឺគាត់បានលើកនូវពេលវេលាមុនឆ្នាំ១៩៧៥ គឺមុនពេលវេលានៃយុត្តាធិការរបស់តុលាការនេះ។ ដូច្នេះខ្ញុំយល់ឃើញថា វាអាចនឹងមិនមានប្រយោជន៍ច្រើនសម្រាប់ដល់តុលាការក្នុងការធ្វើការវិនិច្ឆ័យទៅលើព័ត៌មានទាំងឡាយដែលបានផ្តល់ដោយសាក្សីរូបនេះ។ អ៊ីចឹងសូមលោកប្រធានមេត្តាពិនិត្យ សូមអរគុណ។

[០៩:៣៣:៥៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ យើងខ្ញុំយល់ឃើញថា ការជំទាស់នេះគឺមិនត្រឹមត្រូវទាល់តែសោះ។ តុលាការបានស្តាប់ភស្តុតាងជាច្រើនចំពោះព្រឹត្តិការណ៍មុនថ្ងៃ១៧ មេសា ៧៥ ភាគច្រើនពីសាក្សីជំនាញ ហ្វីលីព ស្ប៊ត។ ព្រឹត្តិការណ៍នេះពិតជាពាក់ព័ន្ធមែនទែនទៅនឹងបរិបទ ដើម្បីជួយឲ្យស្វែងរកការពិតទាក់ទងទៅនឹងគោលនយោបាយខ្មែរក្រហម ឆ្ពោះមកកាន់ទីក្រុងភ្នំពេញនោះ។

ខ្ញុំក៏សូមរំឭកដល់អង្គជំនុំជម្រះផង ហើយជនជាប់ចោទទាំងពីរគឺបានបដិសេធថា ការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញនេះគឺជាបញ្ហានៃការជួយដល់បញ្ហាមនុស្សធម៌ទៅវិញទេ។ ប៉ុន្តែយើងចង់មើលដោយផ្ទាល់ថាតើជំហររបស់អ្នកទាំងនោះ មានជំហរយ៉ាងម៉េចទៅលើប្រជាជនចំពោះការជម្លៀសប្រជាជននៅក្នុងរយៈពេលពីរបីសប្តាហ៍ ឬក៏ប៉ុន្មានខែក្រោយពីទីក្រុងភ្នំពេញដួលរលំទៅ តើគេគិតគូរយ៉ាងណានោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៥:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចច្រានចោលនូវសង្កេត ឬការកត់សម្គាល់ពីសំណាក់មេធាវីជាតិការពារក្តីលោក ខៀវ សំផន។ អង្គជំនុំជម្រះត្រូវការស្តាប់នូវភស្តុតាងទាំងនេះ ដើម្បីស្វែងរកការពិតក្នុង

រឿងក្តីនេះ។ ហើយការបង្ហាញហេតុផលរបស់តំណាងសហព្រះរាអាជ្ញាមានលក្ខណៈសមស្រប។

លោកសាក្សីបើលោកនៅចងចាំ សូមលោកឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយ ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ។

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** *(គ្មានការបកប្រែ)*

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** លោក ស្កេនប៊ឹក តើលោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញដែរឬទេ គឺសំណួរពាក់ព័ន្ធទៅនឹងការរៀបរាប់របស់លោកនៅថ្ងៃទី០៥ មីនា ដែលលោកនិយាយអំពីរ៉ុក្កែតដែលបាញ់មិនសូវចំកន្លែងនោះនៅពេលដែលបាញ់ទៅលើអាកាសយានដ្ឋាន?

**ឆ៖** គឺវាបាញ់ទៅនៅជិតអាកាសយានដ្ឋានតែប៉ុណ្ណោះ ហើយគេប្រើអាវុធយុទ្ធភណ្ឌទំនើបៗជាងនោះ។ គឺបានន័យថា គេបាញ់ដើម្បីឲ្យចំអាកាសយានដ្ឋាន។ កន្លែងនោះហើយគឺជាកន្លែងអាកាសយានដ្ឋាន គឺជាកន្លែងដែលផ្គត់ផ្គង់នូវស្បៀង ឬក៏អាវុធ។ ដូច្នេះហើយគឺអាកាសយានដ្ឋាននោះ ក៏ជាកន្លែងដែលភ្ជាប់នូវពីទំនាក់ទំនងពីកន្លែងផ្សេង។ ដូច្នេះគេត្រូវការវាយប្រហារឲ្យចំអាកាសយានដ្ឋាននោះដោយសារវាជាកន្លែងចាំបាច់។ ហើយវាជាហេតុការណ៍មួយអវិជ្ជមាន គឺការវាយប្រហារនេះ វាបានបន្តរហូតដល់តំណាក់កាលចុងក្រោយ។

[០៩:៣៨:២៣]

នៅពេលចុងក្រោយនោះ គឺថាភ្នំពេញបានក្លាយទៅជាគុក មានប្រជាជនប្រហែលជា១លាននាក់នៅក្នុងទីក្រុងភ្នំពេញមុនពេលសង្គ្រាម ប៉ុន្តែក្រោយមកគឺថាមានប្រជាជន១លានទៀត បានហូរចូលមកទីក្រុងភ្នំពេញដើម្បីគេចេញពីការវាយប្រហាររបស់ខ្មែរក្រហមនៅតាមទីជនបទ។ ដូច្នេះនៅពេលនោះ គឺថាអ្នកដែលចូលមកទីក្រុងភ្នំពេញបានក្លាយទៅជាអ្នកគុក នៅក្នុងគុកទាំងអស់។

**ស៖** ខ្ញុំសូមទុកបញ្ហានេះមួយអន្លើសិន ហើយខ្ញុំសូមចូលទៅដល់ដំណាក់កាលមួយទៀត។ នៅត្រង់ទំព័រ២៣, ERN ជាភាសាអង់គ្លេស 00898321 ប្រសិនបើខ្ញុំសូមឲ្យឆ្លើយដោយខ្លីៗ ហើយខ្ញុំនឹងអានការដកស្រង់នេះឲ្យលោកឆ្លើយ។ "ការបាញ់អាកាសយានដ្ឋានបានបន្តបាញ់ផ្តោងពីខាងលើ។ អាកាសយានដ្ឋាន -- កប៉ាល់ហោះដើម្បីផ្គត់ផ្គង់សម្ភារៈផ្សេងៗនោះ គឺកំពុងតែចុះចូលទៅផ្នែកយោធា ហើយយើងឃើញមានគ្រាប់មួយចំនួននោះ បានធ្លាក់នៅលើដី ដែលន័យថាគឺមានអ្នកគេឃ្លាំមើលដើម្បីបាញ់

ឲ្យចំ"។ ដូច្នេះហើយខ្ញុំសូមសួរលោក ថាតើនៅពេលនោះ មានគ្រាប់ផ្លោងចំកន្លែងនោះដែរឬទេ?

[០៩:៤០:០៦]

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

បាទ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក វិុចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំបានស្តាប់ការតាំងសំណួររបស់សហព្រះរាជអាជ្ញាមួយសន្ទុះដែរ ក៏ប៉ុន្តែដល់ពេលដែលខ្ញុំត្រូវជំទាស់ទៅនឹងការ ដែលគាត់រៀបចំសំណួររបស់គាត់ឡើងវិញដោយរបៀបនេះហើយ។ យើងត្រូវតែគោរពតាមវិធានរបស់យើង យើងកុំភ្លេចថាលោក ស្តេនប៊ឹក នៅទីនេះគឺឆ្លើយក្នុងនាមជាសាក្សី។ ជាការពិតលោក ស្តេនប៊ឹក ក៏ជាអ្នកកាសែតធ្លាប់និពន្ធសៀវភៅ ឬក៏អត្ថបទទៅលើប្រធានបទនេះផងដែរ។ ក៏ប៉ុន្តែលោក ស្តេនប៊ឹក មិនមែនឆ្លើយក្នុងនាមអ្នកជំនាញនោះឡើយ។

[០៩:៤០:៥៦]

ហេតុដូច្នេះយើងគួរតែកម្រិតការតាំងសំណួររបស់យើងនេះ នៅពេលដែលយើងសួរលោក ស្តេនប៊ឹក ជាពិសេសទៅលើកន្លែងដែលគាត់បានឃើញដោយផ្ទាល់ខ្លួន ឬក៏គាត់សង្កេត។ ហើយប្រសិនបើគាត់បានឃើញ ឬបានឮនោះ ថាតើប្រភពនោះគួរឲ្យជឿជាក់ដែរឬទេ?

ក៏ប៉ុន្តែប្រសិនបើយើងសូមឲ្យលោក ស្តេនប៊ឹក ធ្វើការស្មានអំពីវិធីសាស្ត្ររបស់ខ្មែរក្រហម ការបាញ់របស់ខ្មែរក្រហមនោះ គឺវាហាក់ដូចជាហួសនូវសមត្ថភាពរបស់គាត់ក្នុងនាមជាសាក្សីដែលគាត់មកឆ្លើយនៅថ្ងៃនេះ។ លោក ស្តេនប៊ឹក មិនមែនជាជំនាញនោះទេ ហើយគាត់ជាសាក្សី។ ដូច្នេះយើងគួរតែធ្វើការសួរសំណួររបស់គាត់ សំណួរទៅកាន់គាត់ក្នុងនាមជាសាក្សី។ ខ្ញុំសូមជំទាស់ការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានខ្ញុំសួរសំណួរនេះ មិនមែនសួរអ្នកជំនាញនោះទេ គឺគ្រាន់តែសួរព័ត៌មានដែលគាត់បានសង្កេតឃើញ។ គាត់សង្កេតឃើញថា គ្រាប់នោះគឺវាធ្លាក់បាញ់ទៅនៅពេលដែលយន្តហោះកាន់តែចុះជិតទៅដល់ដី។ ដូច្នេះហើយការជំទាស់របស់មេធាវីមិនត្រឹមត្រូវនោះទេ។ លោក ស្តេនប៊ឹក គឺគាត់

មានសមត្ថភាពក្នុងការបង្ហាញទៅលើចំណុចនេះ ហើយគាត់បានដឹង អាចធ្វើការសន្និដ្ឋានទៅតាមអ្វីដែលគាត់បានសង្កេតឃើញនៅក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយហេតុការណ៍នោះ។

[០៩:៤២:១៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការឆ្លើយតបដោយខ្លី។ ចំណុចនេះគឺជាចំណុចដែលខ្ញុំចង់លើកឡើងហើយ គឺមិនមែនសាក្សីនេះមិនអាចធ្វើសេចក្តីសន្និដ្ឋាននោះទេ។ សេចក្តីសន្និដ្ឋាននោះ គឺថាទាល់តែអ្នកជំនាញទើបអាចធ្វើបាន។

ប្រសិនបើលោកប្រធានសួរខ្ញុំ ឬលោកស្រីចៅក្រមសួរខ្ញុំនោះ គឺថាខ្ញុំគិតថាវាមានបញ្ហា ប្រសិនបើយើងសួរសំណួរទៅកាន់សាក្សីក្នុងនាមជាអ្នកជំនាញបែបនេះ វានឹងបង្កើតជាបញ្ហា។ លោក ស្តេនប៊ឺក ប្រហែលជាមានគុណវុឌ្ឍិជាអ្នកជំនាញ ក៏ប៉ុន្តែយើងមិនឲ្យមិនត្រូវសួរគាត់ឲ្យគាត់ធ្វើសេចក្តីសន្និដ្ឋានទៅតាមអ្វីដែលគាត់ស្តាប់ឮ បានឃើញនោះទេឡើយ។

[០៩:៤៣:០១]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៥:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសម្រេចលើបញ្ហាជំទាស់តវ៉ាចំពោះសំណួរដែលសួរចុងក្រោយដោយមេធាវីការពារក្តីលោក នួន ជា។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមឲ្យចៀសវាងការដែលលើកឡើងថាសាក្សីនេះត្រូវតែមានសិទ្ធិបង្ហាញជំនាញរបស់ខ្លួន។ ដូច្នេះតំណាងសហព្រះរាជអាជ្ញាត្រូវតែអញ្ជើញឲ្យរៀបចំសំណួររបស់ខ្លួនឡើងវិញដែលលោកនិយាយថា យោងតាមលោកបានសរសេរតាមកំណត់ហេតុរបស់លោកនោះតើលោកយោងយ៉ាងម៉េចទៅលើកំណត់ហេតុនេះ។ ដូច្នេះសហព្រះរាជអាជ្ញាគួរតែរៀបចំសំណួររបស់ខ្លួនឡើងវិញ។

[០៩:៤៧:៤៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ដូចដែលអង្គជំនុំជម្រះបានបង្គាប់ យើងមើលទៅលើអត្ថបទនេះ ខ្ញុំសូមអានឡើងវិញដើម្បីឲ្យយើងយល់និងទាំងអស់គ្នាដឹង។ “ការបាញ់ផ្លោងចូលអាកាសយានដ្ឋានបានបន្ត យន្តហោះផ្គត់ផ្គង់យន្តហោះផ្សេងដើម្បីការពារនោះគឺកំពុងតែចូលទៅកាន់តែជ្រៅផ្នែកឃោធានៅអាកាសយានដ្ឋាន។ គ្រាប់ផ្លោងនោះធ្លាក់នៅពេលដែលយន្តហោះទាំងអស់នោះចុះទៅដល់ដី។ ដូច្នេះបានន័យថា កងកម្លាំងដែលចាំវាយសម្រុកចូលនោះ ដូចជាមានអ្នកសង្កេតការណ៍ជាមុន”។

ដូច្នេះតាមដែលការបង្គាប់របស់អង្គជំនុំជម្រះ តើលោកមានការសង្កេតយ៉ាងម៉េចទើបលោកបាននិយាយថា ខ្មែរក្រហម ឬក្រុមទាហាននោះមានអ្នកសង្កេតការណ៍ជាមុនដើម្បីរៀបចំការវាយផ្លោង?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** គឺបានន័យថាគេប្រើប្រាស់កែវយឹត--

[០៩:៤៧:៥៨]

**ស៖** ខ្ញុំសូមស្កាត់ សូមឲ្យលោក ស្កេនប៊ឺក ធ្វើការនិយាយឡើងវិញនូវចម្លើយរបស់លោកដោយសារយើងនិយាយស្តាប់បានតែមួយកំណាត់ទេ។

**ឆ៖** ខ្ញុំសន្និដ្ឋានចំណុចនេះគឺយើងឃើញថា នៅពេលនោះមានអ្នកសង្កេតការណ៍ អ្នកចាំមើលនៅជិតអាកាសយានដ្ឋាន ដោយសារតែពីមុនពេលបាញ់លើកមុនៗនោះគឺថា ការបាញ់ផ្លោងនោះដូចជាមិនចំគោលដៅនោះទេ។ ក៏ប៉ុន្តែគឺក្នុងរយៈពេលប៉ុន្មានថ្ងៃនាពេលនោះគេបានលើកឡើងថា គេរើលុកចូលកាន់តែកៀកទៅៗហើយ។ ដូច្នេះគេរើចូលទៅដល់កៀកកន្លែងយន្តហោះដែលផ្គត់ផ្គង់នូវស្បៀងរួចទៅហើយ។ ដូច្នេះបានន័យថា ប្រសិនមិនមានអ្នកសង្កេតមើល សង្កេតពីជិតៗនោះទេ ធ្វើម្តេចបានជាគេបានបាញ់ផ្លោងចំល្អជាងមុនទៅ។ ដូច្នេះ ចំណុចនេះគឺបានន័យថាវាមិនមានអ្វីដែលវាផ្លាស់ប្តូរត្រង់ចំណុចនេះនោះទេដែលខ្ញុំបានឃើញនោះ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំត្រង់ចំណុចនេះ។ តើមានផលប៉ះពាល់អ្វីដែលបានកើតឡើងដោយសារមានការបាញ់ផ្លោងទៅលើកន្លែងដែលមានការផ្គត់ផ្គង់អាហារនោះ?

[០៩:៤៩:៣៧]

**ឆ៖** ប្រសិនបើយើងគិតអំពីស្បៀងដែលគេផ្គត់ផ្គង់នោះ ហើយនៅពេលដែលទ័ពវាយលុករបស់ខ្មែរក្រហមធ្វើការវាយបន្តទៅមុខសម្រុកចូលទៀតនោះ គឺបានន័យថាម្ហូបអាហារស្បៀងកាន់តែតិចៗទៅ។ តម្រូវការផ្សេងៗដូចជាប្រេងឥន្ធនៈកាន់តែថយទៅៗ។ ដូច្នេះបានន័យថា វា ហេតុការណ៍នេះវាមានការលំបាក និងកាន់តែធ្ងន់ធ្ងរទៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារលោក នួន ជា!

**លោក វិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំឡើងឃើតបន្តិចជំទាស់ឆ្លើយនេះ ចម្លើយនេះបានឆ្លើយទៅលឿនជាងសំណួរ។ ដូច្នេះហើយខ្ញុំសូមធ្វើការសង្កេត ហើយស្នើសុំអង្គជំនុំជម្រះថា ខ្ញុំមិនត្រឹមតែគិតថា សហព្រះរាជអាជ្ញាគួរតែណែនាំឲ្យរៀបចំសំណួររបស់គាត់ទៅកាន់បុគ្គលរូបនេះ ក្នុងនាមជាសាក្សីនោះទេ។ សាក្សីនោះក៏គួរតែត្រូវបានណែនាំឲ្យឆ្លើយតបទៅនឹងសំណួរទាំងឡាយណា ដែលសាក្សីបានឃើញបានស្តាប់ឮតែប៉ុណ្ណោះ។ ទោះបីជាសំណួរបានរៀបចំឡើងតាមការណែនាំរបស់អង្គជំនុំជម្រះក៏ដោយ ក៏ប៉ុន្តែសាក្សីហ្នឹងបានឆ្លើយ ហាក់ដូចជាគាត់ហ្នឹងជាអ្នកជំនាញទៅវិញ។

[០៩:៥១:១៥]

ហេតុដូច្នេះក៏មានការ គួរតែមានការណែនាំពីអង្គជំនុំជម្រះទៅកាន់សាក្សី ហើយឲ្យសាក្សីចៀសវាងកុំធ្វើការសន្និដ្ឋាន ឬក៏កុំធ្វើសេចក្តីសន្និដ្ឋាន វាទូលំទូលាយឈានទៅដល់ការសន្និដ្ឋាន ឬក៏ឆ្លើយជាលក្ខណៈសន្និដ្ឋាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម មេធាវីយល់ខុសហើយ សាក្សីគ្រប់ទាំងអស់ៗ គឺមានសិទ្ធិផ្តល់ភស្តុតាងទៅតាមអ្វីដែលពួកគាត់សង្កេតឃើញ បានឃើញ ឬក៏ប្រជាជនសាមញ្ញនោះ ក៏អាចធ្វើការទាញសន្និដ្ឋានតាមការសង្កេតទៅលើហេតុការណ៍ដែលខ្លួនបានឃើញនោះដែរ។ វាមិនមែនជាចម្លើយដែលធ្វើឡើងដោយអ្នកជំនាញទេ ប្រសិនជាឆ្លើយបែបនេះ គឺជាការឆ្លើយរបស់បុគ្គលម្នាក់ដែលបានសង្កេតឃើញ ហើយទាញសន្និដ្ឋានទៅលើហេតុការណ៍ទាំងអស់នោះតែប៉ុណ្ណោះ។

[០៩:៥២:១៣]

ដូច្នេះអ្នកសង្កេតការណ៍ទៅលើហេតុការណ៍ទាំងអស់នោះ អាចទាញសេចក្តីសន្និដ្ឋានបាន។

ដូច្នេះការសន្និដ្ឋានទាំងអស់ គឺតាមការដឹងរបស់បុគ្គលរូបនេះ ហើយសាក្សីរូបនេះគឺជាសាក្សីដែលអាចទាញសេចក្ដីសន្និដ្ឋានតាមព័ត៌មានដែលគាត់បានសរសេរនៅក្នុងសៀវភៅរបស់គាត់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការឆ្លើយតបលោកប្រធាន។ សាក្សីបានផ្ដល់សក្ខីកម្មហាក់ដូចជានិយាយអំពីការប្រព្រឹត្តរបស់ខ្មែរក្រហម វាយប្រហារទៅលើរដ្ឋាភិបាល លន់ នល់។ ដូច្នេះគាត់មិនមែនឆ្លើយក្នុងនាមជាសាក្សីទេ។ សាក្សីធម្មតាមិនអាចផ្ដល់ហេតុផលសន្និដ្ឋានបែបនេះនោះឡើយ។ សំណួរដែលបានសួរទៅកាន់សាក្សីរូបនេះ គឺបានរៀបចំឡើងដើម្បីសួរ ដើម្បីទាញយកចម្លើយក្នុងនាមជាអ្នកជំនាញ។ ដូច្នេះគឺសំណួរនេះផ្ដល់លទ្ធភាពឲ្យសាក្សីនេះក្នុងកម្រិតមួយរិតត្បិតឲ្យសាក្សីធ្វើការទាញសន្និដ្ឋាន។ ជាពិសេសទៅលើការប្រើវិធីសាស្ត្ររបស់ខ្មែរក្រហមវាយប្រយុទ្ធទៅលើទ័ពរដ្ឋាភិបាល លន់ នល់។

**លោក អាប់ឌុលឡាក់ ថារីក៖**

ការជំទាស់នេះ គឺថាមិនមែនមានមូលដ្ឋានទេ វានាំឲ្យមានការពន្យារពេលវេលាទៅកាន់ការតាំងសំណួររបស់យើងខ្ញុំនោះទេ។ ប្រសិនបើមានការឆ្លើយតបដូច្នេះ គឺខ្ញុំក៏អត់មានសិទ្ធិឆ្លើយតបទៅវិញដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៣:៥៦]

**ប្រធានអង្គជំនុំ៖**

សូមជម្រាប និងរំឭកឡើងវិញថា អង្គជំនុំជម្រះបានកំណត់ច្បាស់លាស់អំពីឋានៈនៅចំពោះមុខខ្លួនថាជាសាក្សី ឬជាអ្នកជំនាញ ឬជាដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើគាត់ជាឋានៈជាសាក្សី ការតាំងសំណួរទាំងឡាយ កម្រិតត្រឹមតែជាសាក្សីបានហើយ។ ក្នុងនាមជាសាក្សីមិនអាចតាំងសំណួរឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋានទេ។ នេះយើងអនុវត្តនៅក្នុងតុលាការនេះតាំងពីដើមរហូតដល់ពេលនេះ។

វាចម្លែកណាស់ដែលតំណាងសហព្រះរាជអាជ្ញាលើកបែបនេះនៅពេលនេះ។ កន្លងមកមានការជំទាស់ជាច្រើន ហើយអង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់ជាច្រើនលើសំណួរទាំងឡាយដែលឲ្យគោលដៅ នៃការឆ្លើយក្នុងនាមជាសាក្សីធ្វើសេចក្ដីសន្និដ្ឋាន។ យើងបានប្រាប់ទៅជម្រាបអំពីករណីយកិច្ចរបស់ក្នុងនាមជាសាក្សី ដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះយ៉ាងច្បាស់លាស់ ហើយព្រឹកមិញក៏យើងបានជម្រាបដែរ។

[០៩:៥៥:០០]

លោក ស៊ីដនី ស្កេនបឺក លោកអាចក្នុងនាមជាសាក្សីសូមរំឭកម្តងទៀត។ លោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលសួរដោយចៅក្រម ឬដោយភាគីនៃរឿងក្តី។

បន្តទៀត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ចំពោះការណែនាំ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ស្កេនបឺក នៅពេលនេះ ខ្ញុំសូមបន្តចូលសួរអំពីហេតុការណ៍ថ្ងៃទី១៧ ខែមេសាវិញម្តង។ ប្រសិនបើខ្ញុំសូមចាប់ផ្តើមដំបូងនោះ នៅក្នុងការរៀបរាប់របស់លោក ជាពិសេសនៅលើទាហានដែលលោកបានឃើញ។ នៅក្នុងសំណុំរឿង យើងមានអត្ថបទមួយដែលបានចេញផ្សាយនៅក្នុងកាសែតឈីកាហ្គោទ្រីប្យូន អត្ថបទនេះ ប្រហែលជាការផ្សាយឡើងវិញទៅតាមកាសែតញូវយ៉កថែមស៍។ ខ្ញុំនឹងអានដើម្បីឲ្យលោកបញ្ជាក់ថាតើលោកសង្កេតឃើញដូច្នេះ ឬក៏យ៉ាងណា?

[១៩:៥៦:២៧]

ឯកសារ E3/368 គឺអត្ថបទចុះខែឧសភា ឆ្នាំ១៩៧៩ គឺនិយាយអំពីការរស់រានមានជីវិត។ អត្ថបទនេះគឺគួរឲ្យចាប់អារម្មណ៍។ គឺមានសរសេរដូចតទៅ "មន្ត្រីអាមេរិកបានរៀបរាប់ជនកុម្មុយនីស្តថាជាអ្នកស្មោះស្ម័គ្រ ក៏ប៉ុន្តែពួកគេមានភាពប្តេជ្ញា និងរឹងប៉ឹង ហើយមានវិន័យត្រឹមត្រូវណាស់"។ ទៅកថាខណ្ឌមួយនេះក្រោមនេះបន្តិចគឺអត្ថបទមានសរសេរដូចតទៅ "ទាហានដែលយើងឃើញនៅតាមជនបទនិងទីក្រុងភ្នំពេញ គឺមានទាំងនារី និងយុទ្ធជន។ អ្នកខ្លះនោះ គឺអាយុជាង១០ឆ្នាំតែប៉ុណ្ណោះ។ អ្នកទាំងអស់នោះមានសុខភាពល្អ ហើយមានរបៀបរៀបរយ មានអាវុធពពាក់ពពូន"។ តើខ្ញុំសូមសួរលោក ការសង្កេតរបស់លោកគឺដូច្នេះដែរឬទេ ចំពោះទាហានខ្មែរក្រហមនាពេលនោះ?

**លោក ស៊ីដនី ស្កេនបឺក៖**

**ឆ៖** ខ្ញុំសន្និដ្ឋានចំណុចនេះគឺដោយសារតែខ្ញុំចូលរួមពពាក់ពពូនជាមួយនឹងអ្នកទាំងអស់នេះ នៅពេលដែលខ្ញុំដើរចេញពីប្រទេសកម្ពុជា បានន័យថាធ្វើដំណើរចេញពីប្រទេសកម្ពុជានៅក្នុងក្បួនរថយន្ត។

ពេលនោះ គឺថាគេបានឃាត់ខ្ញុំម្តងដែរ ក្រុមរបស់យើងខ្ញុំ ហើយគេមានម្ហូបអាហារ គេឲ្យយើងដើរទៅលាងមុខនៅតាមទន្លេផងដែរ នៅពេលដែលគេបញ្ឈប់យើង។ បានន័យថាយើងខ្ញុំនេះបានឃើញរូបភាពច្រើន។ ដូច្នេះរូបភាពទាំងអស់នោះ គឺបង្ហាញឲ្យខ្ញុំឃើញច្បាស់ ហើយពាក្យទាំងអស់នេះគឺខ្ញុំជាអ្នកនិយាយតាមអ្វីដែលខ្ញុំបានឃើញ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់ម្ភៃនាទី អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ស្តេនប៊ឺក ឥឡូវនេះអង្គជំនុំជម្រះសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។ ហើយម៉ោងនៅទីនោះមិនដឹងទេ ប៉ុន្តែនៅទីនេះគឺម៉ោងរហូតដល់ម៉ោងដប់និងម្ភៃនាទី ចាប់ផ្តើមបន្តណ៎ា។ សូមលោកជ្រាប។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:៥៩នាទី ដល់ម៉ោង ១០:២២ នាទី)*

[១០:២២:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីដនី ស្តេនប៊ឺក អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើសុំការពន្យារពេលបន្ថែមកន្លះថ្ងៃទៀតក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

ដូច្នេះពេលវេលាហ្នឹង គឺបែងចែកតំណាងសហព្រះរាជអាជ្ញារួមនឹងសហមេធាវីនាំមុខបីវគ្គសវនាការគឺនៅវគ្គទី២នៃព្រឹកនេះ ហើយនិងមួយវគ្គព្រឹកថ្ងៃស្អែកទៀត ហើយនៅសេសសល់ ពេល

សេសសល់គឺ បីវគ្គចុងក្រោយគឺសម្រាប់ក្រុមមេធាវីការពារក្តី។ សូមភាគីជ្រាប!

អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីដនី ស្កេនប៊ឺក។ សូមអញ្ជើញ!

[១០:២៣:៤១]

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រេកអរណាស់ដែលអង្គជំនុំជម្រះផ្តល់ពេលវេលាបន្ថែមមកជូនខាងយើងខ្ញុំ។

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** លោក ស្កេនប៊ឺក ខ្ញុំជឿថាលោកអាចស្តាប់យើងខ្ញុំបាន ព្រោះស្តាប់សំឡេងលោកកំពុងតែនិយាយបាន។ ខ្ញុំសូមបន្តទៅលើប្រធានបទដែលយើងបាននិយាយគ្នាអំពីវិន័យរបស់កងទ័ពខ្មែរក្រហមបាទនេះបើតាមការកត់សម្គាល់ឃើញរបស់លោក។ នៅក្នុងសំណុំរឿងយើងមានអត្ថបទថតចម្លងនៃសារព័ត៌មានរបស់សហរដ្ឋអាមេរិក ដែលលោកយកមកសរសេរនៅក្នុងអត្ថបទរបស់លោកនៅខែកញ្ញា ៧៥ គឺឯកសារ E3/355 ជាសេចក្តីសង្ខេបចុះថ្ងៃទី១៨ កញ្ញា ៧៥។ ខ្ញុំសូមផ្តល់ ERN ជូនដូចតទៅ៖ ជាភាសាខ្មែរគឺ 00740897 ហើយទំព័រគឺដូចខាងក្រោមហ្នឹង ជាភាសាបារាំងគឺ 00751938, អង់គ្លេស 0043800*(ស៊ីក)* គឺក្រសួងការបរទេសសហរដ្ឋអាមេរិកដែលបាន លោកបានយកមកសរសេរក្នុងអត្ថបទរបស់លោកនៅថ្ងៃទី១៨ កញ្ញា ៧៥។ បាទ គឺសេចក្តីសង្ខេបសារព័ត៌មានដូចខាងក្រោមនេះ៖

សូមដកស្រង់ "ទាហានខ្មែរក្រហមជាកសិ -- កុមារៗកសិករ ហើយប៉ុន្តែអ្នកដឹកនាំគឺថាអាចជាអ្នកអប់រំដែលមានចេះភាសាបារាំងបាន"។ គឺឯកសារនេះ ខ្ញុំបានផ្ញើជូនទៅលោកហើយ លោក ស្កេនប៊ឺក។ តាមការកត់សម្គាល់របស់លោកទាក់ទងទៅនឹងមន្ត្រីខ្មែរក្រហមដែលថា មានការអប់រំ រៀនសូត្រអប់រំច្រើន ហើយអាចចេះនិយាយភាសាបារាំងបានទៀតផង។

[១០:២៦:៣២]

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំឮសួរពួកគេនិយាយភាសាបារាំងនៅពេលគេចូលមកស្ថានទូត។

**ស៖** តើមានលក្ខណៈណាទៀតទេ ពាក់ព័ន្ធទៅនឹងឥរិយាបថ ឯកសណ្ឋាន អាកប្បកិរិយា ដែលនាំឲ្យលោកយល់ឃើញថា ពួកគេគឺជាអ្នកដែលមានការរៀនសូត្របានខ្ពង់ខ្ពស់នោះ?

**ឆ៖** ខ្ញុំមិនមានការទាក់ទងច្រើនអីជាមួយពួកគេទេ ប៉ុន្តែអ្វីដែលខ្ញុំបានទាក់ទងជាមួយពួកគេនោះ គឺធ្វើឲ្យខ្ញុំគិតឃើញថា ពួកគេមានការបណ្តុះបណ្តាលឲ្យក្លាយទៅជាមន្ត្រីយោធា គឺថាបានល្អ ហើយឯកងទ័ពវិញនោះ គឺថាមិនដូចគ្នាទេ ក៏ទ័ពធម្មតាៗនោះ។

**ស៖** បាទ សូមអរគុណ។ ត្រង់ចំណុចនេះដដែល យើងខ្ញុំមិនមានពេលច្រើនពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលលោកបានលើកឡើងនេះទេ ប៉ុន្តែសូមឲ្យលោកនិយាយសង្ខេបបានហើយ។ ហើយអង្គជំនុំជម្រះបានឮពីព្រឹត្តិការណ៍នេះពីលោកសាក្សី រ៉ូកូហ្វ ហើយ។ ចំណុចមួយដែលខ្ញុំចង់ស្វែងយល់បន្ថែមជាមួយនឹងលោកនោះ នៅពេលដែលលោកនៅឯមាត់ទន្លេ ហើយគេឃាត់លោកនៅទីហ្នឹងអស់មួយរយៈពេល។ តើលោកមានបានកត់សម្គាល់ឃើញពីឥរិយាបថរបស់មន្ត្រីយោធាទាំងនោះទេ ឬក៏យោធាណាមួយទេ?

[១០:២៨:៣០]

**ឆ៖** បាទ មន្ត្រីយោធានោះ គឺថាគេកំពុងតែបាយថ្ងៃត្រង់ ហើយគឺជំនួយការរបស់ខ្ញុំ ហើយនិងប្អូនប្រុសរបស់គាត់បានចូលទៅកាន់មន្ត្រីកងទ័ពហ្នឹង ហើយបានឧទ្ទេសនាមប្រាប់គេថា យើងជាជនជាតិកាណាដា ហើយយើងមកទីនេះ គឺដើម្បីកត់ត្រានៅជ័យជម្នះរបស់ពួកគេ។ ហើយបន្ទាប់មកគាត់ចាប់ផ្តើមនិយាយអីភាសាខ្មែរជាមួយពួកគេ ហើយគាត់ក៏និយាយជាមួយនឹងកងទ័ពខ្មែរក្រហមថា ឧត្តមសេនីយ៍មួយរបស់លោក គឺនិយាយថា “សារព័ត៌មានអាចធ្វើការជាមួយយើងបាន”។ ដូច្នេះមន្ត្រីកងទ័ពដែលហូបបាយថ្ងៃត្រង់គឺថាបានអនុញ្ញាតឲ្យយើងបង្កប់ដោយការបញ្ចុះបញ្ចូល ហើយអនុញ្ញាតសុំឲ្យខ្ញុំចូលទៅក្នុងអគារមួយផ្សេងទៀត ដែលជាទីបញ្ជាការបណ្តោះអាសន្នរបស់លោកនៅពេលនោះ។

ខ្ញុំសូមទៅជាមួយនឹងមន្ត្រីយោធារបស់លោក ហើយដើម្បីសួរសំណួរផ្សេងៗ ទោះបីជាគេប្រព្រឹត្តមកលើអ្នកយកព័ត៌មានយ៉ាងណាក៏ដោយ គេឆ្លើយថាបាន ដូច្នេះគេមានមន្ត្រីមួយ យើងឡើងជិះម៉ូតូ ជិះពីខាងក្រោយខ្នង ហើយធ្វើដំណើរទៅកាន់អគារនុ៎ង។ គឺរយៈពេលប្រហែលជា២០ ឬក៏៣០នាទីក្រោយមក រ៉ន គាត់វិលមកវិញ ហើយក្រោយមកយើងក៏ត្រូវបានដោះលែង។ យើងខ្ញុំទាំងបីនាក់នេះគឺ រ៉ូកូហ្វ ខ្លួនខ្ញុំ ហើយនិង ចន ស្វេន ថាគឺរឿងហ្នឹងគឺចប់សព្វគ្រប់ហើយ។ ខ្ញុំចង់និយាយថា ប្រន គាត់មានចំណាប់អារម្មណ៍ខ្លាំងណាស់។ ប៉ុន្តែ ប្រន នេះគឺគាត់បានជួយសង្គ្រោះជីវិតរបស់យើង គាត់គឺជាមនុស្សល្អណាស់ គាត់ស្លាប់ប៉ុន្មានឆ្នាំក្រោយមក។

គាត់ជឿជាក់សន្តិភាព នៅក្នុងរបបខ្មែរក្រហមគាត់ឈឺចាប់ខ្លាំងមែនទែន--

[១០:៣១:១៦]

**ស៖** ខ្ញុំសូមទោសដែលកាត់ផ្តាច់លោក ខ្ញុំដឹងថាវាសំខាន់ណាស់។

**ឆ៖** ខ្ញុំហាក់ងាកចេញបន្តិច ប៉ុន្តែក្នុងក៏បន្តិចគឺថាគាត់ អ្វីដែលជាមនុស្សដែលល្អ ខ្ញុំចងចាំក្នុងជីវិតរបស់ខ្ញុំ។ ហើយគេដោះលែងយើង ហើយអនុញ្ញាតឲ្យយើងចាកចេញ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរឲ្យបានស៊ីជម្រៅបន្តិច យើងមិនមានពេលវេលាច្រើនទេ មានចំណុចមួយចំនួនដែលយើងមានចំណាប់អារម្មណ៍មែនទែន នៅក្នុងកំណត់ត្រាប្រចាំថ្ងៃរបស់លោករៀបរាប់នៅត្រង់ទំព័រ៦៨។ មានចំណុចមួយនៅក្នុងដំណើររឿងនេះ នៅទំព័រ៦៨, ERN អង់គ្លេស 00898276 ដែលត្រង់នេះលោកសរសេររៀបរាប់អំពីការសន្ទនារវាង ឌិត ប្រន ហើយនិងកងទ័ពដែលចាប់លោកនោះ។ សូមដកស្រង់ "ពួកកងទ័ពបះបោរឲ្យយើងចាកចេញ យើងមិនចង់បានពួកអ្នកឯងមកទេ។ ប្រន ដឹងថាយើងអាចនឹងបាត់បង់ជីវិត បើមិនមានរូបគាត់នោះទេ។ វាជាការនិយាយអំពី យើងនិយាយពីភាពស្មោះត្រង់ ហើយគាត់អាចជួយសង្គ្រោះជីវិតយើងបាន។ នៅក្នុងពាក្យទាំងនេះគឺយើងមិនចង់បានអ្នកឯងទេ ចង់បានតែអ្នកធំម្នាក់ទេ"។

តើ ថាតើលោកឮពាក្យ ពាក្យហ្នឹងឮតាមពី ឌិត ប្រន ឬក៏ឮផ្ទាល់មាត់?

[១០:៣៣:១៤]

**ឆ៖** បាទ ឌិត ប្រន គាត់និយាយប្រាប់ខ្ញុំ នៅពេលហ្នឹងគាត់ប្រាប់ខ្ញុំពាក្យខ្មែរអំពីអ្នកធំ ខ្ញុំមិនចាំទេនៅពេលហ្នឹង។ ខ្ញុំមើលទៅ ប្រនៗ នៅជំទាស់តវ៉ា ជជែកតវ៉ាជាមួយពួកគេ ពួកគេជាកងទ័ពដែលមានអាវុធនៅពេលបើកបរហ្នឹង។ ដោយសារគេភ្ជង់អាវុធមកដាក់ភ្ជង់ក្បាលយើងតែម្តង។ ខ្ញុំគិតថា អ្ហូ! ខ្ញុំក៏គិតឃើញថា យី! ឌិត ប្រន គាត់នៅជជែកតវ៉ាអីទៀត បើមិនអ៊ីចឹងទេគេនឹងសម្លាប់យើងហើយ។ ហើយខ្ញុំក៏សួរនៅក្នុងរថយន្តហ្នឹងសួរទៅគាត់ ហេតុអីក៏លោកនៅជជែកតវ៉ាជាមួយពួកគេ? ហើយ ប្រន គាត់ថា "ខ្ញុំដឹង បើថាមិនមានខ្ញុំទេ អ្នកឯងទាំងពីរនាក់ហ្នឹង គេនឹងសម្លាប់អ្នកឯងចោលហើយ"។

**ស៖** បាទ សូមអរគុណ។ តើលោកមានបានសួរទៅគាត់ ថាតើមានចំណុចណាមួយ ដែលអាចពន្យល់ថា *ឌី ប៊ីក វ័ន* ហ្នឹងគឺថាចង់បានអ្នកធំម្នាក់នោះ ចង់មានន័យថាម៉េច?

**ឆ៖** ពាក្យថា "អ្នកធំម្នាក់" ហ្នឹងប្រហែលជាគេគិតឃើញថា ពួកយើងទាំងបីហ្នឹងជាអាមេរិកាំងហើយ។

**ស៖** សូមបន្តទៅចំណុចមួយទៀតនៃព្រឹត្តិការណ៍ដដែលនុ៎ង គឺព្រឹត្តិការណ៍ដែលលោករៀបរាប់ថា ជនជាតិកម្ពុជាពីរនាក់គេរុញចូលទៅក្នុងរថយន្ត។ នៅត្រង់ទំព័រដដែល ហើយលោកបាននិយាយថា "ពួកគេស្លៀកពាក់ឯកសណ្ឋានស៊ីវិលទេ ប៉ុន្តែក្រោយមកគឺថាគេជាកងទ័ពហើយ។ ម្នាក់ក្នុងពីរនាក់ហ្នឹងគឺផាត់ មានពុកមាត់ពាក់អាវឃើត គាត់ព្យាយាមយកកាបូបរបស់គាត់ដាក់ចូលក្នុងហោប៉ៅរបស់ខ្ញុំគាត់និយាយប្រាប់ថា គាត់ជាមន្ត្រីម្នាក់ ហើយគាត់ត្រូវតែលាក់អត្តសញ្ញាណរបស់គាត់"។

ដោយសារតែជាការរៀបរាប់នូវព្រឹត្តិការណ៍ដដែល យើងសូមចូលទៅមើលទំព័រ៦៤នៃសៀវភៅស្តីពីវាលពិឃាតនោះ។ ERN អង់គ្លេស 00862598 បាទ ត្រង់ទំព័រ៦៤, លោក ស្តេនប៊ីក -- បាទ សូមកែតម្រូវមិនមែនទំព័រ៦៤ ទេទំព័រ៦២។ លោកនិយាយដូចតទៅ៖ "គេឈប់ ក្រោយមកយកមនុស្សពីរនាក់គឺស្លៀកពាក់ឯកសណ្ឋានស៊ីវិលគឺថា គឺជាមេបញ្ជាការកងទ័ពជើងទឹកម្នាក់។ ខ្មែរក្រហមដឹងថាអ្នកពីរនាក់ហ្នឹងជាអ្នកណា ហើយខ្ញុំនិយាយថា អ្នកទាំងពីរហ្នឹងនឹងត្រូវគេសម្លាប់ចោលហើយ"។ ខ្ញុំសូមសួរទៅលោក ថាតើនេះគឺជាដំណើររឿងរ៉ាវត្រឹមត្រូវមែនទេ តាមការដឹងរបស់លោកគឺថាម្នាក់ក្នុងចំណោមពីរនាក់ហ្នឹងអាចជាអនុបញ្ជាការកងទ័ពជើងទឹកនៃ--?

[១០:៣៧:០១]

**ឆ៖** ខ្ញុំមិនដឹងភ្លាមទេពេលនោះ ខ្ញុំដឹងក្រោយពេលដែលគេដោះលែងខ្ញុំហើយដែលបុរសទាំងពីរនាក់នោះត្រូវគេឃាមកាម។ ពួកគេទាំងពីរអត់ត្រូវបានដោះលែងទេ។ ខ្ញុំមិនចាំរឿងរ៉ាវទាំងស្រុងទេ។ គាត់ព្យាយាមឲ្យកាបូបគាត់មកខ្ញុំ កាបូបដាក់លុយគាត់មកឲ្យខ្ញុំ។ ដោយសារតែយើងស្ថិតក្នុងស្ថានភាពដូចគ្នា ការដែលឲ្យកាបូបដែហ្នឹងមកឲ្យ កាបូបដាក់ប្រាក់មកឲ្យខ្ញុំគឺថាអាចនឹងជួយគាត់បាន។ ហើយស្តេនប៊ីក គាត់នៅលើ ជាន់មួយជាមួយពួកគេហ្នឹង។ នៅពេលដែលគេដោះលែងពួកយើងខ្ញុំនេះ ពួកគេអង្គុយនៅលើចិញ្ចើមផ្លូវដែលមានកងទ័ពឃាមកាមពួកគេ។ យើងទាំងអស់ពេលហ្នឹងបានដឹងថា យើងមិនអាចជួយស្អីដល់ពួកគេពីរនាក់ហ្នឹងបានទេ។ ដូច្នេះយើងក៏ដើរចេញមក។ នេះគឺជាអ្វីៗដែលវាកើតឡើងនៅក្នុងពេលសង្គ្រាម ហើយខ្ញុំមិនអាចភ្លេចរឿងហ្នឹងបានទេ។ ប៉ុន្តែខ្ញុំមិនអាចជួយអ្វីពួកគេបានទេ ហើយយើងក៏ចាកចេញមក។ ខ្ញុំមិនដឹងឆ្លើយជាមួយសំណួរលោកយ៉ាងម៉េចលើសពីហ្នឹងទៀតទេ ប៉ុន្តែវាជាថ្ងៃមួយដែលគួរឲ្យឈឺចាប់។

[១០:៣៨:៤១]

**ស៖** លោក ស្តេនប៊ីក តើលោកនៅចាំដោយហេតុការណ៍ណាមួយឈ្មោះអនុមេបញ្ជាការកង

ទ័ពជើងទឹកទេ? តើមានអ្វីកើតឡើងដល់រូបគាត់ទេ ក្រោយមកលោកដឹងទេ?

**ឆ៖** ខ្ញុំអត់បានទទួលដំណឹងអីពីគាត់នោះទេ ខ្ញុំអ្វីដែលខ្ញុំដឹងអាចគ្រាន់តែស្មានបានតែប៉ុណ្ណោះ។

**ស៖** យើងខ្ញុំសូមបញ្ឈប់លោកត្រឹមចំណុចនេះចុះ ដើម្បីឱ្យខ្ញុំអាចបន្តចូលទៅព្រឹត្តិការណ៍កើតឡើងក្រោយពេលគេដោះលែងលោក។ តែមុនចូលទៅដល់ការទំនាក់ទំនងគ្នារបស់លោកជាមួយពួកគេនេះ មានសារមានអត្ថបទ ចំណុចមួយនៅក្នុងសៀវភៅរបស់លោកដែលលោករៀបរាប់ លន់ ណុន ដែល លន់ ណុន គឺថាព្យាយាមគេចខ្លួនចេញពីទីក្រុងភ្នំពេញ។ ខ្ញុំនឹងសួរសំណួរបន្តបន្ទាប់នៅត្រង់ទំព័រ២២ នៃកំណត់ត្រាប្រចាំថ្ងៃរបស់លោក ERN 00898230 បាទទំព័រ២២នៃកំណត់ត្រាប្រចាំថ្ងៃរបស់លោកជាសារខ្លីទេដែលលោកនិយាយដូចតទៅ ចុះថ្ងៃទី០៥ ខែមីនា។

[១០:៤០:២៦]

សូមដកស្រង់ "ពាក្យចចាមអារ៉ាមលេចឮឡើងថា លន់ នល់ នឹងភៀសខ្លួន និងស្រូតចាកចេញពីប្រទេស ដើម្បីដោយសារថាគាត់គឺថាអាចនឹងត្រូវសម្លាប់ដោយពួកបះបោរនេះ"។ ខ្ញុំសូមសួរដំបូងទៅលោក ថាតើលោកបានដឹងអ្វីអំពីពួកមហាក្បត់ទាំងប្រាំពីរ ដែលគេត្រូវបណ្ដើរយកទៅសម្លាប់ចោល?

**ឆ៖** ខ្មែរក្រហមគឺបានចេញសេចក្ដីថ្លែងការណ៍មួយ គេហៅអ្នកទាំងនោះថា "ពួកមហាក្បត់ទាំងប្រាំពីរ" ដែលត្រូវតែសម្លាប់ចោល ហើយគេនិយាយថ្លែងហើយថ្លែងទៀត។ អ្នកទាំងអស់ហ្នឹងមិនត្រូវបានសម្លាប់ទាំងអស់ទេ ពីព្រោះថា លន់ នល់ បានចាកចេញពីប្រទេសជាមួយគ្រួសាររបស់គាត់ដោយយកលុយទៅរាប់លានដុល្លារ ដែលគេបានរកឃើញប៉ុន្មានឆ្នាំក្រោយមកទៀត។ បាទ នេះគឺអ្វីដែលខ្ញុំដឹង។

**ស៖** ខ្ញុំសូមអានជូនលោកនិយាយអំពីសេចក្ដីប្រកាសព័ត៌មាន ថាតើវាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោករៀបរាប់នេះទេ? នេះគឺឯកសារ E3/117 ជាប្រតិចារឹកនៃការផ្សាយសំឡេងរបស់វិទ្យុល្បួចលាក់របស់ចលនាតស៊ូ ដែលចុះថ្ងៃទី២០ ខែកុម្ភៈ ៧៥ -- ចុះថ្ងៃទី២៦ កុម្ភៈ ៧៥។ ខ្ញុំសូមផ្ដល់ ERN មុនសិន ហើយក្រោយមកសឹមអានអំពីសម្រង់នេះ ERN ខ្មែរ 00242308, បារាំង 00281432, អង់គ្លេស 00166772។

[១០:៤៣:០៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់កំព្យូទ័រជាភាសាខ្មែរ

ដើម្បីឲ្យសាធារណជនបានជ្រាប។ លោក ស្កេនប៊ឹក ខ្ញុំអានជូនលោកស្តាប់បាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមឲ្យបុគ្គលិកខាង អេ.វី មេត្តាជួយដល់យើងខ្ញុំ។ ចំណងជើងនៃអត្ថបទនោះគឺថា "ខៀវ សំផន បានធ្វើជាអធិបតីនៅក្នុងសមាជកងទ័ព (ផ្សាយតាមវិទ្យុលួចលាក់របស់ចលនា ស. ស៊ី) នៅម៉ោងដប់មួយ -- ជី -- ១៣ ជី.អឹម.ធី ថ្ងៃទី២៦ កុម្ភៈ ៧៥"។

[១០:៤៤:០៣]

បាទ ខ្ញុំសូមដកស្រង់ត្រង់ទំព័រដដែល "ទី១ នៅថ្ងៃទី២៤, ២៥ កុម្ភៈ ៧៥ សមាជជាតិមហាអស្ចារ្យត្រូវបានប្រារព្ធលើកទី២ របស់ខ្លួនក្នុងតំបន់រំដោះ ក្រោមអធិបតីភាពរបស់ ខៀវ សំផន ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជារដ្ឋមន្ត្រីការពារជាតិ និងនាយសេនាធិការនៃកងកម្លាំងប្រដាប់អាវុធរំដោះជាតិ និងប្រជាជនកម្ពុជា"។

ហើយខាងក្រោមមកទៀត នៅត្រង់កថាខណ្ឌមួយ សូមដកស្រង់ "ពាក់ព័ន្ធទៅនឹងពួកក្បត់ទាំងប្រាំពីរ សមាជជាតិបានសម្រេចដូចខាងក្រោម៖ ពួកក្បត់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វៃណង់ដែស គឺជាប្រមុខពួកក្បត់ និងជាប្រធានក្រុមធ្វើរដ្ឋប្រហារប្រឆាំងជាតិដ៏ទុរយស ដែលបានផ្តួលរំលំឯករាជ្យ សន្តិភាព អព្យាក្រឹតរបស់កម្ពុជា"។

[១០:៤៥:០៧]

ហើយខាងក្រោមមកទៀត "ក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានិងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិប្រកាសថាវាជាការចាំបាច់ដែលត្រូវសម្លាប់ពួកមហាក្បត់ទាំងប្រាំពីរនេះ ដោយសារតែក្បត់ជាតិ ក្បត់ប្រជាជន ហើយដោយសារតែអំពើពុករលួយ ដែលពួកគេបានធ្វើ មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា"។

សូមឲ្យលោករៀបរាប់ចំពោះពួកក្បត់ទាំងប្រាំពីរនេះបន្តិចមក ដូចដែលលោករៀបរាប់មុនបន្តិចនេះហើយ។

**ឆ៖** បាទហ្នឹងហើយ។

**ស៖** ហើយថាតើការផ្សព្វផ្សាយនេះវាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកឮនៅពេលនោះទេ?

**ឆ៖** ខ្ញុំផ្ទាល់ខ្ញុំមិនដែលឮការសេចក្ដីថ្លែងដោយផ្ទាល់ ប៉ុន្ដែបានយើងឃើញរបាយការណ៍ ឬសេចក្ដីរាយការណ៍នៅពេលនោះថាអ៊ីចឹង។

**សៈ** តើសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងពួកមហាក្បត់ទាំងប្រាំពីរនេះ គឺអ្វីដែលលោកបានដឹងប៉ុន្មានសប្ដាហ៍ ឬប៉ុន្មានអាទិត្យមុនមកដល់១៧ មេសា ៧៥ ឬយ៉ាងម៉េច?

[១០:៤៦:២៧]

**ឆ៖** បាទ អ៊ីចឹងហើយ មានការនិយាយច្រើនណាស់អំពីអ្នកពួកក្បត់ទាំងនេះ។

**សៈ** សូមអរគុណ។ ដូចដែលខ្ញុំបានជម្រាបជូនហើយថាយើងនឹង យើងខ្ញុំនឹងលើកឡើងអំពីព្រឹត្តិការណ៍ដែលកើតឡើងក្រោយពីគេចាប់ខ្លួនលោក។ ជាពិសេសការប្រព្រឹត្តិដោយពួកខ្មែរក្រហមមកលើទាហានរបបសាធារណរដ្ឋខ្មែរ។

ខ្ញុំសូមចូលទៅទំព័រ៦៦ ទៅ៦៧ នៃកំណត់ត្រាប្រចាំថ្ងៃរបស់លោក ERN 00898274 ដល់25។ មានការផ្សាយសំឡេងដែលលោកបានរៀបរាប់នុ៎ង លោករៀបរាប់ថា "មានការបន្ទច់បង្អាក់ ការផ្សាយនេះ" ហើយលោកលើកឡើងថា "ការផ្សាយនេះគឺត្រូវបានមន្ត្រីកងទ័ពនោះគឺថាយើងមកទីនេះ មិនមែនមកចរចាទេ ហើយក្រោយមកវិទ្យុរំដោះហ្នឹងបាននិយាយថា យើងមកភ្នំពេញមិនមែនដើម្បីចរចាទេ គឺមកហ្នឹងដោយគឺថាចុងកាណុងតែម្ដង។ យើងមកចាប់ពួកអាក្បត់ លន់ នល់ ហើយយើងសូមអំពាវនាវឲ្យកងទ័ពរបស់ លន់ នល់ ទាំងអស់ដាក់អាវុធចុះ ហើយបើរឹងទទឹងគឺថានឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ"។

[១០:៤៨:២៣]

ហើយខាងក្រោមនិយាយថា "មានសារមួយទៀត ដែលផ្សាយជាច្រើនដង សូមអញ្ជើញឲ្យរដ្ឋមន្ត្រី ឧត្ដមសេនីយ៍ទាំងអស់ដែលមិនបានរត់ចេញខ្លួន សូមឲ្យមកចូលជួបជាមួយពួកយើងភ្លាមៗនៅក្រសួងព័ត៌មាន ដើម្បីមករៀបចំចាត់ចែងនូវវិធានការណាមួយ ដើម្បីរក្សាសណ្ដាប់ធ្នាប់ឡើងវិញ"។ បញ្ចប់ការដកស្រង់។ ខ្ញុំសូមសួរទៅលោក ថាតើការផ្សាយនេះ ការផ្សាយវាពាក់ព័ន្ធទៅនឹងរដ្ឋមន្ត្រីនិងឧត្ដមសេនីយ៍ទាំងអស់ដែលត្រូវអញ្ជើញឲ្យមកក្រសួងព័ត៌មាន តើលោកបានឮដោយផ្ទាល់ ឬក៏លោកឮពីគេដែរ?

**ឆ៖** បាទ ខ្ញុំទទួលព័ត៌មាននេះពីមនុស្សម្នាក់ ដែលខ្ញុំជួលកាលហ្នឹង ជួលឲ្យតាមស្ដាប់ការផ្សាយវិទ្យុហ្នឹង នៅពេលណា នៅពេលដែលខ្ញុំចេញទៅតាមដងផ្លូវនានា។ នៅពេលដែលខ្មែរក្រហមមកចូល

កាន់កាប់ទីក្រុងភ្នំពេញហ្នឹង គាត់ជាគ្រូបង្រៀននៅសាកលវិទ្យាល័យ គាត់ដកស្រង់សេចក្តីថ្លែងការណ៍ហ្នឹងដោយផ្ទាល់។ បាទ ជាចំណុចមួយដែលគាត់បានកត់ត្រាជាចុងក្រោយហើយ ព្រោះគាត់មកសណ្ឋាគារ។ នៅពេលដែលយើងទៅដល់សណ្ឋាគារ គឺយើងបានដឹងចំណុចហ្នឹង។ ហើយគាត់មានក្រុមគ្រួសាររបស់គាត់នៅជិះនៅក្នុងរថយន្ត ហើយគាត់ក៏បានកត់ត្រាហើយ គាត់កាន់កំណត់ត្រានៅក្នុងដៃរបស់គាត់ ហើយគាត់បើកឡានចេញទៅ ប៉ុន្តែគាត់ហុចសារហ្នឹងតាមទ្វាររថយន្តមកឲ្យយើងខ្ញុំ។

[១០:៥០:២៤]

**ស៖** ឥឡូវនេះខ្ញុំសូមបន្តចូលទៅដល់ការរៀបរាប់ដំណើររឿងដោយលោក ដែលលោកបានឃើញនៅក្រសួងព័ត៌មាននោះ។ នៅត្រង់ទំព័រ៦៩ និងទំព័រ៧០ នៃកំណត់ត្រាប្រចាំថ្ងៃរបស់លោក ហើយនិងបន្តទៅដល់ទំព័រ៧១ផងដែរ។ ERN ជាភាសាអង់គ្លេស 00898277 នៅពីរទំព័រខាងក្រោម និងពីទំព័របន្តបន្ទាប់មកទៀត។

លោកបានសរសេរដូចតទៅ នៅត្រង់ទំព័រ៦៩ សូមដកស្រង់៖ "យើងមានព័ត៌មានពីក្រសួងការបរទេសដោយសារមានការស្នើសុំឲ្យមន្ត្រីជាន់ខ្ពស់ទៅរាយការណ៍ឲ្យគេនៅទីនោះ។ នៅពេលយើងទៅដល់គឺថាអ្នកទោស ៥០គឺឈរនៅខាងក្រៅអគារ ហាក់បីដូចជាទីបញ្ជាការបណ្តោះអាសន្នរបស់ពួកបះបោរ នៅក្នុងចំណោមអ្នកទោសទាំងហ្នឹងគឺមានឧត្តមសេនីយ៍ទោ លន់ ណុន ប្អូនប្រុសរបស់សេនាប្រមុខ លន់ នល់, ឧត្តមសេនីយ៍ទោ ឈឹម ឈួន ដែលជិតដិតទៅនឹងសេនាប្រមុខនេះ ហើយនិងមានឧត្តមសេនីយ៍ក៏រួមទាំងសមាជិកគណៈរដ្ឋមន្ត្រីមួយចំនួនទៀតផងដែរ"។

[១០:៥២:០០]

បាទ ខ្ញុំសូមសួរលោកដំបូង ថាតើ ខ្ញុំសូមសួរផ្សេងពីនេះទៅវិញ។ តើលោកអាចស្គាល់ទេដោយផ្ទាល់លោកស្គាល់ឧត្តមសេនីយ៍ណាខ្លះ ក្នុងចំណោមឧត្តមសេនីយ៍ទាំងអស់ ក៏និងសមាជិកគណៈរដ្ឋមន្ត្រីណាមួយនៃរបបសាធារណរដ្ឋខ្មែរទេ?

**ឆ៖** គឺមានតែមួយចំនួនតូចទេដែលខ្ញុំធ្លាប់និយាយជាមួយ ប៉ុន្តែច្បាស់ហើយដែលថាពួកគេទាំងអស់មានការភ័យខ្លាចយ៉ាងខ្លាំង ដែលថាគេនឹងត្រូវយកទៅសម្លាប់ចោលហើយ។ ហើយក៏មានស្ត្រីខ្លះផងដែរ គឺស្ត្រីហ្នឹងធ្វើការនៅក្នុងកាកបាទក្រហមកម្ពុជា។ ខ្ញុំមិនដឹងថាអ្នកណាត្រូវគេសម្លាប់ អ្នកណាមិនត្រូវគេសម្លាប់ទេ អ្នកណាខ្លះដែលត្រូវគេសម្លាប់ទេ តែខ្ញុំដឹងថា លន់ ណន់ នោះគឺពួកគេបានប្រកាសថា គេបានសម្លាប់ ហើយ ឡុង បូរ៉េត នោះដែលជានាយករដ្ឋមន្ត្រីគាត់បានមកដល់ទីនុំង អ្នកខ្លះថាគាត់

បានចាកចេញពីប្រទេស ប៉ុន្តែគាត់មិនអាចចាកចេញបាន គាត់ក៏ត្រូវខ្មែរក្រហមសម្លាប់ដែរ។ បាទខ្ញុំបាននិយាយជាមួយគេនៅត្រង់អគារហ្នឹងតែម្តង។

[១០:៥៣:៣៨]

**ស៖** យើងនឹងចូលមកដល់ការសន្ទនារបស់លោកនៅបន្តិចទៀតនេះ។ បាទ លោករៀបរាប់អំពីព្រឹត្តិការណ៍ត្រង់នោះដែរ ហើយលោកក៏មានសរសេរនៅក្នុងកំណត់ត្រាប្រចាំថ្ងៃរបស់លោក ខ្ញុំនឹងលើកឡើង។ នៅទំព័រ១៧, លោក ស្កេនប៊ឺក, សូមដកស្រង់ "ប៉ុន្មាននាទីក្រោយមកបុរសម្នាក់គឺថាបានឲ្យអ្នកទោសឈរជាបីជួរ មានមន្ត្រីកងទ័ព មន្ត្រីស៊ីវិល ហើយអ្នកសារព័ត៌មាននោះក៏ត្រូវតែឈរមួយជួរផ្សេងផងដែរ។ ហើយមន្ត្រីម្នាក់ប្រហែលជាឧត្តមសេនីយ៍ដែលដឹកមុខគេ គាត់ស្លៀកពាក់ឯកសណ្ឋាន ប៉ុន្តែមិនមានអត្តសញ្ញាណទេ គាត់បដិសេធមិនផ្តល់ឈ្មោះទេ ហើយបាននិយាយទៅកាន់អ្នកទោសទាំងអស់ហ្នឹង។ គាត់និយាយថា គឺមានតែពួកក្បត់ប្រាំពីរនាក់ទេ ប៉ុន្តែអ្នកទាំងនោះត្រូវដោះស្រាយទៅតាមក្រោយ។ ហើយក្រោយមកលោកក៏បាននិយាយទៅមេដឹកនាំកងទ័ពហ្នឹង យោងតាមកំណត់ត្រារបស់លោក។ ខ្ញុំសូមសួរទៅលោកថា តើទាហានប៉ុន្មាន -- កងទ័ពប៉ុន្មាននាក់ដែលបានយាមឡោមព័ទ្ធទៅនឹងអ្នកទោសទាំងអស់នេះ?

[១០:៥៥:២៨]

**ឆ៖** ប្រហែលជាមានកងទ័ព ១០ ទៅ ១៥នាក់ ពួកគេគឺថានៅដើរព័ទ្ធជុំវិញក្រុមអ្នកទោសហ្នឹងដើរព័ទ្ធជុំវិញនុ៎ង។

**ស៖** សូមអរគុណ។ ដើម្បីកុំឲ្យមានការមន្ទិលសង្ស័យ តើកងទ័ពខ្មែរក្រហមហ្នឹង ឬមេបញ្ជាការកងទ័ព -- ជាកងទ័ពធម្មតា ឬមេបញ្ជាការបាទ?

**ឆ៖** *(គ្មានការបកប្រែ)* ។

**ស៖** បាទ សូមអរគុណ។ ហើយក្រោយមកទៀតលោកបានរៀបរាប់ថា មេកងទ័ពហ្នឹងគឺថាបាននិយាយជាមួយនឹងអ្នកកាសែត ហើយលោកសរសេរដូចតទៅ សូមដកស្រង់ "ដោយសារតែមានការសន្ទនាជាបន្តបន្ទាប់ លន់ នល់ គឺថាបានសួរទៅអ្នកនេះទេ ថាតើអ្នកទោសនៅទីហ្នឹង ឬក៏ថាមន្ត្រីដទៃទៀតអាចចាកចេញពីប្រទេសបានទេ បើខ្លួនសូមចាកចេញនេះ។ ក្រោយមកទៀត គឺអ្នកសារព័ត៌មានបានអាចសួរសំណួរហ្នឹងបាន។ មេកងទ័ពហ្នឹងសើចយ៉ាងស្ងួត វាអាស្រ័យទៅលើរដ្ឋាភិបាល គាត់និយាយថា គេចេញនូវបទបញ្ជា គាត់គ្រាន់តែមេបញ្ជាការកងទ័ព ប៉ុន្តែមេបញ្ជាការរដ្ឋាភិបាល និងអ្នក

នយោបាយមិននៅឆ្ងាយពីទីក្រុងប៉ុន្មានទេ ប៉ុន្តែគេឲ្យកងទ័ពហ្នឹងចូលខ្លួនមុនគេដើម្បីរៀបចំអ្វីៗទាំងអស់"។

តើវាស៊ីសង្វាក់គ្នាទេ សេចក្ដីថ្លែងការណ៍ដែលនិយាយដោយមេបញ្ជាការកងទ័ពហ្នឹង? ថាសេចក្ដីសម្រេចហ្នឹងនឹងត្រូវធ្វើឡើងដោយរដ្ឋាភិបាលនោះ?

[១០:៥៧:២៣]

**ឆ៖** បាទ ត្រឹមត្រូវហើយ ស៊ីសង្វាក់គ្នាហើយ។ នៅពេលខ្ញុំចេញខាងក្រៅអគារមកហ្នឹង គឺខ្ញុំដើរចេញមក ខ្ញុំឮយ៉ាងដូច្នេះ។

**ស៖** បាទ សូមអរគុណ។ ព្រឹត្តិការណ៍ដែលកើតបន្ទាប់មកទៀត គឺការមកដល់របស់ ឡុង បូរ៉េត។ ហើយលោកនិយាយដូចតទៅ សូមដកស្រង់ "នៅពេលដែលយើងនិយាយជាមួយគ្នា ឡុង បូរ៉េត ក៏មកដល់។ ប្រពន្ធគាត់បានបើកគាត់ -- មកដល់នេះតាមរយៈរថយន្តម៉ែកសឺដេស ហើយគឺវា -- គឺគាត់បានជូនដៃរបស់គាត់ ហើយគាត់ស្លៀកពាក់ជាមួយនឹងអាវយឺត ហើយនិងខោជើងវែង ហើយមើលទៅដូចភ័យខ្លាចមែនទែន ហើយភ្នែករបស់គាត់បិទបើកៗដូចជាភ័យ។ គាត់ហើយនិង សិរិមតៈ គឺជាមនុស្សពីរនាក់នៅក្នុងចំណោមពួកក្បត់ទាំងប្រាំពីរ ដែលត្រូវប្រកាសថាសម្លាប់ដោយមិនបានចេញពីប្រទេស។ ហើយគាត់បាននិយាយតាមរយៈទូរស័ព្ទពីយប់មិញ ឥឡូវនេះគាត់មិនអាចនិយាយអ្វីបានទេ។ ខ្ញុំព្យាយាមសួរសំណួរមួយចំនួនទៅគាត់ ប៉ុន្តែគាត់គ្រាន់តែនិយាយថា បាទ, ទេ ឬក៏សូមអរគុណ។ ដូច្នេះការសន្ទនានេះ គឺមិនអាចធ្វើទៅបានទេ"។

តើលោកអាចរៀបរាប់ទេនៅពេល ឡុង បូរ៉េត មកដល់ថាតើមានអ្វីកើតឡើងទៀត? ហើយនៅពេលដែលលោកព្យាយាមចង់និយាយជាមួយ ឡុង បូរ៉េត នោះតើមានអ្វីកើតឡើងទៅ លើរូបគាត់ក្រោយមក?

[១០:៥៩:០៨]

**ឆ៖** ខ្ញុំអាចនិយាយបានថា ក្រោយមកគេប្រកាសថា គេបានសម្លាប់គាត់ចោលហើយ គឺនៅពេលហ្នឹង ក្រោយពីខ្ញុំនិយាយជាមួយ ឡុង បូរ៉េត ថាតើគាត់ក្លាហាន ខ្ញុំសរសើរគាត់ក្លាហាន។ ក្រោយមកខ្ញុំចាប់ផ្ដើមមានអារម្មណ៍ថា ភ័យខ្លាចពីព្រោះខ្ញុំខ្លាចគេចាប់ខ្លួនខ្ញុំម្ដងទៀត។ យើងក៏ទៅសណ្ឋាគារវិញ រៀបចំវេចខ្ចប់ខោអាវ និងខោអាវខ្លះៗ គឺចំណីអាហារកំប៉ុង។

**ស៖** បាទ សូមអរគុណ។ យើងនិយាយអំពីនៅស្ថានទូតបារាំងផងដែរ នៅក្នុងចុងបញ្ចប់នៃកថាខណ្ឌនេះ នៅត្រង់ទំព័រ៧១ "នៅពេលដែលយើងចាកចេញពីក្រសួងព័ត៌មាន អ្នកទោសត្រូវបានគេ

យកទៅក្នុងអគារ។ នេះជាពេលចុងក្រោយហើយដែលយើងបានឃើញពួកគេ”។ តើក្រុមមនុស្ស៥២នាក់ ដែលលោកបានលើកឡើងរួមនៅក្នុងនោះមានទាំង ឡុង បូរ៉េត ផងតើមែនដែរឬទេ?

**ឆ៖** ជាពិតគឺដូច្នេះមែន។

[១១:០០:២៤]

**ស៖** តើលោកអាចសង្កេតទេ មានអ្វីដែលកើតឡើងចំពោះប្រពន្ធរបស់គាត់ ដែលជាអ្នកបើកឡានដឹកគាត់ទៅកន្លែងនោះនោះ?

**ឆ៖** ២, ៣ថ្ងៃក្រោយមក ភរិយារបស់គាត់នេះបានបើកឡានទៅដល់ច្រកទ្វារស្ថានទូតបារាំង ហើយភរិយារបស់គាត់នោះបានស្នើសុំជួបជាមួយនឹងបុរសម្នាក់ធ្វើការនៅអង្គការសហប្រជាជាតិ ធ្វើការនៅក្នុងបរិវេណស្ថានទូតនោះ។ បុរសនោះបានដើរមកសំដៅច្រកទ្វារ ហើយភរិយារបស់គាត់នោះបានស្នើសុំសិទ្ធិជ្រកកោននៅទីនោះ។ ក៏ប៉ុន្តែខ្មែរក្រហមបានប្រាប់បុរសអង្គការសហប្រជាជាតិនោះបាន -- ខ្មែរក្រហមបានប្រាប់បុរសនោះថា មិនអាចទទួលយកអ្នកដែលមានឋានៈខ្ពស់ណាទៀតចូលក្នុងស្ថានទូតនេះទេ។ មន្ត្រីទូតនៅក្នុងកន្លែងនោះគឺត្រូវបានគេប្រាប់ថា ទោះបីក្នុងករណីណាក៏ដោយគឺថាមិនអាចទទួលយកអ្នកផ្សេងនោះទេ។ ហើយមន្ត្រីដែលបានទៅជួបជាមួយនឹងអ្នកនោះ ឬក៏ភរិយានោះគឺថាមានភាពរន្ធត់ចិត្តដោយសារតែគាត់នោះមិនអាចទទួលសិទ្ធិជ្រកកោនសម្រាប់ភរិយារបស់បុគ្គលរូបនោះ។

[១១:០២:១០]

**ស៖** សូមអរគុណ។ មុនពេលដែលយើងចាកចេញពីការនិយាយអំពីក្រសួងព័ត៌មាននេះ ខ្ញុំសូមចាក់នូវខ្សែវីដេអូខ្លីមួយ ដែលក៏មាននៅក្នុងសំណុំរឿងផងដែរ គឺជាខ្សែវីដេអូឯកសារ “ការកាប់សម្លាប់របស់ ប៉ុល ពត”។ ឯកសារនេះគឺឯកសារ E3/2355R ERN គឺ 00172454 D00172454។ ឯកសារខ្សែវីដេអូនេះមានតែ ៤២វិនាទីតែប៉ុណ្ណោះដែលបានចាក់នៅក្នុងសាលសវនាការម្តងរួចមកហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ដូច្នេះសូមអនុញ្ញាតពីលោកប្រធាន ចាក់ខ្សែវីដេអូដែលមានរយៈពេលតែ៤០វិនាទីនេះ ដើម្បីបញ្ចាំងជូនមើល។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោក ស្តេនប៊ឹក វាជាឯកសារ ហើយក៏មានសំឡេងផងដែរ ឯកសារវីដេអូ មានខ្សែអាត់សំឡេង ផងដែរ ហើយនៅក្នុងនោះក៏មានរូបភាពបង្ហាញឲ្យលោកពិនិត្យមើលផងដែរ។ យើងនឹងចាក់ខ្សែវីដេអូ ជាមុន ថាតើនៅក្នុងនោះមានរូបថត រូបភាពណាមួយដែលលោកស្គាល់ដែរឬទេ?

ដូច្នេះនៅពេលនោះសូមសោតទស្សន៍ធ្វើការចាក់បញ្ចាំង។

[១១:០៣:៥០]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ប្រជាជនគឺត្រូវមានភាពឯកោ ហើយមិនបានស្គាល់អំពីកុមារដែលមានសម្លៀកបំពាក់នេះនោះ ទេ។ តើកុមារទាំងនេះជាខ្មែរដែរឬទេ? ទ័ពទាំងអស់នេះគឺជាកសិករដែលមិនចេះអក្សរ ហើយមិនដែល ធ្លាប់ចូលមកក្នុងទីក្រុង ឬមិនដែលធ្លាប់ឃើញបរិក្ខាកាលពីលើកមុននោះឡើយ។ ដូច្នេះហើយយើង ឃើញថាប្រជាជនទាំងអស់នេះ គឺជាអ្នកដែលរងគ្រោះ។ ទីបញ្ហាដំបូង គឺថាត្រូវព័ទ្ធចំពោះអ្នកមន្ត្រី រដ្ឋការ លន់ នល់។ រូបថតនេះគឺថតនូវអ្នកដែលជាធ្វើការនៅក្នុងសម័យ លន់ នល់"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:០៤:៣៥]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោក ស្តេនប៊ឹក ប្រសិនបើលោកបានពិនិត្យមើលនេះ គឺថាអំមិញនេះឃើញរូបនេះភាព ច្បាស់ដែរឬទេ?

**លោក ស៊ីដនី ស្តេនប៊ឹក៖**

**ឆ៖** បានឃើញច្បាស់ហើយ។

**ស៖** នៅក្នុងរយៈពេល២វិនាទីចុងក្រោយ យើងឃើញមានបុរសម្នាក់ស្លៀកខោវែង និងមាន គេផ្សេង មនុស្សផ្សេងទៀតឈរនៅ ជិតនោះផងដែរ។ តើទីតាំងនោះគឺលោកស្គាល់ដែរឬទេ ជាទីតាំងអ្វី ដែរ?

[១១:០៥:១៥]

**ឆ៖** ខ្ញុំដូចជាមិនស្គាល់ទេ។

**ស៖** ខ្ញុំនឹងបង្ហាញនៅលើអេក្រង់ឲ្យលោកពិនិត្យមើល ហើយសូមឲ្យលោកនៅចាំដែរឬទេ ប្រសិនបើចាំយើងនឹងសួរភ្លាមៗតែម្តង។

**លោក អាប់ឌុលឡាក់ ថារីក៖**

ដូច្នេះនៅពេលនេះសូមឲ្យសោតទស្សន៍ចាក់ពីរយៈពេល៣៦ ទៅដល់រយៈពេលបញ្ចប់ខ្សែវីដេអូអម្បាញ់មិញនេះតែម្តង ដើម្បីឲ្យយើងបានឃើញទាំងអស់គ្នាគឺពីចំណុច ៣៦វិនាទីរហូតដល់ចប់តែម្តង។ សូមឲ្យខាងសោតទស្សន៍ជួយមេត្តាចាក់។

**ប្រធានអង្គជំនុំ៖**

បាទ ផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវខ្សែវីដេអូរូបភាពអម្បាញ់មិញនេះតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១១:០៦:០០]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"រូបថតនេះគឺថតនូវរូបភាពរបស់អ្នករដ្ឋការសម័យ លន់ នល់ ដែលត្រូវបានគេយកប្រមូលផ្តុំទៅដាក់ជិតកន្លែងវាយតេនីស"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:០៦:១៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើរូបភាពនេះធ្វើឲ្យលោកនឹងឃើញឡើងវិញដែរឬទេ? តើវាជាហេតុការណ៍មួយដែលគេបានប្រមូលអ្នកប្រជាធិបតេយ្យ ឬអ្នករដ្ឋការនៅទីនោះ ឬក៏យ៉ាងណាដែរ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** ខ្ញុំមិនដែលឃើញនោះទេ ប៉ុន្តែវាមានកន្លែងវាយតេនីស នៅក្នុងទីក្រុងភ្នំពេញ។ ខ្ញុំព្យាយាមនឹករកឈ្មោះគឺជាក្លឹប។ កន្លែងនោះមានកន្លែងវាយតេនីស ដែលអ្នកជនបរទេសនោះ និងជនកម្ពុជាខ្លះនោះទៅលេងនៅទីនោះ ហើយហូបអាហារនៅទីនោះផងដែរ ហើយក៏មានអាងហែលទឹកនៅទីនោះផងដែរ។

**ស៖** សូមអរគុណ។

[១១:០៧:១២]

**ឆ៖** ខ្ញុំមិនអាចនិយាយថា កន្លែងហ្នឹងគឺជាកន្លែងដែលពួកគេកំពុងតែឈរនៅឬក៏យ៉ាងណានោះទេ។ ខ្ញុំមិនប៉ាននិយាយទេ ខ្ញុំមិនច្បាស់ទេ ហើយខ្ញុំក៏មិនបានដឹងផងដែរ។ វាអាចមានការកាប់សម្លាប់ច្រើនដែរ។ ហើយនៅថ្ងៃនោះគឺថាអាចមានការកាប់សម្លាប់ ហើយថ្ងៃក្រោយៗមក ទៀតក៏អាចមានការកាប់សម្លាប់ផងដែរ។ ខ្ញុំមិនបានដឹងនោះទេ ដូច្នេះហើយខ្ញុំមិនប៉ានឆ្លើយនោះទេ ។

**ស៖** បាទ ចម្លើយដែលលោកឆ្លើយមានសារៈសំខាន់ណាស់ សូមអរគុណ។ នៅពេលនេះគឺថាយើងកំពុងតែជជែកគ្នា និងសួរដេញដោលអំពីរបបសាធារណរដ្ឋ ជាពិសេសមន្ត្រីសាធារណរដ្ឋ។ គឺថាខ្ញុំសូមសួរបន្តរយៈកាលទៅមុខទៀតគឺថ្ងៃទី១៩ ខែមេសា ហើយសួរត្រង់ទំព័រ៨២ នៃកំណត់ហេតុប្រចាំថ្ងៃរបស់លោក។

លោកបានរៀបរាប់ដូចតទៅ គឺនៅពេលដែលលោកស្ថិតនៅក្នុងស្ថានទូតបារាំង លោក បានរៀបរាប់នូវអ្វីដែលលោកបានឮ និងបានឃើញ។ "នៅម៉ោងប្រហែលជាបួនសាមសិបនាទីល្ងាច ឡានមានឧគ្ឃោសនសព្ទបើកកាត់ស្ថានទូតពីរបីដងដោយប្រកាសថា នៅមានជនក្បត់ និងជនមហាក្បត់នៅក្នុងក្រុង។ ដូច្នេះហើយយើងត្រូវតែស្វែងរកពួកវា។ យើងគិតថាវាជាការគួរឲ្យភ័យខ្លាចនៅពេលដែលពួកគេប្រកាសដូច្នេះនៅមុខស្ថានទូត"។

[១១:០៨:៥៤]

ខ្ញុំឈប់នៅត្រង់នេះ បន្ទាប់មកខ្ញុំចូលទៅទំព័រ៨៥ វិញម្តង។ ហើយខ្ញុំនឹងអានអត្ថបទមួយទៀតជូនលោកដែលពាក់ព័ន្ធទៅនឹងថ្ងៃទី២០ ខែមេសា។ លោកលើកឡើងដូចតទៅ "ក៏ប៉ុន្តែខ្មែរក្រហមគឺមករកមនុស្សមួយចំនួននៅថ្ងៃនេះ មន្ត្រីជាន់ខ្ពស់ដែលលាក់ខ្លួននៅទីនេះ។ នៅម៉ោងពីរសាមសិបនាទីនៅក្នុងពេលដែលមានខ្យល់ត្រសៀកៗគួរឲ្យភ័យខ្លាច ទាហានមានអាវុធគឺ បានឡើងឡានហ្ស៊ីបហើយពួកគេបាននិយាយជាមួយនឹង ឌីរាក់ នៅច្រកទ្វារចូល ហើយបន្ទាប់មកចូលមកក្នុង។ ក្នុងរយៈពេលពីរបីនាទីក្រោយមកមានមនុស្សដែលពួកគេចង់បាននេះ គឺចាប់ផ្តើមដើរចេញមកក្រៅ។ ពួកគេគឺមានស្ត្រី និងកុមារ។ សិរិមតៈ ចេញពីស្ថានទូតគាត់ដើរទៅកាន់ច្រកទ្វារ។ បុរសបារាំងឈរនៅក្បែរគាត់និយាយថាអតីតនាយករដ្ឋមន្ត្រីត្រូវបានប្រាប់ខ្មែរក្រហមថា ពួកគេដឹកខ្ញុំចេញទៅហើយ ខ្ញុំមិនខ្លាចទេ ខ្ញុំត្រៀមខ្លួនទទួលខុសត្រូវ។ អ្នកទោសទាំងអស់គឺធ្វើឫកជា អត្តចរិតមួយគួរឲ្យគោរព ជាពិសេសសម្រាប់ ហុង ប៊ុនហួរ។ អ្នកទោសត្រូវបានដាក់នៅក្នុងឡានមួយ ពីរបីនាទីក្រោយមកពួកគេបានអង្គុយក្រោមភ្លៀង។

ប្រហែលជាម៉ោងបីជាង ឡាននោះបានបើកកាត់យឺតៗពីមុខស្ថានទូតចេញទៅ។

តើហេតុការណ៍នេះដែលលោកបានឃើញ គឺការប្រគល់ខ្លួនរបស់ ហុង ប៊ុនហួរ និងសិរិមតៈ តើលោកបានឃើញដែរឬទេ?

[១១:១០:៥៥]

**ធ៖** បាទ ខ្ញុំបានឃើញ គឺពិបាកមើលណាស់នាពេលនោះ។

**ស៖** លោកឆ្លើយ លោកបាននិយាយថា ពួកគេយកមនុស្សដែលពួកគេចង់បានចេញទៅហើយ ដូច្នេះតើហេតុអ្វីបានជាលោកប្រើប្រាស់ពាក្យដូច្នេះ?

**ធ៖** អ្នកដែលពួកគេចង់បាន លោកសំដៅលើពាក្យហ្នឹងឬយ៉ាងម៉េច?

**ស៖** បាទ គឺលោកនិយាយថាអ្នកដែលខ្មែរក្រហមចង់បាន?

**ធ៖** ជាការពិតទៅ គឺខ្ញុំសរសេរដោយសារតែខ្ញុំបានឃើញអ្វីដែលបានកើតឡើង។ ខ្មែរក្រហមបានមកដល់ ហើយបាននិយាយថាមានមនុស្សនៅក្នុងហ្នឹង ឌីរាក់ បានចូលទៅ ហើយបន្ទាប់មកនោះខ្មែរក្រហមបាននាំពួកហ្នឹងចេញមក។

[១១:១១:៤៨]

ដូច្នេះខ្ញុំគិតថាឃ្លាហ្នឹងហើយ ដែលចេញពីអ្វីដែលខ្ញុំបានឃើញដូច្នេះ។ ខ្មែរក្រហមប្រាប់ ឌីរាក់ ថាពួកគេចង់បានមនុស្សហ្នឹង។ ឌីរាក់ បាននិយាយអំពីបញ្ហាហ្នឹងផងដែរ នៅយប់នោះ។ គឺនៅយប់នោះគាត់បាននិយាយថា ខ្មែរក្រហមបានចូលមកស្ថានទូត ហើយចាប់មនុស្សមួយចំនួនយកដាក់ឡានចេញទៅ។ គឺគាត់បានលើកឡើងអំពីពលរដ្ឋកម្ពុជាដែលពុំមានលិខិតបញ្ជាក់ពីបរទេស ត្រូវតែចាកចេញពីស្ថានទូត។ ឌីរាក់ ក៏ធ្លាប់ជាអ្នកទោសឈ្លើយសឹកនៅក្នុងសង្គ្រាមលោកលើកទី២ផងដែរ គាត់គឺជាមនុស្សល្អ។ ឌីរាក់ បាននិយាយថា នៅពេលដែលយើងធ្វើដូច្នេះ បានន័យថានៅពេលដែលយើងទៅប្រាប់អ្នកហ្នឹងឲ្យពួកគេដើរចេញពីស្ថានទូតនោះ បើសិនជាយើងដើរទៅប្រាប់គេឲ្យចេញពីស្ថានទូតអ៊ីចឹងយើងមិនមែនជាមនុស្សនោះទេ។

**ស៖** នៅពេលនេះ គឺយើងឯកសារមួយច្បាប់ដែលខ្ញុំបានបញ្ជូនឲ្យលោកពិនិត្យមើលផងដែរ គឺសារទូរលេខមកពីស្ថានទូតបារាំង ពាក់ព័ន្ធទៅនឹងហេតុការណ៍នេះ។ ឯកសារលេខ D199/26.2.199 គឺជាសារទូរលេខចុះថ្ងៃ១៨ ខែមេសា ឆ្នាំ៧៥ មានតែមួយទំព័រតែប៉ុណ្ណោះ។

[១១:១៣:៤១]

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធានជាទីគោរព ខ្ញុំសូមអនុញ្ញាតអានចេញពីសារទូរលេខនេះដើម្បីឲ្យសាក្សីស្តាប់មើលថាតើឯកសារនេះបានជួយជាប្រយោជន៍អ្វីខ្លះដល់យើងទាំងអស់គ្នា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

[១១:១៤:០០]

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណ។

**ស៖** លោក ស្តេនប៊ីក ឯកសារនេះចុះថ្ងៃ១៨ ខែមេសា ឆ្នាំ៧៥ គឺសរសេរដោយ និពន្ធដោយ ឌីរាក់ ចុះហត្ថលេខាដោយ ឌីរាក់ ផងដែរ។ មានសរសេរដូចតទៅ៖

"កម្មវត្ថុ៖ ការសុំជ្រកកោននយោបាយ ខ្ញុំយោងទៅលើសារទូរលេខ ៥៨៦, ៥៨៧, ៥៩៤។ ក្រោយពីការបរិច្ឆេទរបស់គណៈកម្មការក្រុង ខ្ញុំធ្វើការបង្ខំ ធ្វើការពិចារណាទៅលើបុគ្គលដែលមានក្នុងបញ្ជីក្នុងស្ថានទូត។ ទី១ ទ្រង់សិរិមតៈ, ព្រីនសេស មុំ ម៉ានីវង្ស ដែលជាប្រពន្ធ ហើយនិងមានកូនសម្តេចសីហនុ ផងដែរ។ ទី៣ លោក អ៊ុង ប៊ុនហ៊ំ ប្រធានសភា, ទី៤ លោក លឿង ណាល់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ក្រោយពីមានការសុំសិទ្ធិជ្រកកោននោះ គឺខ្ញុំត្រូវបានគេបង្ខំឲ្យៗបញ្ចេញមនុស្សទាំងអស់នេះចេញពីស្ថានទូតក្នុងរយៈពេល២៤ម៉ោង"។ លោក ស្តេនប៊ឹន តើលោកស្គាល់ឈ្មោះបុគ្គលមួយចំនួន ក្រៅពីបុគ្គលដែលលោកបានលើកឡើងឈ្មោះអម្បាញ់មិញដែរឬទេ?

[១១:១៥:២៦]

**ឆ៖** ខ្ញុំស្គាល់គ្រួសារហ្នឹងខ្លះ ជាពិសេសឈ្មោះ ក៏ប៉ុន្តែខ្ញុំមិនដែលជួបពួកគាត់នោះទេ។ ហើយផ្នែករបស់ខ្ញុំនេះ គឺសំឡឹងមើល សិរិមតៈ។ ដោយសារតែទ្រង់ សិរិមតៈ ប៉ុន្មានថ្ងៃមុននាពេលនោះ ប្រហែលជា១ថ្ងៃតាមខ្ញុំដឹង គឺគាត់ទ្រង់បានបញ្ជូនសារមួយច្បាប់ទៅប្រធានាធិបតី ដូចជា ឃីស៊ីងហ្គ័រ, ខ្ញុំមិនចាំទេ, បានលើកឡើងថា "លោកបោះបង់ពួកយើងចោល។ លោកបាននិយាយថា លោកជួយយើងក៏ប៉ុន្តែនៅពេលនេះ លោកមិនបានជួយយើងទេ"។ គាត់សរសេរ...។ល។ ហើយ សិរិមតៈ គាត់លើកឡើងថាគាត់នឹងនៅក្នុងប្រទេសរបស់គាត់មិនចាកចេញទេ រហូតទៅដល់ថ្ងៃចុងក្រោយ។

[១១:១៦:៣១]

**ស៖** សូមអរគុណ។

**ឆ៖** នៅពេលដែលគាត់ចាកចេញពីបរិវេណនោះ គឺថាគាត់ឈរត្រង់ដូចពលរដ្ឋខ្មែរ ហើយគាត់ឈររឹងត្រង់តែម្តង។ គាត់មានទឹកមុខមាំនាពេលនោះ។

**ស៖** សូមអរគុណ។ នៅក្នុងសារទូលេខនោះ គឺមានសរសេរយោងថ្ងៃកំណត់ដោយគណៈកម្មាធិការក្រុង។ តើលោកអាចជួយពន្យល់បញ្ជាក់បានដែរឬទេ តើវាពាក់ព័ន្ធនឹងអ្វីដែរ កាលបរិច្ឆេទផុតកំណត់? ហើយលោកបាននិយាយអំពីគណៈកម្មាធិការក្រុងនោះ តើលោកស្គាល់ទេ? ហើយលោកស្គាល់គណៈកម្មាធិការនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនស្គាល់ទេ។ ខ្ញុំពិតជាមិនស្គាល់នោះទេ។

[១១:១៧:២៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអនុញ្ញាតពីលោកប្រធានបង្ហាញរូបថតមួយសន្លឹកដើម្បី ឲ្យលោកពិនិត្យមើល តើលោកស្គាល់ដែរឬទេ? គឺឯកសារ E190.1.307 ឯកសារកាសែតញូវស៍វីក ចុះខែឧសភា ឆ្នាំ១៩៧៥ គឺសរសេរដោយ ស្តេនប៊ីក រៀបរាប់អំពីហេតុការណ៍នាពេលនោះ។

ដូច្នេះសូមអនុញ្ញាតពីលោកប្រធានធ្វើការបង្ហាញរូបថត ដែលមាននៅក្នុងអត្ថបទកាសែតនោះជូនសាក្សីពិនិត្យមើល។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

[១១:១៨:១៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** រូបថតនេះ គឺមានរូបភាពច្បាស់ ត្រង់ ERN ជាភាសាអង់គ្លេស 00445261។ ដូច្នេះខ្ញុំនាពេលនេះ ស្នើសុំឲ្យជំនួយការរបស់ខ្ញុំធ្វើការបញ្ចាំងនៅលើអេក្រង់ ដោយមានការអនុញ្ញាតពីលោកប្រធាន។

លោក ស្តេនប៊ីន តើលោកមានរូបថតនេះមួយច្បាប់នៅចំពោះមុខដែរឬទេ?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** ខ្ញុំមាន។

**ស៖** សូមលោកទុកពេលឱ្យយើងខ្ញុំមួយភ្លែតសិន ដើម្បីធ្វើការរកមើល ERN ហើយដើម្បីបញ្ចាំងជូនចៅក្រម និងភាគីដទៃទៀតនៅក្នុងបន្ទប់សវនាការ។

[១១:១៩:១៨]

**ឆ៖** បាទខ្ញុំអាចចាំបាន។

**ស៖** យើងមានរូបថតនេះហើយត្រៀមសម្រាប់បង្ហាញជូនយើងទាំងអស់គ្នា។ សូមឱ្យសោតទស្សន៍ធ្វើការជួយបញ្ចាំង១រូបថត និងជូនយើងទាំងអស់គ្នានៅក្នុងបន្ទប់សវនាការ និងនៅក្រៅបន្ទប់សវនាការផងដែរ។ ពាក្យនៅខាងក្រោមនេះគឺថា "គ្មានជម្រក ហុង ប៊ុនហួរ ត្រូវបានបង្ខំដោយបណ្ដេញចេញដោយបារាំង"។ តើនៅក្នុងរូបថតនេះលោកស្គាល់ទេគឺជា ហុង ប៊ុនហួរ ឬក៏យ៉ាងម៉េច នរណាដែរ?

**ឆ៖** ខ្ញុំបានឃើញរូបថតនេះ ខ្ញុំមិនបានឃើញហេតុការណ៍ដោយផ្ទាល់នោះទេ មិត្តរបស់ខ្ញុំម្នាក់គឺបានឃើញហេតុការណ៍ហ្នឹង ជួបគាត់ ហើយវាមានហេតុការណ៍ហ្នឹងកើតឡើងមែន។ យើងឃើញនៅពេលនោះមានលុយមួយក្ដាប់នៅក្នុងវ៉ាលិស ក៏ប៉ុន្តែខ្ញុំមិនដែលឃើញហេតុការណ៍នេះបានកើតឡើងនោះទេ។ វាមិនមែនជាហេតុការណ៍មួយដែលខ្ញុំបានចាប់អារម្មណ៍ និងផ្ដោតអារម្មណ៍នោះទេ។

**ស៖** សូមអរគុណ យើងបន្តទៅមុខទៀត។ ពាក់ព័ន្ធទៅនឹងហេតុការណ៍នៃការដកបញ្ចេញមន្ត្រីសាធារណរដ្ឋខ្មែរចេញពីស្ថានទូត សូមឱ្យលោកមើលទំព័រ៩៥, ៩៦, ៩៧, អង់គ្លេស 00898303 និងទំព័របន្តបន្ទាប់។ លោកបានរៀបរាប់នៅក្នុងនោះអំពីការសន្ទនាដែលលោកធ្វើឡើងនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ៧៥ ជាមួយនឹងអ្នកជំនួញបារាំង ជាពិសេសរវាងជំនួញជាមួយនឹងខ្មែរក្រហម។ នេះគឺជាហេតុការណ៍មួយចំនួនដែលគាត់បានរាយរាប់ប្រាប់លោក។

[១១:២១:៥៧]

សូមដកស្រង់សម្ដី៖ "ខ្មែរក្រហមលើកឡើងថា គេកំពុងតែព្យាយាមសម្លាប់អ្នកពីរបបចាស់ ជាពិសេសអ្នកដែលកំពុងតែលាក់ខ្លួននៅក្នុងក្រុង។ ហេតុដូច្នេះហើយភូមិភាគនេះ គឺស្ថិតនៅក្នុងការគ្រប់គ្រងរបស់យោធា មិនទាន់មានសន្តិសុខត្រឹមត្រូវ"។

ក្រោមហ្នឹងបន្តិចទំព័រដដែល គាត់បានលើកឡើងថា "យើងចំណាយពេល១អាទិត្យហើយ ដោយសារការជម្លៀស ជាពិសេសនោះគឺដោយសារយើងរង់ចាំត្រីធំ សិរិមតៈ ដែលកំពុងនៅក្នុងស្ថានទូត"។

នៅខាងក្រោមហ្នឹងបន្តិច បើកថាខណ្ឌទៀត គាត់លើកឡើងថា "ខ្មែរក្រហមហៅមនុស្សទាំងអស់នោះថា ហៅអ្នកដែលនៅក្នុងលាក់ក្នុងក្រុងគឺជាពួកព្រៃ។ ដូច្នេះនៅពេលនោះ គឺថាអ្នកដែលនៅក្នុងស្ថានទូតនោះក៏ត្រូវបានគេបញ្ចេញពីស្ថានទូតមកឲ្យខ្មែរក្រហម"។

តើព័ត៌មានទាំងអស់នេះ គឺលោកទទួលបានពីអ្នកជំនួញបារាំងដែលលោកបានជួបសន្ទនាជាមួយលោកលើកឡើងអំពីការដែលគេចង់ចាប់មន្ត្រីសាធារណរដ្ឋខ្មែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ជាការពិតគឺខ្ញុំបានទទួលព័ត៌មានដូច្នេះមែន។

[១១:២៣:១១]

**សៈ** មានចំណុចមួយទៀតនៅក្នុងទំព័របន្ទាប់ ខ្ញុំសូមដកស្រង់សម្ដី បុរសបារាំងនោះនិយាយថា "នៅពេលដែលក្រុមកម្ពុជាមួយក្រុមធំ ចាកចេញពីស្ថានទូត២ថ្ងៃមុននោះពួកគេត្រូវបានដឹកទៅស្ដាតក្រុង ហើយប្រជាជនទាំងអស់ត្រូវបានដឹកចេញតាមឡាន បើកចេញទៅតាមផ្លូវ។ គាត់យល់ឃើញថា ខ្មែរក្រហមមានបណ្ដាញល្អណាស់ ជាពិសេសអ្នកដែលប្រាប់ពួកគេ ភ្នាក់ងារដែលប្រាប់ពួកគេអំពីអ្នកដែលស្ថិតនៅក្នុងក្រុង នរណាខ្លះដែលធ្លាប់នៅក្នុងក្រុងមុនពេលជ័យជម្នះ"។

តើលោកនៅចាំទេអំពីការរៀបរាប់នេះ? ជាពិសេសគឺការដកមនុស្សទៅតាមឡានចេញទៅ គឺមនុស្សដែលចាកចេញ ដែលគេដកមកពីស្ថានទូតនោះ។ តើលោកនឹកឃើញទេ លោកធ្លាប់ឮពាក្យហ្នឹងពីក្នុងកិច្ចប្រជុំ ឬធ្លាប់ឮពីគេដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចធានាចំពោះព័ត៌មាននេះទេ។ ខ្ញុំមិនបានដឹងថា តើពិតជាកើតឡើងដែរឬទេចំពោះហេតុការណ៍នេះ ក៏ប៉ុន្តែមានរឿងរ៉ាវមួយចំនួនកើតឡើងនៅក្នុងពេលនោះ។ ខ្ញុំមិនបានដឹងអំពីហេតុការណ៍នេះទេ ចំពោះហេតុការណ៍មួយនេះ។ ហើយហេតុការណ៍នេះគឺជាហេតុការណ៍បង្ហាញឲ្យយើងឃើញមួយ ដែលវាអាចឲ្យយើងអ្នកថតរូប ឬក៏អ្នកសារព័ត៌មានបានដឹង។ ហើយមានមនុស្សមួយចំនួនបានត្រូវគេយកចេញពីស្ថានទូតនេះ មុនពេលដែលគេយក សិរិមតៈ ចេញទៅ។ ហើយអ្នកទាំងអស់នោះគឺមិនចង់ពាក់ព័ន្ធទៅនឹងស្ថានភាពនេះ។ ដូច្នេះនៅក្នុងការរៀបចំកន្លែងជ្រកកោននោះ គឺថាគេបានរៀបចំ ក៏ប៉ុន្តែខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះអ្នកអាជីវករបារាំងដែលបានរៀបរាប់ចំពោះខ្ញុំនោះទេ។

[១១:២៤:១១]

**សៈ** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងអ្នកដែលជាពលរដ្ឋកម្ពុជា ហើយត្រូវបានបណ្ដេញចេញពីបរិវេណនោះ ខ្ញុំនឹងអានកំណត់ហេតុរបស់លោកទំព័រ៨៣, ៨៤, អង់គ្លេស ERN 0089821 ទៅដល់

22។ គឺថ្ងៃទី២០ ខែមេសា ដែលលើកឡើងអំពីហេតុការណ៍ហ្នឹងមុនបន្តិច។ ខ្ញុំសូមលើកឡើងថា វាពាក់ព័ន្ធទៅនឹងការចាកចេញរបស់ជនជាតិកម្ពុជាពីស្ថានទូត លោកបានលើកឡើងអំពីចំណុចហ្នឹងផងដែរ។

ដកស្រង់សម្តី៖ "នៅម៉ោងប្រហែលប្រាំពីរសាមសិបនាទីព្រឹក មានព័ត៌មានអាក្រក់ សមាជិករបស់ស្ថានទូតចាប់ផ្តើមដើរចុះដើរឡើងនៅក្នុងស្ថានទូត ប្រាប់ជនជាតិកម្ពុជាថា ប្រសិនបើមិនមានឯកសារពីបារាំងនោះទេ ត្រូវតែចាកចេញពីស្ថានទូត ដើម្បីទៅតាមទីជនបទ។ យើងចង់ជួយពួកលោកក៏ប៉ុន្តែយើងគ្មានវិធីនោះទេ។ ប្រសិនបើលោកនៅតែនៅក្នុងស្ថានទូតយើងនឹងមានបញ្ហា"។

កថាខណ្ឌពីរខាងក្រោម គឺលោកបានរៀបរាប់ដូចតទៅ "បន្តិចក្រោយមកយើងបានដឹងថា បារាំងផ្តល់ប្រឹក្សាដល់កម្ពុជាថា វាមានការណែនាំពីខ្មែរក្រហម។ នៅក្នុងកិច្ចប្រជុំចុងក្រោយគេបានប្រាប់ ឌីរាក់ ថាគឺគេចង់រកអ្នកដែលមិនមានឯកសារបារាំង ជាពិសេសចង់ជ្រកកោន ចាកចេញពីប្រទេសកម្ពុជា"។

[១១:២៧:៣២]

តើលោកអាចជួយពន្យល់ ផ្តល់ព័ត៌មានអំពីហេតុការណ៍ដែលគេលើកឡើងថា ស្ថានទូតនាពេលនោះ គឺជាកន្លែងដែលគេប្រមូលផ្តុំជនជាតិបរទេសនោះ? តើលោកបានដឹងទេថា ឌីរាក់ បានលើកឡើងអ្វីខ្លះជាពិសេសនៅពេលដែលគាត់ទាក់ទងជាមួយនឹងខ្មែរក្រហមនោះ?

**ឆ៖** កថាខណ្ឌដែលលោកបានអានអម្បាញ់មិញ គឺយើងក៏បានត្រូវបានគេប្រាប់ផងដែរ ហើយគេប្រាប់ដូច្នេះ។ ឌីរាក់ មានអារម្មណ៍មិនសប្បាយចិត្តទេនៅពេលនោះ ប៉ុន្តែគាត់គ្មានជម្រើស។ រដ្ឋាភិបាលរបស់គាត់ គឺមិនឱ្យគាត់ផ្តល់សិទ្ធិជ្រកកោនចំពោះអ្នកដែលខ្មែរក្រហមស្គាល់នោះទេ។ ឌីរាក់ គ្មានសិទ្ធិផ្តល់សិទ្ធិជ្រកកោននោះទេនាពេលនោះ។

**ស៖** តាមការសង្កេតរបស់លោក លើកលែងតែអ្នកដែលមានលិខិតឆ្លងដែនបរទេស តើពលរដ្ឋកម្ពុជាទាំងអស់ដែលគ្មានលិខិតឆ្លងដែនបរទេសនោះ បានចាកចេញពីស្ថានទូតដែរឬទេ នៅក្នុងថ្ងៃបន្តបន្ទាប់ក្រោយមកនោះ?

[១១:២៨:៥៣]

**ឆ៖** ដូចជាមិនអស់ ទាំងអស់គ្នានោះទេ។ ពលរដ្ឋកម្ពុជាខ្លះ គឺនៅតែដើរចុះដើរឡើងនៅក្នុងស្ថានទូត ហើយគិតថាពួកគេនោះនៅតែមានលទ្ធភាពឡើងជិះចាកចេញពីប្រទេសតាមក្បួនចាកចេញទៅផងដែរ។ ខ្ញុំគិតថា អ្នកទាំងអស់នោះ គឺអាចចាកចេញទៅបានខ្លះដែរ ដោយមានការជួយពី ប៊ីហ្សូ យើងបានជួយពួកគេតាមជើងហោះហើរ ក្បួនលើកទី១នៅពេលព្រឹក។ ដោយសារតែគេមិនបានអាច

សម្គាល់តាមរយៈពណ៌សម្បុរស្បែក។ ដូច្នេះហើយគឺពួកគេអាចគេចចេញទៅបាន។ ខ្ញុំមិនដឹងថា ប៉ុន្មាននាក់ទេ ដែលអាចរត់គៀសខ្លួនចេញទៅបាននោះ ក៏ប៉ុន្តែមានខ្លះដែរ ដោយមាន ប៊ីហ្ស៊ូ ជាអ្នកជួយ។ ស្ត្រី និងកុមារ នៅពេលនោះ គឺអាចចាកចេញទៅខ្លះដែរ ក៏ប៉ុន្តែខ្ញុំមិនដឹងច្បាស់ប៉ុន្មាននោះទេ។ ខ្ញុំសួរថា ច្រើន ឬតិចនោះ ព្រោះខ្ញុំមិនអាចប្រាប់ផងដែរ។

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណ។ លោកប្រធាននៅពេលនេះខ្ញុំនឹងប្តូរប្រធានបទថ្មី តើវាជាពេលសមស្របសម្រាប់ឈប់សម្រាក ឬក៏បន្តទៅមុខទៀតលោកប្រធាន?

[១១:៣០:១៧]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលតទៅនេះ រហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ ដែលមានរហស្សនាម TCE-12 ដែលនឹងសួរដេញដោលដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីដទៃទៀតនៃរឿងក្តី។

ឯសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឹក ផ្អាកត្រឹមនេះសិន។ សវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះនឹងបន្តនៅព្រឹកស្អែកចាប់ផ្តើមពីម៉ោងប្រាំបី និងសាមសិបនាទី។

[១១:៣១:០០]

លោក ស៊ីដនី ស្កេនប៊ឹក សវនាការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះត្រូវសម្រាកហើយ តែការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ សវនាការស្តាប់សក្ខីកម្មលោកត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងសូមអញ្ជើញលោកបន្តផ្តល់សក្ខីកម្មតាមមធ្យោបាយសោតទស្សន៍នៅថ្ងៃស្អែកទៀត។ ពេលវេលាដែលនឹងចាប់ផ្តើម គឺដូចនៅថ្ងៃនេះដែរគឺនៅម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ម៉ោងនៅកម្ពុជា។ លោកស្តាប់បានទេលោក ស្កេនប៊ឹក?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

បាទ លោកប្រធានខ្ញុំស្តាប់បានច្បាស់ហើយ។ បាទខ្ញុំនឹងត្រៀមខ្លួនរួចរាល់នៅម៉ោងប្រាំបីសាមសិបលោកប្រធាន។

[១១:៣១:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ស្កេនប៊ឺក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលាសវនាការនេះ និងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះ តាមកាលបរិច្ឆេទបានកំណត់រួចហើយ ហើយនិងបានជម្រាបជូនភាគីរួចហើយ គឺអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញដែលមានរហស្សនាម TCE-12។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញអ្នកជំនាញចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំគិតថាការណែនាំពីចៅក្រមនៃអង្គជំនុំជម្រះ គឺថាយើងស្នើសុំឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់កាលពីម្សិលមិញតាមអ៊ីម៉ែល។ យើងស្នើសុំថា តើយើងមានអាចមានពេលវេលាបន្ថែមទៀត ដើម្បីធ្វើការសួរដេញដោលទៅលើសាក្សីរូបនេះ។ ព្រោះថាពេលវេលាដែលយើងត្រូវការ គឺវាអាស្រ័យទៅលើចម្លើយដែលអ្នកជំនាញផ្តល់ទៅដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែយើងក៏ធ្វើការពិចារណាផងដែរ ទៅ

លើកាលៈទេសៈដែលថាសាក្សីអ្នកជំនាញនេះ បានផ្តល់នូវសំណុំរឿង០០១ដែលបានផ្តល់ដោយសាក្សីរូបនេះ។ ហេតុដូច្នេះហើយយើងគិតថា ពេលវេលាដែលបែងចែកឲ្យយើងប្រហែលជាមួយម៉ោង ឬក៏មួយម៉ោងតិចតួចនេះ វាហាក់ដូចជាមិនគ្រប់គ្រាន់។ ដូច្នេះ ខ្ញុំស្នើថាឥឡូវនេះ យើងបន្តសិនទៅ ហើយយើងចាំមើលថាតើសាក្សីអ្នកជំនាញហ្នឹងគាត់ឆ្លើយយ៉ាងម៉េច បន្ទាប់មកយើងនឹងសម្រេចតទៀត ថាតើយើងស្នើសុំដូចដែលយើងបានស្នើសុំកាលពីម្សិលមិញ ឬមួយក៏យ៉ាងណា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក កូប៉េ។

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លី។ គាត់ជាអ្នកជំនាញដែលបានធ្វើសក្ខីកម្មក្នុងសំណុំរឿង០០១ហើយ។ ដូច្នេះ ខ្ញុំគិតថាការដែលនិយាយថា អ្នកជំនាញនោះដែលអាចធ្វើសេចក្តីថ្លែងការណ៍នោះ គឺមិនត្រឹមត្រូវទេ។ ដូច្នេះ ការដែលលើកឡើងដោយខាងមេធាវីការពារក្តីអម្បាញ់មិញនេះ គឺវាមិនសមស្របនោះទេ។

[១៣:៣៦:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ កាលពីម្សិលមិញនេះមានសំណើពីខាងមេធាវីការពារក្តីមែន ដែលតំណាងឲ្យខាង នួន ជា ពាក់ព័ន្ធទៅនឹងអ្នកជំនាញរូបនេះ។ គឺពាក់ព័ន្ធទៅនឹងពេលវេលាផ្តល់ជូនដល់ភាគី។ យើងខ្ញុំកត់សម្គាល់ឃើញនូវអ៊ីម៉ែលរបស់ ណាតាលី ដែលបានធ្វើក្នុង -- តាំងនាមឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណី។ គឺថាការធ្វើហ្នឹង ពាក្យសុំហ្នឹង គឺថាវាយឺតពេលទៅហើយ យើងដឹងថាគាត់នឹងមកផ្តល់សក្ខីកម្មតាំងពីយូរណាស់ហើយ។ ហើយកាលពី២០០៩ ក៏យើងដឹងដែរថា មានការមកផ្តល់សក្ខីកម្មនោះ។ ដូច្នេះ វាមិនសមស្របទេ ដែលគាត់ស្នើសុំផ្លាស់ប្តូរពេលវេលានោះ។ ដូច្នេះ ប្រសិនបើអង្គជំនុំជម្រះសម្រេចទៅតាមការស្នើសុំរបស់ នួន ជា នោះយើងក៏អាចស្នើសុំបន្ថែមពេលវេលាខាងសហព្រះរាជអាជ្ញាដែរ ប្រសិនជាអង្គជំនុំជម្រះផ្តល់ជូនមេធាវីការពារក្តីបែបនេះ ក៏យើងសុំដែរ។ ក៏ប៉ុន្តែយើងគិតថា សំណើហ្នឹងគឺថាមិនសមស្របទេ ពីព្រោះថាដាក់

យឺតពេលទៅហើយ។ សូមអរគុណលោកប្រធាន។

[១៣:៣៨:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤០:០៦]

**ប្រធានអង្គជំនុំ៖**

បាទ បន្ទាប់ពីបានស្ដាប់នូវសំណើសុំរបស់មេធាវីការពារក្ដីលោក នួន ជា និងភាគីដទៃទៀតដែលមានការពាក់ព័ន្ធនឹងពេលវេលានេះអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិចារណាសម្រេចនូវពេលវេលាខាងមុខងនេះ ពីព្រោះសំណើនេះអាស្រ័យទៅលើស្ថានភាពជាក់ស្ដែងនៃភាពសំខាន់ ឬក៏ភាពចាំបាច់នៃសំណួរដែលសួរឡើងដោយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលភាគីពាក់ព័ន្ធនឹងអាចតាំងសំណួរបែបណា ឬក៏ត្រូវការពេលវេលាសមស្របបែបណានោះ។ ដូច្នេះបញ្ហានេះអង្គជំនុំជម្រះនឹងពិនិត្យពិចារណាទៅតាមស្ថានភាពជាក់ស្ដែងនៅពេលខាងមុខ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញគាត់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[១៣:៤១:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ សួស្ដីលោកអ្នកជំនាញ តើលោកអ្នកជំនាញឈ្មោះ ឈឹម សុធារ៉ា អ៊ីចឹងពិតមែនដែរទេ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះ! ខ្ញុំបាទ ឈ្មោះ ឈឹម សុទ្ធារ៉ា ពិតប្រាកដ មែន។

**ស៖** បាទអរគុណ លោក ឈឹមសុទ្ធារ៉ា តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំបាទអាយុ ៤៥ឆ្នាំ។

**ស៖** បាទ អរគុណហើយតើទីលំនៅសព្វថ្ងៃរបស់លោកនៅទីកន្លែងណា? ហើយលោកប្រកបមុខរបរធ្វើអ្វីដែរ?

**ឆ៖** ទីលំនៅសព្វថ្ងៃ ខ្ញុំបាទរស់នៅផ្ទះលេខ២ លេខ៤ ផ្លូវឧកញ៉ាវាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌ

00919059



សែនសុខ។ ហើយមុខរបររបស់ខ្ញុំបាទ គឺជាគ្រូពេទ្យឯកទេសខាងជំងឺផ្លូវចិត្ត និងជានាយកអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។

**ស៖** បាទ អរគុណលោក សុធារ៉ា។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹងគឺលោកមិនមានជាប់ចំណាងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៃរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិពន្ធ ឬក៏ញាតិលោហិតជាមួយជនជាប់ចោទ ទាំងពីររូបគឺលោក នួនជា និងលោក ខៀវ សំផន ដែរ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដហើយលោកប្រធាន។

[១៣:៤៣:១៥]

**ស៖** បាទ អរគុណ។ ហើយតាមរបាយការណ៍ដដែលគឺថាលោកបានធ្វើសម្បថរួចហើយមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះតើពិតមែនដែរទេ?

**ឆ៖** បាទ ពិតប្រាកដហើយបាទ។

**ស៖** បាទ អរគុណហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគីនៃរឿងក្ដីថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មអ្នកជំនាញរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាំងសំណួរដេញដោលមុនភាគីដទៃទៀតនៃរឿងក្ដី។ បាទ ហើយពេលវេលាដែលបានកំណត់នេះគឺមានរយៈពេល១ម៉ោង ៤៥នាទី។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម ភាគីអង្គសវនាការទាំងមូល។ សូមជម្រាបសួរលោកអ្នកជំនាញ។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរលោកហើយបន្ទាប់ពីខ្ញុំបញ្ចប់សំណួររបស់ខ្ញុំលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងបន្តសំណួរពីខាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងអ្វីដែលជាជំនាញរបស់លោក។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ជាបឋមតើលោកអាចជម្រាបអង្គសវនាការបានទេ អំពីការសិក្សារបស់លោកពាក់ព័ន្ធទៅនឹងជំនាញផ្នែកចិត្តសាស្ត្រ។ បាទសូមលោកជួយបំភ្លឺ។

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទសូមអរគុណលោកមេធាវីនាំមុខ។ ខ្ញុំបាទបានសិក្សាខាងផ្នែកវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលភ្នំពេញ ដែលបញ្ចប់នៅក្នុងឆ្នាំ១៩៩២។ ហើយបន្ទាប់មកនៅឆ្នាំ១៩៩៤ ខ្ញុំបាទបានបន្តការសិក្សាថ្នាក់ឯកទេសខាងជំងឺផ្លូវចិត្តហ្នឹងជាមួយសាកលវិទ្យាល័យអូស្លូរបស់ប្រទេសន័រវេស និងសាកលវិទ្យាវិទ្យាសាស្ត្រសុខាភិបាល។ ហើយដែលបានបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ នៅក្នុងឆ្នាំ១៩៩៨។ ហើយបន្ទាប់មកនៅឆ្នាំ៩៩ទៅឆ្នាំ២០០០ ខ្ញុំបានបន្តការសិក្សាបន្តទៀតថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យញ៉ូវសាវ៉េល នៃប្រទេសអូស្ត្រាលី។ ហើយដែលខ្ញុំបានបញ្ចប់សញ្ញាបត្រអនុបណ្ឌិតនៅឆ្នាំ២០០០។ សព្វថ្ងៃនេះ ខ្ញុំបាទកំពុងតែបន្តការសិក្សាថ្នាក់បណ្ឌិតទៀត ខាងផ្នែកបណ្ឌិតទស្សនវិជ្ជា ខាងផ្នែកសុខភាពផ្លូវចិត្តហ្នឹងនៅសាកលវិទ្យាល័យម៉ូណាសនៃប្រទេសអូស្ត្រាលី។ ហើយសព្វថ្ងៃនេះ ខ្ញុំនៅក្នុងជាបេក្ខជននៅក្នុងឆ្នាំចុងក្រោយដែលរៀបនឹងជិតនឹងបញ្ចប់ការសិក្សាហើយបាទ។

[១៣:៤៦:២៥]

**ស៖** បាទសូមអរគុណ។ សំណួរបន្តរបស់ខ្ញុំ ខ្ញុំចង់សុំសួរលោកពាក់ព័ន្ធទៅនឹងប្រវត្តិការងាររបស់លោកវិញម្តង។ ថាតើលោកអាចជម្រាបអំពីអំពីប្រវត្តិការងាររបស់លោកបានឬទេ ជាពិសេសពាក់ព័ន្ធទៅនឹងជនរងគ្រោះនៃសម័យខ្មែរក្រហម។ អ៊ីចឹងប្រវត្តិការងារទូទៅរបស់លោក ហើយនិងប្រវត្តិការងារពាក់ព័ន្ធទៅនឹងជនរងគ្រោះដែលលោកធ្វើផ្ទាល់? សូមអរគុណ។

**ឆ៖** បាទសូមអរគុណលោកមេធាវី។ ក្នុងផ្នែកវិស័យសុខភាពផ្លូវចិត្តនេះ ខ្ញុំបាទបានធ្វើការរយៈពេលប្រហែលជា១៩ឆ្នាំហើយ។ អ៊ីចឹងខ្ញុំបាទ ជាអ្នកឯកទេសមួយក្នុងចំណោមអ្នកឯកទេស១០នាក់មុនគេបំផុតនៅប្រទេសកម្ពុជាក្រោយពីសម័យរបបខ្មែរក្រហម។ ហើយខ្ញុំបាទចាប់ធ្វើការជាមួយជនរងគ្រោះដោយរបបខ្មែរក្រហមដោយផ្ទាល់ និងជាពិសេសទាក់ទងទៅនឹងជនរងគ្រោះនៅក្នុងមន្ទីរឃុំឃាំងស-២១ហ្នឹង គឺចាប់តាំងពីឆ្នាំ៩០ ចន្លោះ២០០៥ ហើយ២០០៦ រហូតមកដល់ពេលហ្នឹងបាទ។

**ស៖** តើក្រៅពីជនរងគ្រោះនៃស-២១ លោកមានធ្វើការងារផ្នែកសុខភាពផ្លូវចិត្តជាមួយជនរងគ្រោះផ្សេងទៀតដែរឬទេ ដែលជនរងគ្រោះហ្នឹងជាជនរងគ្រោះតាំងពីសម័យខ្មែរក្រហមមក?

[១៣:៤៨:១១]

**ឆ៖** បាទ ខ្ញុំបាទជាពិសេស អង្គការរបស់ខ្ញុំបាទដែលធ្វើការហ្នឹង បានធ្វើការនៅជាមួយនឹងជនរងគ្រោះដោយសម័យខ្មែរក្រហមហ្នឹងយ៉ាងច្រើន។ ជនរងគ្រោះដោយសារការរំលោភ ជនរងគ្រោះ

ដោយធ្វើអំពើទារុណកម្ម ហើយនិងអ្នកជំងឺផ្សេងៗទៀតដែលខ្ញុំបាទផ្ទាល់ ហើយនិងអង្គការរបស់ខ្ញុំបានព្យាបាលជាទូទៅ សុទ្ធតែរងនូវអំពើទារុណកម្ម និងការធ្វើបាប ការប៉ះទង្គិចផ្លូវចិត្តពីសម័យខ្មែរក្រហមទាំងអស់បាទ។

[១៣:៤៨:៤៩]

**សៈ** កាន់តែជាន់ច្បាស់ថែមទៀត តើលោកមានបាន ឬក៏អង្គការរបស់លោកមានធ្វើការជាមួយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី០០២ នេះដែរឬទេ?

**ឆៈ** បាទមាន គឺដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី០១ និង០២ ដែលពួកយើងកំពុងធ្វើការជាមួយរាល់ថ្ងៃ។

**សៈ** នៅក្នុង -- ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាទូទៅនៃសម័យខ្មែរក្រហមនោះ តើលោកអាចជម្រាបអំពីលទ្ធផលដែលលោកបានធ្វើការជាមួយពួកគាត់កន្លងមកថា តើពួកគាត់មានផលប៉ះពាល់អ្វីខ្លះបន្ទាប់ពីអ្វីដែលគាត់បានទទួលរងនូវសម័យខ្មែរក្រហមនោះ?

**ឆៈ** បាទ ខ្ញុំអាចនិយាយថាភាគច្រើននៃជនរងគ្រោះដែលយើងធ្វើការជាមួយ ដែលយើងផ្ដល់សេវាសុខភាពផ្លូវចិត្តហ្នឹង គឺរងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងច្រើន។ ប្រសិនបើយើងមើលតែសំបកក្រៅដូចថាមើលរៀងគាត់ខាងក្រៅ យើងមិនបានពិភាក្សាសួរនាំគាត់ គឺយើងមើលទៅហាក់ដូចជាគាត់ហ្នឹងមានលក្ខណៈធម្មតា។ ប៉ុន្តែនៅពេលដែលយើងចាប់ផ្ដើមសួរអំពីប្រវត្តិរបស់គាត់ឲ្យបានជ្រៅ យើងចាប់ផ្ដើមសួរនាំអំពីការរស់នៅរបស់គាត់នៅក្នុងរបបខ្មែរក្រហម សួរនាំអំពីបងប្អូន នៅពេលនោះយើងចាប់ផ្ដើមដឹងថា គាត់រងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងពីរបប ប៉ុន្តែដោយសារការជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារការលំបាកក្នុងការរស់នៅប្រចាំថ្ងៃ ធ្វើឲ្យគាត់ហ្នឹងអាចមានលក្ខណៈមួយដែលយើងមើលទៅថាគាត់មិនមានការប៉ះពាល់ខាងផ្លូវចិត្ត ដោយសារតែគាត់នៅតែអាចបន្តសកម្មភាពបាន។ អ៊ីចឹងជាសរុបទៅ ខ្ញុំគិតថាគាត់ហ្នឹង -- ភាគច្រើននៃជនរងគ្រោះដែលពួកយើងធ្វើការជាមួយ គឺមានបញ្ហាផ្លូវចិត្តប៉ះទង្គិចផ្លូវចិត្តច្រើន។

[១៣:៥១:០៧]

**សៈ** តើលោកអាចជម្រាបបានទេថា អ្វីខ្លះដែលជាសញ្ញាដែលធ្វើឲ្យយើងឃើញថាពួកគាត់មានការប៉ះទង្គិចផ្នែកផ្លូវចិត្ត?

**ឆ៖** បាទ យើងមានវិធីសាស្ត្រនៅក្នុងការស្រាវជ្រាវ -- នៅក្នុងការកំណត់ ថាគាត់ហ្នឹងអាចមានការប៉ះទង្គិចផ្លូវចិត្ត។ ឧទាហរណ៍ យើងបាននៅក្នុងវិស័យសុខភាពផ្លូវចិត្ត គឺយើងប្រើរង្វាស់សម្រាប់វាស់វែងរកសញ្ញាដែលពួកគាត់មាន។ ហើយជាទូទៅ ក៏យើងសង្កេតឃើញថាគាត់នៅមានការយល់សប្តិច្រើន គាត់នៅមាន -- ខ្ញុំចង់សូមបញ្ជាក់ថា ប្រតិកម្មផ្លូវចិត្តដែលគាត់មានហ្នឹងអាចមានលក្ខណៈជាជំងឺ។ អ្នកខ្លះអាចមានជាជំងឺដែលភាសាអង់គ្លេសថា ប៉ូស្ត្រូម៉ាទិក ស្ត្រេស ឌីហ្សតឌ័រ ឬក៏ ភី.ធី.អេស.ឌី ហ្នឹងអាចមានជាជំងឺបាក់ស្បាត អាចមានជំងឺធ្លាក់ទឹកចិត្ត អាចមានជំងឺថប់អារម្មណ៍ ហើយអ្នកខ្លះទៀតអាចមានជំងឺសង្ស័យ ជំងឺ*ផារ៉ាណយ*(Paranoia) ដែលកើតមកពីការធ្វើទារុណកម្មដ៏ធ្ងន់ធ្ងរ និងការតាមដានទៅលើពួកគាត់ទាំងអស់ហ្នឹង។ ហើយចំពោះរោគសញ្ញាដែលយើងឃើញ ដែលគាត់មានជាប្រចាំនោះគឺការនឹកឃើញឡើងវិញ អំពីរឿងរ៉ាវដែលគាត់ធ្លាប់ជួបប្រទះ។ ជាពិសេសនៅពេលដែលគាត់ហ្នឹងមានដូចថាសញ្ញារំញោចអីមួយចំពោះព្រឹត្តិការណ៍អីមួយដែលស្រដៀងចំពោះអ្វីដែលគាត់ធ្លាប់ជួបប្រទះ ធ្វើឲ្យគាត់រំឭកឡើងវិញនូវរោគសញ្ញាទាំងអស់នោះ។

[១៣:៥២:៥១]

ហើយជួនកាលគាត់យល់សប្តិអាក្រក់ អំពីការដេញសម្លាប់ អំពីការធ្វើបាប អំពីការស្លាប់របស់បងប្អូន ឬក៏យល់សប្តិអំពីឃើញថា បងប្អូនដែលអ្នកស្លាប់ទៅហ្នឹងរស់នៅវេទនា លំបាក ឬក៏រកឃើញថា គាត់រងទារុណកម្មអីផ្សេងៗ។ ហើយបងប្អូនខ្លះទៀតថា យល់សប្តិហាក់ដូចជានៅជាប់នៅក្នុងទ្រុងដែលរើខ្លួនមិនរួចជាដើម។ អ៊ីចឹងសញ្ញាទាំងអស់ហ្នឹងគឺជាសញ្ញាដែលបញ្ជាក់ថា គាត់នៅមានការប៉ះទង្គិចផ្លូវចិត្ត ហើយលក្ខណៈរបស់ហ្នឹងគឺ លក្ខណៈស្រដៀងហ្នឹង *ត្រូម៉ាទិកអ៊ីវិន*។ ព្រឹត្តិការណ៍ដែលគាត់បានជួបប្រទះនៅក្នុងសម័យខ្មែរក្រហម។

**ស៖** អម្បាញ់មិញលោកបានលើកអំពីសញ្ញាណបួនៗយ៉ាង ភី.ធី.អេស.ឌី, ការបាក់ស្បាត ហើយនិងសញ្ញាណពីរផ្សេងទៀតដែលខ្ញុំមិនមែនជាអ្នកជំនាញ មិនចាំទេ។ ថាតើលោកអាចបញ្ជាក់អំពីសញ្ញាណនីមួយៗដែលលោកបាននិយាយហ្នឹង ហើយលក្ខណៈរបស់ជនរងគ្រោះហ្នឹងមានសញ្ញាណរបៀបម៉េចដែលមានសញ្ញាណនីមួយៗហ្នឹង?

[១៣:៥៤:០៦]

**ឆ៖** បាទ ខ្ញុំសូមលើក ភី.ធី.អេស.ឌី មួយ ហើយនិងបាក់ស្បាតមួយចុះ ពីព្រោះ ភី.ធី.អេស.ឌី គឺជាសញ្ញាមួយដែលអ្នកស្រាវជ្រាវជាច្រើនដែលតែងតែលើកយកមកនិយាយថា ប្រជាជនខ្មែរយើងមាន

បញ្ហាផ្លូវចិត្តដោយសារគាត់មាន ភី.ធី.អេស.ឌី – មានវិបត្តិផ្លូវចិត្តក្រោយពីការប៉ះទង្គិច។ ចំពោះសញ្ញារបស់ ភី.ធី.អេស.ឌី ឬក៏វិបត្តិផ្លូវចិត្តក្រោយពីការប៉ះទង្គិចហ្នឹង ខ្ញុំចង់បញ្ជាក់ថា ពួកគាត់ហ្នឹងតែងតែនឹកឃើញឡើងវិញនូវរឿងរ៉ាវដែលកើតឡើង។ ការនឹកឃើញឡើងវិញហ្នឹង អាចនឹកឃើញក្នុងពេលថ្ងៃដែលគាត់តែងមានអារម្មណ៍ថារឿងរ៉ាវហ្នឹងហាក់ដូចជាកំពុងតែកើតឡើង។ ហើយការនឹកឃើញឡើងវិញហ្នឹង ជួនកាលអាចឃើញនៅពេលយប់។ នៅពេលយប់ជាពិសេសនៅពេលគាត់សុបិន សុបិនអាក្រក់ ដែលទាក់ទងទៅនឹងការភ័យខ្លាច ភ័យរន្ធត់យ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍។

ហើយចំណុចសំខាន់ទី២ គឺការជៀសវាង។ គាត់គេចជៀសវាង គឺគាត់ចង់និយាយអំពីរឿងរ៉ាវដែលកើតឡើងទេ គាត់មិនចង់ទៅជួបកន្លែងដែលគាត់ធ្លាប់រងនូវការធ្វើបាប ធ្វើទារុណកម្មនោះទេ ឬក៏គាត់មិនចង់ពិភាក្សាអំពីស្ថានភាពដែលទាក់ទងធ្វើឲ្យគាត់នឹកឃើញឡើងវិញនូវរឿងរ៉ាវដែលគាត់ធ្លាប់ជួបប្រទះហ្នឹងទេ។

[១៣:៥៥:២៩]

ហើយសញ្ញាទី៣ ដែលយើងឃើញច្រើនហ្នឹង គឺជាសញ្ញាដែលទាក់ទងនឹងរាងកាយ គឺទន្ទឹមនឹងការគេចវេះ ទន្ទឹមនឹងការយល់សប្តិអាក្រក់ គាត់ញ័រទ្រូងច្រើន ដូចគាត់ចប់ដង្ហើម គាត់ត្រជាក់ដៃត្រជាក់ជើង គាត់មានលក្ខណៈភ្ញាក់ៗ ដូចថាមានរំញោចអីបន្តិចបន្តួច ធ្វើឲ្យគាត់នោះភ្ញាក់នឹកឃើញទៅដល់រឿងរ៉ាវដែលគាត់ធ្លាប់កើតហ្នឹង។ ហើយទន្ទឹមនឹងធ្វើឲ្យគាត់គេងមិនលក់ គាត់ឈឺក្បាល គាត់ឈឺចុកចាប់ដៃជើង គាត់តានតឹងនៅក្នុងសាច់ដុំអីជាដើម។ បាទ ហ្នឹងគឺជាសញ្ញាដែលទាក់ទងទៅនឹង ភី.ធី.អេស.ឌី។ ប៉ុន្តែខ្ញុំបាទបានធ្វើការស្រាវជ្រាវមួយ ពីព្រោះ ភី.ធី.អេស.ឌី គឺជាសញ្ញាដែល -- ជាជំងឺដែលបង្កើតដោយប្រទេស ដោយអ្នកជំនាញនៅលោកខាងលិច។ ហើយចំពោះប្រទេសខ្មែរយើង ខ្ញុំគិតថាលក្ខណៈប៉ះទង្គិចផ្លូវចិត្តហ្នឹង មានលក្ខណៈខុសដោយឡែកខ្លះ ដោយសារទាក់ទងទៅនឹងវប្បធម៌របស់យើង។

[១៣:៥៦:២៤]

ខ្ញុំលើកឧទាហរណ៍ថា បងប្អូនយើងគាត់មានលក្ខណៈដូចថា វង្វេង បន្ថែមនឹងរោគសញ្ញាដែលមាន ភី.ធី.អេស.ឌី ខ្ញុំរៀបរាប់ខាងលើ។ សញ្ញារបស់គាត់ដូចជា ដូចថាគាត់មិនហ៊ានប្រឈមមុខទេ ក្រោយពីប៉ះទង្គិចផ្លូវចិត្ត។ គាត់មិនមានគំនិតផ្តួចផ្តើម គាត់មិនអាចធ្វើការសម្រេចចិត្ត គាត់ចុះញ៉មគេព្រោះថាសម័យហ្នឹង គាត់រងនូវការធ្វើទារុណកម្ម ហើយយើងបានដឹងហើយថា នៅសម័យខ្មែរក្រហម

ហ្នឹង គឺខ្មែរក្រហមបានប្រើពាក្យថា "ដាំដើមគរ"។ អ៊ីចឹងសញ្ញាវាអាចជាសញ្ញាមួយនៃការប៉ះទង្គិចផ្លូវចិត្ត ជា*ត្រូម៉ា*(Trauma) បែបអ្នកដែលស្របតាមលក្ខណៈវប្បធម៌កម្ពុជាយើងជាង។ គាត់មិនទុកចិត្តខ្លួនឯង គាត់រាងចាល ដូចថាបងប្អូនហ្នឹងគាត់រៀងចាល់ គាត់ចុះត្រចៀកចំណាំហើយ គាត់លែងចង់ធ្វើអីហើយ គាត់ខ្លាច គាត់បង់បាត់នូវការអាណិតអាសូរ ហើយនិងទំនាក់ទំនងជាមួយអ្នកដទៃ។ អ៊ីចឹងសញ្ញាទាំងអស់ហ្នឹង គឺជាសញ្ញាដែលយើងអាចមើលឃើញបន្ថែមពីសញ្ញា ភី.ធី.អេស.ឌី ដែលមាននៅក្នុងការរៀបរាប់របស់ប្រទេសលោកខាងលិច។

[១៣:៥៧:៣៧]

ហើយទន្ទឹមនឹងក៏យើងឃើញមានជំងឺធ្លាក់ទឹកចិត្ត។ ធ្លាក់ទឹកចិត្ត ដូចថាគាត់អស់សង្ឃឹមចំពោះអនាគត ពីព្រោះគាត់បានបាត់បង់ច្រើនណាស់ពីសម័យខ្មែរក្រហមហ្នឹង។ ការបាត់បង់ហ្នឹង ធ្វើឱ្យគាត់ហ្នឹង ដូចជាបាត់បង់ផ្ទះសម្បែង នៅពេលដែលគាត់ចេញ គេជម្លៀសចេញពីផ្ទះ ចេញពីភូមិដ្ឋាន ត្រឡប់មកវិញ មិនមានអី។ ត្រឡប់មកវិញមិនបានជួបបងប្អូន ពីព្រោះបងប្អូនត្រូវគេសម្លាប់។ ត្រឡប់មកវិញបាត់បង់នូវឱកាសផ្សេងៗ។ អ៊ីចឹងសញ្ញាធ្លាក់ទឹកចិត្តហ្នឹងដែលយើងអាចឃើញ ជួនកាលគាត់ឈានរហូតដល់ចង់សម្លាប់ខ្លួន ឬក៏សម្លាប់ខ្លួនទៀត។ បាទ អ៊ីចឹងទាំងអស់នេះ គឺជារោគសញ្ញាដែលខ្ញុំ -- ដែលលោកមេធាវីបានសួរ។

**ស៖** ចុះចំណែករោគសញ្ញា ផារ៉ាណូយ៉ា អាហ្នឹងយ៉ាងម៉េចវិញ?

**ឆ៖** រោគសញ្ញានេះមិនសូវឃើញទេ។ ប៉ុន្តែឃើញមានអ្នកជំងឺខ្លះដែលខ្ញុំបានជួបប្រទះ ដោយសារការដែលគាត់ត្រូវធ្វើទារុណកម្ម។ ចោទប្រកាន់ថា ជាគិញសម្ងាត់។ ចោទប្រកាន់ថា ជានេះជានោះជាដើមហ្នឹង។ អ៊ីចឹងហើយបូករួមនឹងការទារុណកម្មអីហ្នឹង នៅពេលដែលគាត់ចេញពីមន្ទីរឃុំឃាំងធ្វើឱ្យគាត់មានលក្ខណៈភ័យ ហើយគាត់សង្ស័យ គាត់សង្ស័យខ្លាចគេតាមដានគាត់។ សង្ស័យថាគេហ្នឹងមកតាមសម្លាប់គាត់ ឬក៏ជាគិញណាមួយមកតាមដានគាត់ជាដើម។ ហើយយើងជួបប្រទះម្តងម្កាលចំពោះអ្នកជំងឺដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ បាទ។

[១៣:៥៩:១៤]

**ស៖** បាទ សញ្ញាណទាំងអស់នេះ តើលោកអាចជម្រាបបានទេ ពី ក្រោយពីរបបខ្មែរក្រហម ឬក៏ក្រោយពីពេលដែលគាត់ទទួលរងនូវអង្គហេតុ ឬក៏ហេតុការណ៍ដែលធ្វើឱ្យប៉ះដល់ផ្លូវចិត្តរបស់គាត់រហូតមកដល់ឥឡូវនេះ ថាតើជនរងគ្រោះទាំងអស់នោះមានស្ថានភាពប៉ះពាល់ផ្នែកផ្លូវចិត្តរបស់គាត់

ប្រែប្រួលយ៉ាងណាខ្លះ?

**ឆ៖** ខ្ញុំប្រហែលជាមិនយល់សំណួររបស់លោកមេធាវី។ សូមបញ្ជាក់ម្ដងទៀតបាទ។

**ស៖** លោកបានមានប្រសាសន៍ថា ជនរងគ្រោះនៃសម័យខ្មែរក្រហមទទួលរងនៅផលប៉ះពាល់នៅផ្នែកផ្លូវចិត្ត តាំងពីពេលដែលគាត់ទទួលរងអង្គហេតុដែលនាំឲ្យប៉ះពាល់ផ្លូវចិត្តរបស់គាត់ពីដំបូងរហូតមកដល់បច្ចុប្បន្ននេះ ថាតើការសិក្សារបស់លោកបានសង្កេតឃើញថា ការប៉ះពាល់ផ្នែកផ្លូវចិត្តហ្នឹងមានការប្រែប្រួលយ៉ាងណា? ពីមុនខ្លាំង ហើយឥឡូវខ្សោយ ឬក៏បាត់ការបាត់ ការប៉ះពាល់ផ្លូវចិត្តហ្នឹងវាបាត់លែងមានទៅហើយ?

[១៤:០០:៤០]

**ឆ៖** បាទ សូមអរគុណចំពោះការបញ្ជាក់នៅសំណួរឡើងវិញ។ ខ្ញុំបាទសូមបញ្ជាក់ថា ប្រសិនបើពួកគាត់មិនទទួលនូវការព្យាបាល មិនទទួលនូវសេវាគាំទ្រ មិនទទួលនូវការផ្ដល់ប្រឹក្សាអីផ្សេងៗទេ សញ្ញាហ្នឹងមិនទាន់បាត់ទៅណាទេ។ យើងមើលទៅដូចខ្ញុំជម្រាបពីមុន មើលទៅហាក់គាត់ដូចជាមិនលក្ខណៈបញ្ហាអី ព្រោះគាត់មានការងារធម្មតា ប៉ុន្តែសញ្ញាហ្នឹងអាចនឹងកើតមានប្រសិនបើមានការព្រឹត្តិការណ៍ណាមួយអាចរំញោចឲ្យគាត់ហ្នឹងនឹកឃើញឡើងវិញ សញ្ញាហ្នឹងអាចនឹងឃើញឡើងភ្លាម។ អ៊ីចឹងសញ្ញាហ្នឹងមិនទាន់បាត់ទៅណាទេ ចំណែកឯអ្នកទទួលបានការព្យាបាល យើងឃើញថាមានភាពប្រសើរបាទ។ ប៉ុន្តែការព្យាបាលនេះ គឺទាមទាររយៈពេលយូរបាទ ហើយទាមទារការចូលរួមគ្រប់ផ្នែកទាំងអស់ មិនត្រឹមតែវិស័យសុខភាពផ្លូវចិត្តហ្នឹងទេ ការគាំទ្រទាំងពីខាងផ្លូវច្បាប់ ការគាំទ្រទាំងពីសិទ្ធិការគាំទ្រតាំងពីលើកកម្ពស់ជីវភាពអីជាដើម ដើម្បីឲ្យគាត់ហ្នឹងអាចជាសះស្បើយក្នុងរយៈពេលយូរអង្វែង។

[១៤:០១:៥៧]

**ស៖** យើងវិលមក -- ដោយឡែកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី០០២ វិញ ថាតើទិដ្ឋភាពដែលយើងបានពិភាក្សាគ្នាសម្រាប់ជនរងគ្រោះទូទៅហ្នឹង អំពីការឈឺចាប់ផ្នែកផ្លូវចិត្តរបស់គាត់ មានដូចគ្នាសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី០០២ ដែលលោកបានធ្វើការជាមួយដែរឬទេ?

**ឆ៖** បាទ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ ដោយខ្ញុំមិនប្រាកដថា តើសាក្សីអ្នកជំនាញនេះដឹងអំពីអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មឬក៏អត់ ទោះបីថាគាត់ធ្លាប់ដឹងឬក៏ធ្លាប់សាកសួរ ធ្លាប់ស៊ើបអង្កេតក៏ដោយ ក៏អ្នកជំនាញនេះគាត់មិនអាចនិយាយអ្វីពាក់ព័ន្ធទៅនឹងការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលយើងបានស្តាប់នេះ និងសប្តាហ៍កន្លងមក។ ដូច្នេះខ្ញុំគិតថាប្រសិនបើគាត់ -- ប្រសិនបើមិនមែនជាការទាយស្មានទេ គាត់ប្រហែលជាមិនអាចនិយាយអ្វីឲ្យបានទេនៅពេលនេះ។

[១៤:០៣:២៦]

**លោក ពេជ អង្គ៖**

សូមអនុញ្ញាតលោកប្រធាន។ អ្នកជំនាញគាត់ជាអ្នកសិក្សាទៅលើការប៉ះពាល់ផ្នែកផ្លូវចិត្តនៃជនរងគ្រោះសម័យខ្មែរក្រហម ហើយលោកក៏មានការសិក្សាពាក់ព័ន្ធទៅនឹងជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ដូច្នេះលោកមានសមត្ថភាពពេញលេញនៅក្នុងការដឹង ហើយនិងវាយតម្លៃអំពីអ្វីដែលជាផលប៉ះពាល់ផ្នែកផ្លូវចិត្តសម្រាប់ទៅដល់ជនរងគ្រោះ ក៏ដូចជា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី០០២ នេះ។ ដូច្នេះ ខ្ញុំគិតថាសំណួរដែលខ្ញុំបានលើកនេះ គឺជាសំណួរដែលសមស្របសម្រាប់អ្នកជំនាញនេះ។ ជាពិសេសទៅទៀត ដោយសារលោក ឈឹម សុធារ៉ា ជាអ្នកជំនាញគាត់មានលទ្ធភាពនៅក្នុងការវាយតម្លៃអំពីផលប៉ះពាល់នេះ។ បាទ សូមលោកប្រធានអនុញ្ញាតឲ្យអ្នកជំនាញឆ្លើយសំណួរនេះ។ សូមអរគុណលោកប្រធាន។

[១៤:០៤:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះខ្ញុំកត់សម្គាល់ឃើញថា អ្នកជំនាញបាននិយាយថាគាត់មិនត្រឹមតែធ្វើការជាមួយដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០១ទេ គឺថែមទាំងសំណុំរឿង០០២

ទៀតផង។ ដូច្នេះសំណួរនេះគឺជាសំណួរសមស្របហើយ ពីព្រោះគាត់បានធ្វើការជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន។ គាត់មិនបញ្ជាក់ថាអ្នកណាខ្លះទេ ក៏ប៉ុន្តែខ្ញុំគិតថាយើងគួរតែផ្ដល់ឱកាសឲ្យគាត់ដើម្បីឲ្យគាត់បញ្ជាក់ឲ្យបានច្បាស់ ថាតើគាត់មានការសន្និដ្ឋានអ្វីខ្លះ បន្ទាប់ពីគាត់បានធ្វើការជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនហើយនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបបន្តិច ដោយសារនេះជាបញ្ហាដែលមានភាពរសើបខ្លាំង ព្រោះថាវាទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ព្រោះខ្ញុំមិនប្រាកដថា តើគួរតែពិភាក្សាអំពីប្រវត្តិផ្នែកវេជ្ជសាស្ត្ររបស់ដើមបណ្ដឹងរដ្ឋប្បវេណីឬក៏អត់? តើយើងគួរពិភាក្សាអត់នៅពេលនេះ?

[១៤:០៥:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៩:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍ ដើម្បីសម្រេចលើសេចក្ដីជំទាស់របស់មេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ទៅលើសំណួរចុងក្រោយដែលធ្វើឡើងដោយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំពោះអ្នកជំនាញ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន។

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គួរដាក់ទៅអ្នកជំនាញ គួរចោទសំណួរទៅអ្នកជំនាញអំពីបទពិសោធន៍នៃការភ័យខ្លាច អំពីការប៉ះទង្គិចផ្លូវចិត្ត ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានពណ៌នានៅក្នុងតុលាការ ហើយសូមឲ្យអ្នកជំនាញបកស្រាយ។

[១៤:១០:០០]

នេះគឺជាការ -- ប្រសិនបើធ្វើដូច្នេះមែន គឺថាយើងនឹងបដិសេធនូវការជំទាស់ ប៉ុន្តែលោកមិនបានបញ្ជាក់ថាតើអ្នកជំនាញគាត់បានដឹងអំពីការប៉ះទង្គិចផ្លូវចិត្តជាក់ស្ដែង ឬក៏វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចជាក់ស្ដែងណាមួយដែលបានបង្ហាញនៅក្នុងតុលាការនោះឡើយ។ ប្រសិនបើធ្វើដូច្នេះគឺថាអ្នកជំនាញ

គាត់មិនអាចលើកយកអំពីបទពិសោធន៍របស់គាត់ជាអ្នកជំនាញយកមកនិយាយអំពីបុគ្គលណាម្នាក់ជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ដូច្នេះលោកមេធាវី លោកសហមេធាវីនាំមុខគួរតែលើកយកនូវករណីជាក់ស្តែងណាមួយហើយឱ្យអ្នកជំនាញគាត់បរិយាយអំពីរោគសញ្ញា ឬក៏រោគវិនិច្ឆ័យរបស់អ្នកដើមបណ្តឹងរដ្ឋប្បវេណីនោះ។ គឺថាយើងមិនចាំបាច់លើកយកច្រើនទេ គ្រាន់តែលើកយកឧទាហរណ៍ពីរបីមកបង្ហាញគឺវាគ្រប់គ្រាន់ហើយ។ តើខ្ញុំបញ្ជាក់បែបនេះលោកសហមេធាវីនាំមុខច្បាស់ដែរឬទេ?

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកស្រីចៅក្រមដែលបានបញ្ជាក់ ខ្ញុំបានយល់ច្បាស់អំពីបញ្ហានេះ។ ហើយតាមការពិតសហការីរបស់ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត គាត់នឹងលើកអំពីបញ្ហានេះជាក់លាក់។ ដូច្នេះហើយបានជាខ្ញុំមិនបានលើក ខ្ញុំលើកដែលមានលក្ខណៈជាទូទៅច្រើនជាង។ ហើយដូច្នេះខ្ញុំសូមអនុញ្ញាតបន្តសំណួរដែលមានលក្ខណៈជាក់លាក់ជាងមុន។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកអ្នកជំនាញ តើលោកមានបានពិនិត្យអំពី ឬក៏តាមដានដោយផ្ទាល់ ឬក៏មិនផ្ទាល់អំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលសប្តាហ៍នេះ ឬក៏សប្តាហ៍មុន ឬក៏មុនៗហ្នឹងទៀតដែលគាត់បាននិយាយអំពីផលប៉ះពាល់ទៅលើផ្នែកផ្លូវចិត្តរបស់គាត់។ តើលោកបានពិនិត្យ ឬក៏បានឃើញអំពីការផ្តល់សក្ខីកម្មនេះដែរឬទេ?

[១៤:១២:៣៥]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** ខ្ញុំបាទមិនបានឃើញដោយផ្ទាល់នូវសក្ខីកម្មនេះទេ ពីព្រោះក្នុងរយៈពេលប៉ុន្មានអាទិត្យនេះខ្ញុំបានធ្វើបេសកកម្មនៅបរទេស។ ប៉ុន្តែខ្ញុំបាទសូមបញ្ជាក់ថា មានករណីរបស់ដើមបណ្តឹង០០២ខ្លះដែរដែលបានអង្គការខ្ញុំបាទបានធ្វើការជាមួយ។ ជាឧទាហរណ៍ដូចជាស្ត្រី ជាពិសេសគាត់ដែលត្រូវបានគេធ្វើបាបរំលោភនៅក្នុងសម័យខ្មែរក្រហម ដែលមិនត្រឹមតែជាការរំលោភទេ ថែមទាំងជាការធ្វើទារុណកម្ម។ ប្រវត្តិរបស់គាត់នេះគឺមានលក្ខណៈឈឺចាប់ហើយដែលគាត់មិនដែលបាននិយាយចេញចំពោះរឿងរ៉ាវដែលគាត់បានកើតទេ។ ពីព្រោះការនិយាយចេញនូវរឿងរ៉ាវនេះគឺវាមានលក្ខណៈមួយដែលឈឺចាប់ណាស់ចំពោះរូបគាត់ផ្ទាល់។ ជាពិសេសវាជាការលំបាកទៀតសម្រាប់គាត់ នៅពេលដែលគាត់និយាយចេញមកហើយមិនមានអ្នកជួយគាំទ្រ។ អ៊ីចឹងទេគាត់ក៏បានទទួលសេវាពីខាងយើងហើយ។ យើងឃើញ

ថាសញ្ញារបស់គាត់ហ្នឹងគឺមានលក្ខណៈដូចខ្ញុំបានរៀបរាប់ពីមុន គឺគេចវេះមិនចង់និយាយអំពីរឿងរ៉ាវដែលគាត់កើតមានទេ។ គាត់បានមានលក្ខណៈមួយដែលថាអស់សង្ឃឹមចំពោះអនាគត ធ្លាក់ទឹកចិត្ត ហើយគាត់តែងតែយល់សប្តិអាក្រក់អំពីរឿងរ៉ាវដែលកើតមាន ហើយគាត់មិនចង់ជួបគេឯង គឺគាត់មានការភ័យខ្លាច ហើយជាពិសេសប្រសិនបើឃើញនូវលក្ខណៈដែលស្រដៀងចំពោះរឿងរ៉ាវដែលគាត់ ដូចជាមនុស្សដែលស្លៀកពាក់ខ្មៅជាឧទាហរណ៍ ធ្វើឲ្យគាត់ហ្នឹងមានការរន្ធត់ខ្លាំងមែនទែន។

[១៤:១៤:៣០]

**សៈ** ខ្ញុំសូមអនុញ្ញាតកាត់លោកតែម្តងទៅ។ ខ្ញុំចង់ចូលទៅករណីមួយៗនៃដើមបណ្តឹងរដ្ឋប្បវេណីដែលបានមកផ្តល់សក្ខីកម្ម។ ខ្ញុំសូមលើកឧទាហរណ៍ដូចជាករណីដើមបណ្តឹងរដ្ឋប្បវេណីពីររូបគឺ ករណីដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល ហើយនិងករណីដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវុត្ថា ដែលគាត់ជាជនរងគ្រោះក្នុងចំណោមអង្គហេតុដែលគាត់រងគ្រោះដទៃទៀត គឺគាត់ត្រូវបានជម្លៀសចេញពីភ្នំពេញ ហើយគាត់បានឃើញសកម្មភាពសាហាវនៅពេលដែលគាត់បានធ្វើដំណើរចេញពីភ្នំពេញត្រូវបានបង្ខំឲ្យចេញពពីភ្នំពេញ ហើយមានទាំងការបង្ខំឲ្យចេញពីផ្ទះ ការបង្ខំឲ្យចេញពីគោលដៅដែលគាត់កំពុងនៅ។ ទិដ្ឋភាពដែលគាត់ឃើញមនុស្សស្លាប់នៅតាមផ្លូវ គាត់ជាន់លើមនុស្សស្លាប់ គាត់ដើរឈឺជើង ហើយគាត់រយៈពេលយូរដែលត្រូវឆ្លង ត្រូវធ្វើដំណើរតាមផ្លូវ។ ខ្ញុំចៀសវាងមិនលើកអំពីអ្វីដែលជាការលំបាក ការឈឺចាប់របស់គាត់ជាលម្អិតទេ។ ពួកគាត់នៅសម័យនោះ គាត់មានអាយុ៩ឆ្នាំ ឬក៏១១ឆ្នាំ។ ថាតើផលប៉ះពាល់នៃការជម្លៀសទៅលើពួកគាត់ដែលជាកុមារនោះ ថាតើមានលក្ខណៈយ៉ាងដូចម្តេចដែរ ហើយផលប៉ះពាល់នេះវាមានអ្វីមានការបន្តមករហូតដល់ឥឡូវយ៉ាងណាដែរ?

[១៤:១៦:២៥]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅលើសំណួរមួយនេះ វាប្រហែលជារឿងមួយផលខុសប្រសិនបើអ្នកជំនាញគាត់និយាយគាត់និយាយអំពីការប៉ះទង្គិចផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ណាមួយ។ ហើយគាត់អាចថាសួរថា តើបទពិសោធន៍ការប៉ះទង្គិចផ្លូវចិត្តហ្នឹង វាត្រូវជាមួយបទ

ពិសោធន៍ ឬក៏អត់នោះទេ? ប៉ុន្តែអ្វីដែលនិយាយទាក់ទងទៅនឹងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់គាត់ឆ្លងកាត់ គឺវាហាក់ដូចជាមិនជាការជួយទៅដល់សាក្សីគាត់ឆ្លើយទៅលើបញ្ហាទាំងអស់នេះទេ។ ព្រោះថាពេលនោះ គឺអាចនឹងមានរបាយការណ៍បង្ហាញថាមានតែ១០ ទៅ១៥ភាគរយនៃជនរងគ្រោះដែលទទួលរងនូវវិបត្តផ្លូវចិត្តក្រោយការប៉ះទង្គិចនោះទេ។ ដូច្នេះហើយខ្ញុំគិតថាសហមេធាវីនាំមុខ គួរពណ៌នាអំពីការប៉ះទង្គិច ហើយបន្ទាប់មកឲ្យអ្នកជំនាញធ្វើការបកស្រាយ ថាតើការប៉ះទង្គិចផ្លូវចិត្តហ្នឹងវាស្ថិតនៅក្នុងក្រុមណា ឬក៏ប្រភេទណា ហើយថាតើព្យសនកម្មបែបណាដែលគេបានទទួល ឬក៏មានលក្ខណៈបែបណា។ ខ្ញុំគិតថាអ៊ីចឹងប្រសើរជាង។

[១៤:១៧:៥៣]

**លោក ពេជ អង្គ៖**

ពិនិត្យទៅលើអ្វីដែលលោក កូប៉េ បានលើកចុងក្រោយនេះ គឺចូលក្នុងករណីដែលខ្ញុំបានធ្វើនេះហើយ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា គឺមានមូលហេតុត្រឹមត្រូវនិងសមស្របបំផុត។ ដូច្នេះ អ្នកជំនាញមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះទេ។ មេធាវីគប្បីគិតឡើងវិញ ហើយរៀបចំនូវសំណួរឲ្យបានសមរម្យ សមស្របទៅតាមស្ថានភាពនៃការតាំងសំណួរចំពោះអ្នកជំនាញរូបនេះ។

អង្គជំនុំជម្រះសូមរំឮកថា អ្នកជំនាញរូបនេះ គាត់មិនបានមកអង្គុយស្តាប់ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ស្ថានភាពព្យសកម្ម និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យគាត់ថ្លែងរៀបរាប់នៅក្នុងអំឡុងពេលសប្តាហ៍កន្លងទៅនោះទេ ឬក៏ដើមសប្តាហ៍នេះទេ។ អាចលោកអាចមានការគិតពីបញ្ហានេះឲ្យបានជាក់ច្បាស់។ បើពុំដូច្នេះទេ គឺពេលវេលារបស់លោកនឹងអាចអស់ដោយមូលហេតុការរៀបចំនូវសំណួររបស់លោកមិនសមស្រប។

[១៤:១៩:១៧]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តាមការសិក្សារបស់លោកអំពីប្រភេទ អំពីដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាជនរងគ្រោះ តើ

ប្រភេទនៃ -- តើជនរងគ្រោះដែលជាកុមារ ដែលរងនូវការជម្លៀសនោះ គាត់មានផលប៉ះពាល់ផ្នែកផ្លូវចិត្តយ៉ាងដូចម្ដេចខ្លះ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទសូមអរគុណ។ ខ្ញុំបាទសូមបញ្ជាក់ថា ក្នុងការជម្លៀសចេញពីកន្លែងដែលគាត់ធ្លាប់រស់នៅ ចេញពីទីលំនៅ គឺជាព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្តមួយដែលគ្រប់ៗគ្នាបានជួបប្រទះទាំងមនុស្សចាស់ ក៏ដូចជាកូនក្មេង។ អ៊ីចឹងយើងឃើញថាប្រសិនបើការប៉ះទង្គិចហ្នឹងវាមានលើមនុស្សចាស់ ប្រភេទនៃ*ត្រូម៉ា* ការប៉ះទង្គិចហ្នឹងវាធ្វើឲ្យគាត់ហ្នឹងមិនអាចទប់ទល់ដោះស្រាយចំពោះរឿងរ៉ាវដែលកើតមានទេ។ ហ្នឹងចំពោះមនុស្សចាស់ បើសិនជាកូនក្មេង ព្រឹត្តិការណ៍ហ្នឹងវាហាក់ដូចជារឹតតែធ្ងន់ធ្ងរទៀត ពីព្រោះវាធ្វើឲ្យគាត់ហ្នឹងឃ្លាតឆ្ងាយពីទីកន្លែងដែលគាត់រស់នៅ ពីព្រោះថានៅពេលដែលយើងរស់នៅកន្លែងមួយនៅជាមួយក្រុមគ្រួសារមួយ វាមានចំណងផ្លូវចិត្តមួយដែលៗកើតមាន គេហៅថា “*អាថាច់មិន*” ដែលកើតមាន។ អ៊ីចឹងនៅពេលដែលជម្លៀសចេញហ្នឹងវាអាចកាត់ផ្ដាច់ពីចំណងទាំងនោះ ធ្វើឲ្យគាត់ហ្នឹងវាអាចបាត់បង់នូវឱកាសនៅក្នុង ឧទាហរណ៍ថាការរកទទួលទាន នៅពេលដែលគេជម្លៀសទៅដល់កន្លែងហើយ គឺត្រូវធ្វើដំណើរដោយថ្មើរជើង ដោយការលំបាកសព្វបែបយ៉ាង ទៅដល់កន្លែងថ្មីដោយមិនមានជម្រក ហើយត្រូវបាន ជួនកាលត្រូវធ្វើទារុណកម្ម ហើយបង្ខំឲ្យធ្វើការយ៉ាងលំបាក ហើយបាត់បង់នូវ--មានការឈឺស្កាត់ដោយមិនមានការថែទាំ។ ទាំងអស់ហ្នឹងគឺជាការប៉ះទង្គិចផ្លូវចិត្តដែលគាត់បានទទួលជួបប្រទះ។

[១៤:២១:២៨]

ចំពោះកុមារការប៉ះទង្គិចផ្លូវចិត្តនេះគឺធ្វើឲ្យចក្ខុវិស័យរបស់គាត់ទៅអនាគតហ្នឹងគឺមិនបានច្បាស់ មិនបានភ្លឺថ្លាដូចមនុស្សពេញវ័យ ឬក៏មនុស្សចាស់ទេ។ អ៊ីចឹងដោយសារការប៉ះទង្គិចហ្នឹង ផ្លូវចិត្តហ្នឹងទៀតក៏អាចឲ្យបណ្ដាលឲ្យមាននូវវិបត្តិនៅក្នុងការលូតលាស់ខាងផ្នែកផ្លូវកាយ និងផ្លូវចិត្តដែរ។ វិបត្តិក្នុងផ្នែកលូតលាស់ហ្នឹងវាអាចមានផលវិបាកធ្ងន់ទៅទៀតទៅថ្ងៃអនាគត ជាពិសេសទាក់ទងទៅនឹងការរស់នៅ ការទំនាក់ទំនង។ អ៊ីចឹងគាត់អាចមានជំងឺ ភី.ធី.អេស.ឌី ដូចបាក់ស្បាតដូចមនុស្សចាស់ដែរ។ គាត់អាចមានជំងឺវិបត្តិអាកប្បកិរិយា គាត់អាចមានបញ្ហាគេហៅថា *អេនទីសូស្យល* – គឺវិបត្តិដូចថាជាដែលកាច ដែលចូលចិត្តធ្វើបាបគេឯងអ៊ីចឹងទៅ។ ហើយយើងស្រមៃមើលតទៅទៀតថា ពួកគាត់ជាកុមារនៅសម័យខ្មែរក្រហម ប៉ុន្តែនៅពេលឥឡូវគាត់ជាឪពុកម្ដាយរបស់គេហើយ គាត់មានកូនចៅហើយ។

ហើយយើងមើលថា អ៊ីចឹងតើនៅពេលដែលគាត់មានបញ្ហាផ្លូវចិត្តខ្លួនគាត់ពីកុមារ ហើយគាត់ត្រូវបានគេជម្លៀសទៅកន្លែងផ្សេងដែលគេដាក់នៅក្នុងមណ្ឌលកុមារធ្វើការ ធ្វើបាប ធ្វើទារុណកម្មសព្វបែបយ៉ាងហ្នឹង។ អ៊ីចឹងការដែលគាត់ -- សព្វថ្ងៃគាត់អាចចិញ្ចឹមបីបាច់កូននៅក្នុងលក្ខណៈដែលគាត់ត្រូវបានចិញ្ចឹម។ អ៊ីចឹងអាទាំងអស់ហ្នឹង វានឹងប៉ះពាល់បន្តទៀតទៅដល់កូនចៅគាត់ជំនាន់ក្រោយទៀត។

[១៤:២៣:០៦]

**ស៖** ចុះករណីដែលកុមារគាត់រងនូវការជម្លៀសដូចគ្នា ហើយក៏បាត់បង់ឪពុកម្ដាយ បងប្អូនសាច់ញាតិ ហើយនៅកំព្រាតែម្ដង ថាតើមានលក្ខណៈដូចគ្នា ដូចអ្វីដែលលោកបានលើកដែរឬទេ ហើយបើមានអ្វីដែលខុសគ្នា សូមលោកបញ្ជាក់ផង?

**ឆ៖** បាទ ជាទូទៅលក្ខណៈជារួមការប៉ះទង្គិចផ្លូវចិត្តមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែចំណុចមួយដែលខុសគ្នាទៅលើកុមារដែលបាត់បង់ឪពុកម្ដាយនោះ គឺមានលក្ខណៈធ្ងន់ធ្ងរ ពីព្រោះនៅពេលត្រឡប់មកវិញពីរបបខ្មែរក្រហម ពួកគាត់មិនមានអ្នកទីពឹងទេ ពួកគាត់បាត់បង់នូវការគាំទ្រខាងផ្នែកសង្គម។ ហើយយើងបានឃើញថាមានការសិក្សាហើយថា អ្នកដែលទទួលបាននូវការគាំទ្រខាងផ្នែកសង្គមច្រើននៅក្នុងសម័យខ្មែរក្រហម ឬក៏ក្រោយសម័យខ្មែរក្រហមក្ដីហ្នឹង គឺគាត់មានលក្ខណៈផ្លូវចិត្តប្រសើរជាងអ្នកដែលអត់មានការគាំទ្រខាងផ្នែកសង្គមគ្រួសារជាងគេ។ បាទ អ៊ីចឹងខ្ញុំចង់បញ្ជាក់ដែរថា គាត់មានលក្ខណៈទូទៅដូចគ្នាហើយ ប៉ុន្តែក៏លក្ខណៈដោយឡែកលើសពីអ្នកដែលមានឪពុកម្ដាយដែរ។

**ស៖** ខ្ញុំលើកនេះដោយសារមានដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ចូលក្នុងករណីហ្នឹង។ ថាតើ-- ហើយចង់សួរបញ្ជាក់បន្តិច ថាតើគាត់អាចមានអារម្មណ៍នៅក្នុងចិត្តរបស់គាត់ថា ហេតុអ្វីគឺគាត់ខុសពីគេ គេកើតមកមានម៉ែឪ ហើយគាត់គ្មានម៉ែឪ។ តើអារម្មណ៍ហ្នឹងអាចនឹងមានផល -- អាចមានជាឥរិយាបថយ៉ាងណាខ្លះដែលចេញពីអារម្មណ៍របៀបនេះ?

[១៤:២៥:០៩]

**ឆ៖** បាទ យើងឃើញថា គាត់មានវិប្បដិសារីច្រើន ហើយគាត់មានការតូចចិត្តចំពោះខ្លួនឯងច្រើន ចំពោះបញ្ហាដែលកើតមានចំពោះគាត់។ អ៊ីចឹងលក្ខណៈទាំងអស់នេះ វាអាចនាំទៅរកការធ្លាក់ទឹកចិត្ត ហើយបើយើងនិយាយជារួមទៅ គឺគាត់អាចជំងឺបញ្ហាផ្លូវចិត្តមួយដែលទាក់ទងទៅនឹង គេហៅថា *ហ្គ្រីហ្វ*– ដូចថាការកាន់មរណទុក្ខអំពីអ្នកជាទីស្រឡាញ់ដែលបានស្លាប់ទៅ។ ហើយយើងមានឃើញការសិក្សាមួយថ្មីៗហ្នឹងដែរ ដោយមជ្ឈមណ្ឌលប្រឆាំងអំពើទារុណកម្មនៅទីក្រុងបែរឡាំងហ្នឹង គឺយើង

ឃើញថា មានរហូតទៅដល់១៤ភាគរយនៃអ្នកដែលបានចូលរួមក្នុងសិក្សា នៅប្រហែលជា៧០០នាក់ គឺមានបញ្ហា*ហ្គ្រីហ្វ* ហ្នឹង គឺគាត់តែងតែនឹកឃើញអំពីមនុស្សឪពុកម្ដាយ គាត់តែងតែតូចចិត្តអំពីរឿងរ៉ាវដែលកើតឡើង ដោយសារគាត់បាត់បង់ឪពុកម្ដាយ តូចចិត្តដោយសារគាត់បាត់បង់ឱកាសមិនមានអ្នកគាំទ្រ ហើយបញ្ហាហ្នឹងទាក់ទងទៅនឹងវិប្បដិសារី និងការធ្លាក់ទឹកចិត្តជាប់ជាប្រចាំ។

**សៈ** ខ្ញុំនៅពីរសំណួរទៀត បន្ទាប់មកខ្ញុំនឹងផ្ទេរសហការីរបស់ខ្ញុំ។ ចំពោះអ្នកដែលត្រូវបានជម្លៀសហើយទៅនៅមូលដ្ឋាន ហើយបន្ទាប់មកកូនរបស់គាត់ចេះតែស្លាប់ គាត់មានកូនច្រើន ហើយកូនរបស់គាត់ចេះតែស្លាប់បណ្ដើរៗ ដោយសារមានជំងឺ ឬក៏ថាដោយសារគេសម្លាប់។ ថាតើការប៉ះពាល់ផ្លូវចិត្តរបស់ម្ដាយដែលទទួលរងនូវអង្គហេតុយ៉ាងដូចម្ដេចដែរ តើលោកអាចបញ្ជាក់បានទេ?

[១៤:២៦:៥៨]

**ឆៈ** បាទ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺទាក់ទងទៅនឹងការបាត់បង់។ ចំពោះគាត់ប្រហែលជាបាត់បង់លើសអ្នកដទៃ។ ការបាត់បង់ជាទូទៅបន្ថែមទៅលើទ្រព្យសម្បត្តិ ទៅលើឱកាស ទៅលើអ្វីៗសព្វបែបយ៉ាង គាត់ថែមទាំងបាត់បង់ទៅលើអ្នកជាទីស្រឡាញ់ទៀត។ អ៊ីចឹងការដែលបាត់បង់អ្នកជាទីស្រឡាញ់ហ្នឹង វាអាចមានឥទ្ធិពលអាក្រក់ទៅលើបញ្ហាផ្លូវចិត្ត។ ជួនកាលវាអាចធ្វើឲ្យគាត់មានចំណងផ្លូវចិត្តជាមួយអ្នកដែលស្លាប់ហ្នឹងមិនដាច់ ពីព្រោះកូនជាទីស្រឡាញ់ទាំងអស់ដែលគាត់មានហ្នឹង គឺបានស្លាប់អស់ហើយ ធ្វើឲ្យគាត់អាចនឹងមានអារម្មណ៍ឯកកោ ធ្វើឲ្យគាត់ហ្នឹងអាចមានអារម្មណ៍ធ្លាក់ទឹកចិត្តតែងតែនឹកឃើញជាប្រចាំដែលធ្វើឲ្យគាត់មិនអាច ដូចថាធ្វើអ្វីៗនឹងបានសម្រេច ដោយសារគាត់ហ្នឹងតែងតែមានចំណងជានិច្ចចំពោះអ្នកដែលស្លាប់អ៊ីចឹង។ អ៊ីចឹងអាហ្នឹងវាជាការរំខាននៃជីវិត និងសកម្មភាព និងអារម្មណ៍របស់គាត់ជាប់ជាប្រចាំ បាទ។

**សៈ** សំណួរចុងក្រោយរបស់ខ្ញុំចំពោះប្រជាជនដែលគាត់រងនូវការជម្លៀសដោយបង្ខំចេញ ហើយបន្ទាប់មកពេលដែលទៅដល់មូលដ្ឋាន គាត់រងនូវការរើសអើង ដោយគេនិយាយថាជាអ្នកថ្មី ហើយមានការប្រព្រឹត្តទៅលើពួកគាត់ខុសពីអ្នកដទៃ ដូចជាធ្វើការជាទម្ងន់អីជាដើម ហើយឬក៏គេមិននិយាយជាមួយ ឬក៏គេបង្ខំឲ្យធ្វើការធ្ងន់ធ្ងរជាដើម។ តើមានផលប៉ះពាល់ផ្នែកផ្លូវចិត្តអ្វីខ្លះ ចំពោះជំពូកប្រភេទជនរងគ្រោះបែបនេះ?

[១៤:២៨:៤៧]

**ឆៈ** បាទ ខ្ញុំបាទសូមបញ្ជាក់ថា ការប៉ះពាល់ផ្លូវចិត្តនៅក្នុងសម័យខ្មែរក្រហមហ្នឹងគឺកើតមាន

ចំពោះជាទូទៅស្មើរតែគ្រប់មនុស្សគ្រប់គ្នាៗ ហើយនៅក្នុងសម័យនោះ ដែលគេបែងចែករវាងប្រជាជនចាស់ ហើយនិងប្រជាជនថ្មីហ្នឹង គឺជាស្ថានការណ៍មួយដែលធ្វើឲ្យពួកគាត់ហ្នឹងអាចនឹងរស់នៅក្នុងការភិតភ័យទៀត ពីព្រោះថានៅពេលដែលគេចាត់ទុកថាគាត់ជាប្រជាជនថ្មី។ អ៊ីចឹងគឺជាគោលដៅដែលត្រូវបានគេតាមដាន ជាគោលដៅដែលត្រូវបានគេធ្វើបាប ជាគោលដៅដែលត្រូវបានគេទម្លាក់កំហុស។ អ៊ីចឹងធ្វើឲ្យគាត់ហ្នឹងមានភិតភ័យខ្លាចជាប្រចាំ។ អ៊ីចឹងវាធ្វើឲ្យគាត់ហ្នឹងបាត់បង់នូវ ដូចថាជាអត្តសញ្ញាណដែលយើងជាពលរដ្ឋដូចគ្នា ហើយត្រូវទទួលការបែងចែក ហើយត្រូវទទួលការតាមដាន និងតាមការចាប់កំហុស ដើម្បីរកសម្លាប់ចោល។ អ៊ីចឹងខ្ញុំមានអារម្មណ៍ថា គាត់បាន អាចបាត់បង់នូវអត្តសញ្ញាណ ហើយការបាត់បង់អត្តសញ្ញាណហ្នឹង គឺជាផ្នែកមួយនៃការប៉ះទង្គិចផ្លូវចិត្តណាស់ ពីព្រោះគាត់ត្រូវការ ត្រូវបានគេ ដូចថាផាត់ចេញពីបញ្ជាសង្គមមួយដែលពួកគាត់មិនអាចរស់នៅដោយបានសុខមានសេរីភាព មានសិទ្ធិស្មើគ្នាដូចគេដូចឯងបាន។

[១៤:២៩:៥៨]

**ស៖** សូមបញ្ជាក់បន្តិច អម្បាញ់មិញលោកថាលោកមានអារម្មណ៍ថា តើវាជាការសង្កេតរបស់លោក ឬក៏គ្រាន់ជាអារម្មណ៍ធម្មតារបស់លោកដែលលោកទាយយកតែម្តង?

**ឆ៖** ផ្អែកទៅលើបទពិសោធន៍ ហើយខ្លួនខ្ញុំបាទផ្ទាល់ក៏ជាអ្នកដែលរស់នៅក្នុងសម័យនោះ ហើយដែលត្រូវបានគេបែងចែកលក្ខណៈជាប្រជាជនថ្មី។ ដូច្នេះនេះគឺជាអារម្មណ៍មួយដែលខ្ញុំមាន ហើយខ្ញុំគិតថា ជនរងគ្រោះដទៃទៀតក៏មានអារម្មណ៍ដូចគ្នាហ្នឹងដែរ។

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន ខ្ញុំបញ្ចប់សំណួររបស់ខ្ញុំត្រឹមនេះ ហើយខ្ញុំសូមផ្ទេរវេទិកាជូនសហការីរបស់ខ្ញុំ។ សូមលោកប្រធានអនុញ្ញាត និងសូមអរគុណលោកប្រធាន។

[១៤:៣០:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជម្រាបសួរលោក សុធារ៉ា! ខ្ញុំសួរសំណួរលោកមួយចំនួនដោយផ្អែកទៅលើបទពិសោធន៍វិជ្ជាជីវៈ និងទម្លាប់អនុវត្តន៍របស់លោកជាមួយនឹងជនរងគ្រោះ គឺមិនត្រឹមតែដើមបណ្ដឹងរដ្ឋប្បវេណីទេ គឺជាមួយនឹងជនរងគ្រោះខ្មែរក្រហមជាទូទៅ ដែលលោកបានជួបក្នុងឋានៈជាអ្នកជំងឺរបស់លោក។ ខ្ញុំមានសំណួរសួរបន្តមួយ គឺខ្ញុំចង់ត្រឡប់មកនិយាយអំពីពាក្យដែលលោកបានរៀបរាប់អម្បាញ់មិញ គឺពាក្យថា "បាក់ស្បាត" តើលោកអាចពន្យល់បានទេ ថាតើពាក្យថា "បាក់ស្បាត" នេះមានន័យថាយ៉ាងម៉េចដែរ?

[១៤:៣១:៥១]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ សូមអរគុណ។ ពាក្យថា "បាក់ស្បាត" នេះយើងបកប្រែទៅជាភាសាអង់គ្លេស ខ្ញុំសូមបកថា *ប្រូកខិន ខៅរេជ* (broken courage) បានន័យថា សេចក្ដីក្លាហានរបស់គាត់ហ្នឹងត្រូវបានបាក់។ នៅក្នុងវចនានុក្រមសម្ដេចសង្ឃ ជួន ណាត បាននិយាយថា បាក់ស្បាត ហ្នឹងគឺវាកើតមកពីពាក្យពីរ។ ពាក្យ មួយថា "បាក់" ហើយនិងពាក្យ "ស្បាត"។ "បាក់" ហ្នឹងជាការបាត់បង់ ជាការបាក់បែក ហើយ "ស្បាត" ហ្នឹង គឺជារូបរាង ជាការបាក់បែកនៅរូបរាងដែលមិនអាចត្រឡប់មកភាពដើមវិញ។ ហើយសម្ដេចសង្ឃ ជួន ណាត ក៏បានធ្វើយោងទៅការប៉ះទង្គិចផ្លូវចិត្តដែលគាត់ត្រូវបានបាក់ ហើយនិងដូចថា អារម្មណ៍ផ្លូវចិត្តហ្នឹងត្រូវបានបាត់បង់ ហើយនិងខូចខាតហ្នឹង។ អ៊ីចឹងគឺអាហ្នឹងគឺជាអត្ថន័យជាទូទៅដែលខ្ញុំនិយាយទៅលើពាក្យ "បាក់ស្បាត" ប៉ុន្តែក្នុងផ្នែកចិត្តសាស្ត្រវិញ ពាក្យ "បាក់ស្បាត" ហ្នឹងគឺវាមានន័យជ្រៅជ្រះណាស់សម្រាប់រៀបរាប់អំពីទុកលំបាក អំពីទារុណកម្ម អំពីការឈឺចាប់ផ្សេងៗដែលប្រជាជនកម្ពុជាយើងបានជួបប្រទះនៅក្នុងសម័យខ្មែរក្រហមហ្នឹង។

[១៤:៣៣:២៦]

**ស៖** សូមអរគុណ។ លោកឆ្លើយទៅនឹងសំណួរបន្ទាប់របស់ខ្ញុំរួចមកហើយ គឺថាលោកបានលើកឡើងអំពីរោគសញ្ញានៃការបាក់ស្បាតរបស់ជនរងគ្រោះនេះ។ ឥឡូវខ្ញុំចូលទៅសួរព័ត៌មានលម្អិតអម្បាញ់មិញនេះ លោកនិយាយថា ជនរងគ្រោះមួយចំនួននោះ មិនចង់និយាយអំពីរឿងរ៉ាវដែលគាត់បានជួបប្រទះនៅសម័យខ្មែរក្រហមឡើងវិញទេ។ តើលោកធ្លាប់បានជួបជនរងគ្រោះណាដែលបានប្រាប់លោកថា គាត់មិនចង់និយាយអំពីឧក្រិដ្ឋកម្មប្រាប់កូនចៅរបស់ពួកគាត់ ហើយបើសិនជាមាននោះតើ

លោកអាចបញ្ជាក់បានទេថា មូលហេតុអ្វីបានជាគាត់មិនចង់រំឭកអំពីរឿងរ៉ាវឈឺចាប់ដែលគាត់ធ្លាប់ជួបប្រទះហ្នឹងប្រាប់ដល់កូនចៅរបស់ពួកគាត់នោះ?

[១៤:៣៤:១៤]

**ឆ៖** បាទ សូមអរគុណ។ ជាញឹកញាប់ ជនរងគ្រោះដែលរងនូវការប៉ះទង្គិចផ្លូវចិត្តនុ៎ង ដូចខ្ញុំបានជម្រាបជូន មានសញ្ញាមួយ ដូចសញ្ញាគេចវេះមិនចង់និយាយ មិនចង់ជួប ឬក៏ពិភាក្សាអំពីរឿងរ៉ាវដែលកើតមាន ពីព្រោះការពិភាក្សា ការប្រឈមមុខចំពោះរឿងរ៉ាវនោះវាធ្វើឱ្យគាត់ឈឺចាប់បាទ។ អ៊ីចឹងគឺគាត់អត់ចង់និយាយទេ។ អ៊ីចឹងពីព្រោះ -- ប្រសិនបើគាត់អត់ចង់និយាយហ្នឹងធ្វើឱ្យគាត់ហ្នឹងមានលក្ខណៈធូរស្រាល ធ្វើឱ្យគាត់ហ្នឹងលែងឈឺចាប់។ អ៊ីចឹងៗហើយបានជាគាត់ជាព្យាយាមជៀសវាងរហូតមិនព្រមនិយាយអំពីរឿងរ៉ាវ។ ខ្ញុំបាទសូមបញ្ជាក់ថា ប្រជាជនកម្ពុជាហាក់ដូចជាមានអាសញ្ញាដែលទាក់ទងទៅនឹងការគេចវេះមិនចង់និយាយហ្នឹង គឺច្រើនជាងជនជាតិដទៃ។ តាមការសិក្សារបស់ខ្ញុំយ៉ុង ទាក់ទងទៅនឹងជំងឺផ្លូវចិត្តនៅក្នុងប្រទេសក្រោយសង្គ្រាម គឺយើងឃើញថាប្រជាជនកម្ពុជាមានសញ្ញានៃការគេចវេះហ្នឹងច្រើនជាងជនជាតិដទៃទៀត។ អ៊ីចឹងហើយបានខ្ញុំសង្កេតឃើញជាទូទៅ គឺប្រជាជនយើងមិននិយាយអំពីរឿងខ្មែរក្រហមទេ សូម្បីតែនៅក្នុងក្រុមគ្រួសារក៏គាត់មិនចង់និយាយអំពីរឿងរ៉ាវនោះដែរ។ ហើយទាក់ទងចំពោះអ្នកជំងឺវិញ គឺប្រសិនបើយើងមិនសួរ ប្រសិនបើខ្ញុំសួរអំពីបញ្ហាគឺគាត់មិននិយាយជាដាច់ខាត បាទពីព្រោះវាមានការលំបាក។ ហើយជួនកាលទោះបីជាយើងសួរ ក៏គាត់មិនទាន់និយាយដែរ គឺគាត់ត្រូវការចំណាយពេលវេលាគ្រប់គ្រាន់ ដើម្បីឱ្យគាត់ហ្នឹងសម្រួលអារម្មណ៍រហូតដល់គាត់ហ្នឹងអាចក្លាហានគ្រប់គ្រាន់ ដែលគាត់អាចនិយាយអំពីរឿងរ៉ាវនោះបានបាទ។

[១៤:៣៦:០៣]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ ខ្ញុំចង់ដឹងលម្អិតបន្ថែមទៀត តើជនរងគ្រោះមួយចំនួននោះគាត់មិនចង់តែប្រាប់កូនចៅរបស់គាត់ គឺថាបានន័យថា គឺថាមិនអាចត្រឹមតែប្រាប់កូនចៅរបស់គាត់ទេ។ អ៊ីចឹងលោកអាចពន្យល់បានទេ ថាមូលហេតុអីបានជាគាត់មិនចង់រៀបរាប់រឿងរ៉ាវទាំងអស់នេះប្រាប់កូនចៅរបស់គាត់?

**ឆ៖** បាទ ការដែលគាត់មិនចង់រៀបរាប់អំពីរឿងរ៉ាវហ្នឹង ទី១ ខ្ញុំអាចសន្និដ្ឋានបានថា សញ្ញានៃការប៉ះទង្គិចផ្លូវចិត្តហ្នឹង ធ្វើឱ្យគាត់ហ្នឹងគឺមិនចង់រៀបរាប់។ ហើយសូមបញ្ជាក់ថានៅក្នុងប្រទេសកម្ពុជាយើងហាក់ដូចជាមាន *ខុលឡិចទីវ វ៉យ* មួយដែលថាធ្វើឱ្យគាត់ហ្នឹងមិនចង់និយាយរឿងហ្នឹងក្នុងទូទាំង

ប្រទេស។ ពីព្រោះយើងមើលថា មិនសូវមានប្រជាជនកម្ពុជាជាទូទៅដែលនិយាយរៀបរាប់អំពីបញ្ហាហ្នឹងទេ ហ្នឹងទី១។

[១៤:៣៧:០៨]

ទី២ ខ្ញុំចង់និយាយថា ជួនកាលគាត់អាចមានអារម្មណ៍ថា មិនទាន់*វ៉េឌី*– មិនទាន់ប្រុងប្រៀបគ្រប់គ្រាន់ដែលកូនគាត់ហ្នឹងទទួលនូវព័ត៌មាន និងរឿងរ៉ាវទាំងអស់នោះបាន។ ពីព្រោះគាត់អាចគិតថាវាអាចប៉ះទង្គិចទៅលើកូនគាត់ ឬក៏គាត់អាចយល់ថាកូនគាត់អាចនឹងយល់នូវការកើតឡើងហ្នឹងនៅក្នុងវិធីអ្វីមួយផ្សេង។ អ៊ីចឹងហើយប្រហែលជាអាចធ្វើឲ្យគាត់ហ្នឹងចៀសវាងមិនចង់និយាយអំពីរឿងរ៉ាវទាំងនោះបាន។

**ស៖** សូមអរគុណលោក។ ពាក់ព័ន្ធនឹងគំនិតនៃការមិនចង់និយាយនេះដដែល តើលោកធ្លាប់ជួបជនរងគ្រោះណាដែលគាត់ពន្យល់ប្រាប់លោកថា គាត់បានឃើញអ្នកដែលប្រព្រឹត្តអំពីហិង្សាចំពោះគាត់ ដូច្នេះហើយគាត់មិនអាចនិយាយអំពីអ្វីដែលបានកើតឡើងនោះបានទេ? តើលោកធ្លាប់ជួបអ៊ីចឹងទេ?

[១៤:៣៨:២០]

**ឆ៖** ខ្ញុំមិនដែលជួបជនរងគ្រោះដែលនិយាយថា ឃើញអ្នកដែលប្រព្រឹត្តជនដៃដល់ធ្វើមកលើគាត់ ហើយគាត់មិនប៊ាននិយាយទេ។ ប៉ុន្តែខ្ញុំបានជួបលក្ខណៈជាច្រើនដែលគាត់មិនប៊ាននិយាយ ដោយសារអាចបណ្តាលមកពីរោគសញ្ញាហ្នឹងផង អាចបណ្តាលមកពីការភ័យខ្លាចផងបាទ។ សូមអរគុណ។

**ស៖** សូមអរគុណលោកជំនាញ។ ខ្ញុំចង់និយាយពីប្រធានបទពាក់ព័ន្ធទៅនឹងកុមារដែលបានរស់នៅក្នុងរបបខ្មែរក្រហម។ លោកបានដឹងហើយថា មានមនុស្សជាច្រើនបានឆ្លងកាត់របបខ្មែរក្រហម ហើយក៏មានអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន។ តើលោកធ្លាប់ជួបអ្នកជំងឺ ឬអ្នករងគ្រោះនៃរបបខ្មែរក្រហមដែលជាកុមារនៅសម័យនោះ ហើយដែលគាត់បានពន្យល់ប្រាប់លោកថា គាត់ត្រូវតែរាយការណ៍ គឺថាមានន័យថា អង្គការហ្នឹងសូមឲ្យគាត់រាយការណ៍ពីឪពុកម្តាយរបស់គាត់? លោកធ្លាប់ជួបអ៊ីចឹងទេ?

[១៤:៣៩:៣៧]

**ឆ៖** បាទ ខ្ញុំបាទធ្លាប់ជួបច្រើន ជាពិសេសគឺអ្នកជំងឺដែលទទួលសេវាពីអង្គការ ធី.ភី.អូ ភាគច្រើនគឺជាអ្នកដែលមានវ័យកុមារភាពនៅក្នុងសម័យខ្មែរក្រហមនោះ។ ហើយដល់ពេលឥឡូវគាត់នៅក្នុងវ័យមួយដែលជាឪពុកម្តាយ។ ហើយសូមបញ្ជាក់ថាដូចខ្ញុំបានលើកអំពីលក្ខណៈបាក់ស្បាតអ៊ីចឹង លក្ខណៈ

*ប្រូកខិន ខៅរេជ* អ៊ីចឹង។ នៅពេលដែលគាត់ជួប *ត្រូម៉ា* ហ្នឹងគឺធ្វើឲ្យគាត់បាត់បង់នូវសេចក្ដីក្លាហាន ហើយបាត់បង់ *ខៅរេជ* ហើយនៅក្នុងការធ្វើអ្វីៗដើម្បីសិទ្ធិរបស់គាត់ ដើម្បីបុព្វហេតុរបស់គាត់។ ប៉ុន្តែករណីហ្នឹងអាចផ្លាស់ប្ដូរក្រោយពីគាត់ទទួលបាននូវសេវាជួយខាងផ្នែកសុខភាពផ្លូវចិត្ត។ វាអាចជួយសម្រាលនូវការភ័យខ្លាចរបស់គាត់, វាអាចជួយបង្កើននូវទំនុកចិត្តរបស់គាត់, វាអាចជួយឲ្យគាត់ហ្នឹងមានសេចក្ដីសង្ឃឹម។ អ៊ីចឹងយើងឃើញមានបងប្អូនមួយចំនួនដែលគាត់ប្រកែកនៅពេលដំបូងគាត់មិនចង់ហ្នឹងបែរជាចង់វិញក្រោយពីឃើញថាមានមូលដ្ឋានគ្រប់គ្រាន់ដែលអាចការពារគាត់នៅក្នុងការឡើងធ្វើសក្ខីកម្ម បាននិងការនិយាយអំពីការលំបាកដែលគាត់ ឬក៏ឪពុកម្ដាយបានជួបប្រទះបាទ។

[១៤:៤១:០២]

**ស៖** សូមអរគុណលោក។ ខ្ញុំព្យាយាមនិយាយអំពីវិបត្តិជាក់លាក់របស់កុមារ។ អ៊ីចឹងខ្ញុំចង់ឲ្យលោករៀបរាប់អំពីបទពិសោធន៍របស់លោក តើលោកធ្លាប់ជួបកុមារដែលរស់នៅរបបខ្មែរក្រហមដែលបានប្រាប់លោកថាក្មេងៗកាលពីសម័យនោះថាមិនស្ដាប់បង្គាប់ឪពុកម្ដាយទេតែស្ដាប់បង្គាប់អង្គការទៅវិញតើលោកធ្លាប់បានជួបក្មេងណាដែលរៀបរាប់ប្រាប់លោកអ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

លោក សុធារ៉ា កុំទាន់អាល់ឆ្លើយតប។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានស្ដាប់ការតាំងសំណួរដោយសហមេធាវីនាំមុខមួយរយៈកន្លងមក ខ្ញុំមិនគួរណាជំទាស់ទេ ក៏ប៉ុន្តែខ្ញុំមិនដឹងថា តើសំណួរនេះវាពាក់ព័ន្ធដោយរបៀបណានោះទេ ទោះបីសំណួរនេះសួរទៅដល់សាក្សីដោយផ្ទាល់ ឬសួរទៅគ្រូពេទ្យចិត្តសាស្ត្រស្អីដែលត្រូវឲ្យគាត់និយាយ គួរតែទៅនិយាយតែភាពទូទៅ ឬប្រសិនណាជាគេសួរសំណួរក្នុងនាមគាត់ជាអ្នកជំនាញ ឧទាហរណ៍អត្ថបទដែលគាត់បានអានពាក់ព័ន្ធទៅនឹងការប៉ះទង្គិចផ្លូវចិត្តនេះ។ ឥឡូវនេះមានសំណួរសួរថា ចុះបើគាត់ជួបអ្នកណាម្នាក់អាចជាជនរងគ្រោះអីយ៉ាងដូច្នេះ ខ្ញុំរីករាយណាស់ក្នុងការស្ដាប់សក្ខីកម្ម ក៏ប៉ុន្តែលើកនេះគឺថាមិនពាក់ព័ន្ធអ្វីទាល់តែសោះ។

[១៤:៤៣:១៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ចំពោះការជំទាស់បែបនេះនោះ។ ខ្ញុំគិតថាអ្នកជំនាញនៅទីនេះដើម្បីផ្តល់សក្ខីកម្មមិនត្រឹមតែពូអ្វីដែលគាត់សរសេរទេ គឺទៅលើបទពិសោធន៍វិជ្ជាជីវៈរបស់គាត់ និងការអនុវត្តវិជ្ជាជីវៈរបស់គាត់។ គាត់នៅទីនេះនោះពីព្រោះថា គាត់ធ្លាប់ព្យាបាលអ្នកជំងឺដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម។ ដូច្នេះខ្ញុំគិតថា អ្នកជំនាញរូបនេះគាត់មានសមត្ថភាពអាចឆ្លើយពាក់ព័ន្ធទៅនឹងបទពិសោធន៍វិជ្ជាជីវៈរបស់គាត់។ ហើយចំពោះខ្ញុំនោះ ខ្ញុំគិតថាសំណួររបស់ខ្ញុំនោះគឺថាវាចាំបាច់។ ដូច្នេះខ្ញុំគិតថា សៀវភៅរបស់គាត់ហ្នឹងក៏មានភាពចាំបាច់ផងដែរ ក៏ប៉ុន្តែសៀវភៅរបស់គាត់ហ្នឹងមិនមានបានដាក់ចូលទៅក្នុងអ៊ិនធឺហ្វេសរបស់យើងនោះទេ។

[១៤:៤៤:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៥:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់ជូនលើសេចក្តីជំទាស់ដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា លើសំណួរចុងក្រោយដែលសួរឡើងដោយសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះចង់បញ្ជាក់ជូនសហមេធាវីនាំមុខថា ជាការសំខាន់ក្នុងការបញ្ជាក់ឲ្យបានច្បាស់នូវក្នុងសំណួរដែលសួរទៅកាន់អ្នកជំនាញ ដើម្បីកុំឲ្យវាមានផលប៉ះពាល់ចំពោះជនរងគ្រោះ។ អង្គជំនុំជម្រះក៏បញ្ជាក់ជូនមេធាវីការពារក្តី នួន ជា ផងដែរថា ខ្លួននឹងមានឱកាសចោទសួរនៅក្នុងពេលវេលាដែលកំណត់ជូនរបស់ខ្លួន គឺនៅពេលដល់វេនខ្លួនសួរនោះគឺថា ខ្លួនអាចសួរសំណួរជាក់លាក់បាន ដើម្បីបង្ហាញអំពីភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់អ្នកជំនាញរូបនេះ។ សូមអរគុណ។

[១៤:៤៧:១០]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** សូមអរគុណលោកចៅក្រម។ ខ្ញុំសូមអនុវត្តទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ក៏ប៉ុន្តែខ្ញុំព្យាយាមលើកអំពីឧទាហរណ៍ជាក់លាក់ដែលធ្លាប់បង្ហាញនៅទីនេះដោយដើមបណ្តឹងរដ្ឋប្បវេណី។

យើងធ្លាប់បានស្តាប់ឮនៅទីនេះ អំពីបុគ្គលដែលនិយាយថា កូនក្មេងត្រូវបានបំបែកចេញអំពីឪពុកម្តាយ ហើយត្រូវដាក់ឲ្យនៅក្រោមការគ្រប់គ្រង ឬក៏ក្រោមអំណាចរបស់អង្គការ។ តើលោកអាចបញ្ជាក់បានទេ លោកធ្លាប់ទទួលអ្នកជំងឺ ឬក៏ជនរងគ្រោះដែលធ្លាប់ប្រាប់លោកទេថា ពួកគាត់ពេលហ្នឹងគឺថាស្ថិតនៅក្រោមអំណាចរបស់អង្គការ មិនមែនស្ថិតនៅក្នុងការមើលការខុសត្រូវរបស់ឪពុកម្តាយទេ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមបញ្ជាក់ថាមានអ្នកជំងឺជាច្រើនដែលពួកគាត់ទាំងអស់ហ្នឹងសុទ្ធតែនៅក្រោមការគ្រប់គ្រងរបស់អង្គការទាំងអស់។ សុទ្ធតែត្រូវបានបំបែកចេញពីក្រុមគ្រួសារ រស់នៅក្នុងជំរំឃុំឃាំង កងកុមារ ឬក៏កងចល័តទាំងអស់។ ហើយពួកគាត់ហ្នឹងត្រូវអប់រំនៅមនោគមន៍វិជ្ជាដែលយើងគិតថាមិនគួរនឹងការអប់រំចំពោះក្មេងៗ។ ឪពុកម្តាយមិនមែនជាកម្មសិទ្ធិរបស់គាត់ទេ គាត់ខ្លួនគាត់ជាកម្មសិទ្ធិរបស់អង្គការជាដើម។ ហើយអ៊ីចឹងគេបានអប់រំឲ្យពួកគាត់ហ្នឹង គឺស្តាប់បង្គាប់អង្គការជាជាងស្តាប់បង្គាប់ឪពុកម្តាយ។ ហើយមានអ្នកខ្លះរហូតដល់រាយការណ៍អំពីឪពុកម្តាយជូនអង្គការទៀតដោយសារលក្ខណៈហ្នឹងហើយដែលគេហៅថា ជាការដែលពួកខ្មែរក្រហមបានលាងខួរក្បាលចំពោះពួកគាត់។ ហើយពួកគាត់ខ្លះមានវិប្បដិសារីខ្លាំងមែនទែន ចំពោះការដែលបានកើតឡើងនៅពេលនោះ។

[១៤:៤៩:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណអ្នកជំនាញ។ អរគុណមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ -- ដល់អ្នកជំនាញរូបនេះសម្រាកនៅក្នុងអំឡុងពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីនិងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៩ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៦:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ ហើយសូមជម្រាបថានៅសល់ពេលវេលា២៥នាទីទៀត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកអ្នកជំនាញ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយអំពីប្រធានបទមួយទៀត ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ។ ខ្ញុំនឹងសួរសំណួរមួយចំនួន ដោយឈរលើមូលដ្ឋាននៃបទពិសោធន៍របស់លោកដែលលោកបានធ្វើការជាមួយអ្នកជនរងគ្រោះនៃរបបខ្មែរក្រហម ហើយដែលទាក់ទងទៅនឹងអ្វីដែលយើងបានស្តាប់អស់រយៈពេល១ឆ្នាំកន្លះមកហើយនេះ។

[១៥:០៧:០៣]

បើតាមបទពិសោធន៍អាជីពរបស់លោក ហើយនិងការជួបជាមួយនឹងជនរងគ្រោះមួយចំនួន តើលោកអាចនិយាយឲ្យបានលម្អិតអំពីផលប៉ះពាល់ទៅលើជនរងគ្រោះទាំងអស់នេះ ពីមូលហេតុដែលគាត់បានចាកចេញពីផ្ទះរបស់គាត់ ហើយនិងទុកអ្វីៗចោលទាំងអស់ ហើយនិងវត្ថុដែលជារបស់គ្រួសាររបស់គាត់ និងរបស់ជាអនុស្សាវរីយ៍ ហើយនិងអ្វីដែលជាៗអនុស្សាវរីយ៍របស់គាត់។ តើលោកអាចជម្រាបតុលាការបានទេ អំពីផលប៉ះពាល់នៃការបាត់បង់របស់របរទាំងឡាយដែលខ្ញុំបានរៀបរាប់អម្បាញ់មិញនេះ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ សូមអរគុណលោកស្រីមេធាវី។ ខ្ញុំបាទសូមបញ្ជាក់ថា ដូចខ្ញុំបានបំភ្លឺពីមុខខ្លះមកហើយថា យើងមាន កាលណាយើងរស់នៅកន្លែងណា យើងមានចំណងផ្នែកផ្លូវចិត្ត ផ្នែកអារម្មណ៍អនុស្សាវរីយ៍ទាំងឡាយជាមួយកន្លែងនោះ ជាមួយអ្វីៗជុំវិញនោះ ជាមួយនឹងមនុស្សដែលជាទីស្រលាញ់នៅកន្លែងនោះ។ ប៉ុន្តែនៅពេលដែលមានការបង្ខំជម្លៀសចេញពីផ្ទះសម្បែង ពីទីក្រុងដូចការកើតឡើង

នៅក្នុងសម័យខ្មែរក្រហមនោះ ចំណងទាំងអស់នោះនឹងបានត្រូវកាត់ផ្តាច់ទៅហើយ។ យើងបានផ្លាស់ចេញ ចាកចេញពីផ្ទះ ពីលំនៅដ៏សុខសាន្ត យើងបាត់បង់នូវការការពារ ដោយថាសុវត្ថិភាព អារម្មណ៍ក្នុងការមានសុវត្ថិភាពហ្នឹងក្នុងការមានការបាត់បង់ហើយ។ យើងបាត់បង់នូវកន្លែងដែលយើងត្រូវគោរពបូជា បាត់បង់នូវអនុស្សាវរីយ៍ផ្សេងៗ បាត់បង់នូវការការពារទាំងផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកផ្លូវអារម្មណ៍ – ខាង*ស្មៀរីត*។ អ៊ីចឹងការទាំងអស់ហ្នឹងបាត់បង់។ ហើយអាចបាត់បង់មួយទៀតគឺ ទាក់ទងទៅនឹងសាលារៀន កន្លែងធ្វើការ ការបាត់បង់ប្រាក់ចំណូល។ យើងមើលថា មានទស្សនវិទូឥណ្ឌាគាត់មានប្រសាសន៍ថា "ផ្ទះគឺជាសាលារៀនដ៏ល្អ ហើយឪពុកម្តាយគឺជាគ្រូដ៏ល្អ"។ អ៊ីចឹងការបាត់បង់ហ្នឹងគឺជាការបាត់បង់ធ្ងន់សម្រាប់យើងនូវឱកាសរៀនសូត្រ ពីផ្ទះផង ពីសាលា ពីកន្លែង ហើយនិងការដែលជម្លៀសហ្នឹងមិនត្រឹមតែជម្លៀសចេញពីកន្លែងទេ គឺមានការកាត់ផ្តាច់នូវទំនាក់ទំនងរវាងក្រុមគ្រួសារទៀត ដូចជាកូនត្រូវបានជម្លៀសចេញពីឪពុកម្តាយ យកចេញពីឪពុកម្តាយជាដើម។ ត្រង់ហ្នឹងគឺជាការបាត់បង់ឱកាសច្រើន។ ហើយការបាត់បង់ទាំងអស់ហ្នឹង -- ហើយខ្ញុំសូមបញ្ជាក់ទៀតថា ទាក់ទងទៅនឹងការជម្លៀសនោះ វាមិនត្រឹមតែជម្លៀសមួយមុខទេ ប៉ុន្តែទារុណកម្ម ការកាប់សម្លាប់ ការបង្ខំឱ្យធ្វើការដោយមិនមានប្រាក់ចំណូល ឬក៏ធ្វើការដោយមិនមានចំណី មិនមានជម្រក មិនមានការថែទាំបូកនឹងការរស់នៅក្នុងការគំរាមកំហែង ពីព្រោះនៅពេលដែលគេជម្លៀសទៅដល់កន្លែងថ្មីហើយ ពួកឈ្លប ពួកទ័ពខ្មែរក្រហមគេព្យាយាមតាមដានរក ដឹងពីប្រវត្តិអ្នកដែលរៀនសូត្រ អ្នកដែលមាន អ្នកដែលបញ្ញវន្តជាដើម ដើម្បីយកទៅសម្លាប់ចោទនោះ។ គឺទាំងអស់ហ្នឹង គឺសុទ្ធតែ គឺជាការប៉ះទង្គិចផ្លូវចិត្តមួយដែលគាត់ទទួលបានជាបន្ត ជាបន្តបន្ទាប់ ដែលធ្វើឱ្យគាត់ហ្នឹងអាចរស់នៅក្នុងការភិតភ័យជារហូត។

[១៥:១១:០៥]

ខ្ញុំសូមបញ្ជាក់ថា មានអ្នកជំងឺដែលខ្ញុំបានជួបម្នាក់ គាត់បានមានប្រសាសន៍ -- អ្នកជំងឺដែលខ្ញុំបានជួបម្នាក់នោះ គឺថានៅពេលដែលទៅដល់កន្លែងថ្មី គាត់មានការលំបាកខ្លាំងណាស់។ អ៊ីចឹងគាត់ធ្វើការបន់ស្រន់ ហើយនៅពេលនោះ គាត់មិនដឹងទៅព្រះមួយណាទៀត ពីព្រោះទីកន្លែង វត្តអារាមគ្រិស្តសាសនា ឬក៏វិហារអ៊ីស្លាមទាំងឡាយហ្នឹង ត្រូវបានបំផ្លិចបំផ្លាញអស់ទៅទៀត។ អ៊ីចឹងយើងឃើញការបាត់បង់ហ្នឹងទាំងសម្ភារៈ បាត់បង់ទាំងវត្ថុអនុស្សាវរីយ៍ សាសនា ការគោរពបូជា ទំនាមទម្លាប់វប្បធម៌ ការផ្លាស់ប្តូរអំពីទីកន្លែង គឺថាធ្វើឱ្យគាត់មិនអាចដឹងអំពីពេលវេលាសព្វបែបយ៉ាងទៅនឹងកន្លែងថ្មីហ្នឹង គឺជាសភាពមួយដែលហាក់ដូចជាដាក់គាត់ហ្នឹង ទៅកន្លែងមួយដែលថ្មី ដែលធ្វើឱ្យគាត់ហ្នឹង

ពិបាកនឹងរស់ ពិបាកនឹងដោះស្រាយទៅនឹងហេតុការណ៍ទាំងអស់ហ្នឹង បាទ។ អ៊ីចឹងគឺជាគេហៅថាជាការប៉ះទង្គិចផ្លូវចិត្តធ្ងន់ហើយ ដែលកើតមានចំពោះពួកគាត់។

**ស៖** សូមអរគុណ។ នៅក្នុងការជម្លៀសបង្ខំហ្នឹង មានមនុស្សជាច្រើនពន្យល់ថា ខ្លួនជាអ្នកជនរងគ្រោះពីអំពើហិង្សា។ តើលោកបានធ្លាប់ឮពួកគាត់រៀបរាប់អំពីការប៉ះទង្គិចផ្លូវចិត្ត ឬក៏វិបត្តិផ្លូវចិត្ត ដោយថាគាត់ពួកហ្នឹងបានឃើញអំពើហិង្សាទាំងអស់នោះទេ លោកធ្លាប់ស្តាប់ពួកជនរងគ្រោះទាំងអស់នេះនិយាយដែរទេ?

[១៥:១៣:០៥]

**ឆ៖** បាទ សូមបញ្ជាក់ថាការប៉ះទង្គិចផ្លូវចិត្តហ្នឹង គឺអាចកើតមានដោយសារការជួបប្រទះដោយផ្ទាល់ ដោយសារឃើញផ្ទាល់ភ្នែក ឬក៏ដោយសារការស្តាប់ឮ។ អ៊ីចឹងទាំងបីនេះ គឺវាអាចបង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្ត នៅពេលដែលជួនកាលបើគាត់មិនបានជួបប្រទះខ្លួនឯង ប៉ុន្តែគាត់បានឃើញផ្ទាល់ភ្នែកចំពោះអ្នកដែលមានជួបហេតុការណ៍ហ្នឹង ក៏គាត់អាចរងប៉ះទង្គិចផ្លូវចិត្តដែរ ហើយយើងក៏បានឃើញបងប្អូនមួយចំនួនក៏គាត់មិនបានជួបផ្ទាល់ ប៉ុន្តែក៏គាត់បានស្តាប់ឮ។ អ៊ីចឹងការស្តាប់ឮហ្នឹងវាហាក់ដូចជាចាក់ចូលទៅក្នុងអារម្មណ៍ដែលធ្វើឲ្យគាត់ហ្នឹងរន្ធត់។ អ៊ីចឹងវានៅក្នុងកម្រិតមួយដែលគាត់រងនូវការប៉ះទង្គិចដែរបាទ។

**ស៖** តើលោកធ្លាប់បានកត់សង្កេតឃើញថា គាត់ហ្នឹងទទួលរងការប៉ះទង្គិចដែរឬទេ ក្នុងក្រប-ខ័ណ្ឌនៃការប្រកបវិជ្ជាជីវៈរបស់លោកនោះ?

**ឆ៖** បាទ គឺគាត់មានការប៉ះទង្គិចផ្លូវចិត្ត ដូចព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្តផ្សេងៗទៀតដែរចំពោះការជម្លៀសចេញហ្នឹង បាទ។

[១៥:១៤:៤១]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីប្រធានបទមួយដែលត្រូវបាននិយាយលម្អិតដោយដើមបណ្តឹងរដ្ឋប្បវេណី គឺប្រធានបទនៃ ថាគឺការ -- មានការអន្ទងអារម្មណ៍គាត់រហូតហើយដែលធ្វើឲ្យគាត់ហ្នឹងមានការប្រកាន់អាកប្បកិរិយាប្លែក។ តើលោកធ្លាប់ជួបអ្នកដែលថា គាត់អត់ឃ្លានរហូត ហើយនៅមានអារម្មណ៍ថា ស្រេកឃ្លាន ហើយគេ -- គាត់ធ្វើឲ្យគាត់ -- កាលណាគាត់ស្រេកឃ្លានធ្វើឲ្យរបៀបគិតរបស់គាត់ អ្វីៗសព្វបែបយ៉ាងហ្នឹងណ៎ះ អាកប្បកិរិយាអីហ្នឹងប្រែប្រួល។ លោកធ្លាប់បានសង្កេតឃើញករណីបែបនេះទេ?

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[១៥:១៥:៣៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួររបស់សហមេធាវីនាំមុខ តើយើងនិយាយពីជនរងគ្រោះទូទៅ ឬក៏និយាយពីអ្នកជំងឺដែលគាត់បានព្យាបាល ឬក៏និយាយអំពីប្រជាជនដែលជាកម្មវត្ថុដែលគេបានយកចង្កោមសំណួរហ្នឹងទៅសួរសាកសួរនោះ? ដូច្នេះ យើងត្រូវតែមានការចោទសួរជាក់លាក់ថា តើអ្នកជំនាញនេះ ឥឡូវនេះ នៅពេលដែលគាត់ឆ្លើយទៅនេះ តើគាត់ឆ្លើយដោយសារតែការបទពិសោធន៍ដែលគាត់បានជួបប្រទះ ឬក៏និយាយអំពីបញ្ហានៃការមានចង្កោមសំណួរដែលគាត់សួរតាមដងផ្លូវផ្សេងៗនោះ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំដូចជាភ្ញាក់ផ្អើលមែនទែន ខ្ញុំមិនដឹងថាគាត់ខាងការពារក្តីមិនចង់ស្តាប់អ្នកជំនាញទេ។ ប៉ុន្តែទទ្ទឹមនឹងហ្នឹង ខ្ញុំព្យាយាមសូមឲ្យគាត់ឆ្លើយឈរលើមូលដ្ឋាននៃបទពិសោធន៍វិជ្ជាជីវៈរបស់គាត់ទាក់ទងទៅនឹងជនរងគ្រោះសម័យខ្មែរក្រហម។ អ៊ីចឹងខ្ញុំគិតថា ច្បាស់ហើយគាត់នឹងឆ្លើយដោយឈរលើបទពិសោធន៍របស់គាត់ ដែលថានេះយើងបានបញ្ជាក់តាំងពីដើមហើយ។ អម្បាញ់មិញនេះខ្ញុំសួរ -- ប្រាប់គាត់ហើយថា ខ្ញុំសួរសំណួរគាត់ថា ឲ្យគាត់ឆ្លើយទៅតាមបទពិសោធន៍ដែលគាត់បានជួបប្រទះ មិនមែនសួរឲ្យគាត់ឆ្លើយតែពីកតែពាសថា ជួប ថា ឃើញមនុស្សដើរតាមផ្លូវអីនោះទេ គឺថា ផ្តងកាត់លើបទពិសោធន៍ជាក់ស្តែងរបស់គាត់តែម្តង។

[១៥:១៧:១៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៩:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តសំណួរទៅមុខទៀត។ ហើយសូមជម្រាបលោក វ៉ិចទ័រ កូប៉េ ផងដែរថា លោកនឹងមានឱកាសក្នុងការតាំងសំណួរ ឬក៏សួរបញ្ជាក់បន្ថែម

ទៀតនៅក្នុងករណីដែលមានសំណួរណារបស់ភាគីឯទៀតហ្នឹងមានបញ្ហាដែលលោកមិនទាន់យល់ច្បាស់។ សូមអញ្ជើញ!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកអ្នកជំនាញ តើលោកចង់ឲ្យខ្ញុំសួរសំណួរនេះឡើងវិញ ឬក៏យ៉ាងម៉េច?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ សូមបញ្ជាក់ឡើងវិញបន្តិចទៀតបាទ។

[១៥:២០:៣៤]

**ស៖** អម្បាញ់មិញនេះខ្ញុំនិយាយថា មានមនុស្សជាច្រើនដែលគឺថាជនរងគ្រោះដែលគាត់និយាយថា គាត់មានអារម្មណ៍ថាខ្លាំង -- ឃ្លានខ្លាំងជាប់រហូត អន្ទងតាមប្រាណ ហើយដែលធ្វើឲ្យអាកប្បកិរិយារបស់គាត់នេះវាអាស្រ័យនឹងការស្រេកឃ្លានហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកធ្លាប់ឮជនរងគ្រោះទាំងអស់ហ្នឹងនិយាយអំពីស្រែកឃ្លាតរហូតដែរឬទេ? ហើយខ្ញុំចង់សូមឲ្យលោកជម្រាបថាតើការអាកប្បកិរិយាដែលអាស្រ័យនេះ វារងកើតមានឡើងដោយស្ថិតនៅក្រោមឥទ្ធិពលអី? ហើយបើសិនមានឥទ្ធិពលនោះ ថាលោកអាចជម្រាបតុលាការបានទេ ឥទ្ធិពលហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ សូមអរគុណ។ សូមបញ្ជាក់ថា ការប៉ះទង្គិចផ្លូវចិត្ត គឺៗជាព្រឹត្តិការណ៍មួយដែលធ្វើឲ្យបុគ្គលហ្នឹងមានលក្ខណៈមួយដែលថាវាលើសលប់ ដែលវាមានលក្ខណៈលើសលប់ដែលធ្វើឲ្យបុគ្គលហ្នឹងមិនអាចដោះស្រាយនឹងបញ្ហាបាន។ ការប៉ះទង្គិចផ្លូវចិត្ត គឺវាធ្វើឲ្យបុគ្គលហ្នឹងវាមានការប្រែប្រួលនៅក្នុងការគិត ធ្វើឲ្យការប្រែប្រួលនៅក្នុងជំនឿ និងធ្វើឲ្យមានការប្រែប្រួលនៅក្នុងទំនាក់ទំនងរបស់គាត់ជាមួយអ្នកដទៃ។

[១៥:២២:០៥]

អ៊ីចឹងក្នុងករណីដែលគាត់កំពុងតែរងនូវការឈឺចាប់ រងនូវការស្រេកឃ្លាន ការគិតរបស់គាត់ហ្នឹងមានការផ្លាស់ប្តូរ។ គាត់អាចកាត់កេរ្តិ៍ខ្មាសនៅក្នុងការធ្វើអ្វីៗដែលមានលក្ខណៈមួយ ដែលគិតថាឲ្យស្របតាមលក្ខណៈសីលធម៌ហ្នឹង គាត់អាចបំភ្លេចអាហ្នឹង គាត់ទៅធ្វើអ្វីដើម្បីបំពេញនូវតម្រូវគាត់របស់គាត់។ នៅពេលនុ៎ង គឺមានបងប្អូនមួយចំនួនក៏គាត់បាននិយាយដែរថា គាត់ធ្វើអីក៏គាត់ធ្វើដែរនៅពេលដែលគាត់កំពុងតែឈឺចាប់ កំពុងតែអត់ឃ្លាន កំពុងតែស្រេកឃ្លានហ្នឹង។

អ៊ីចឹងលក្ខណៈទាំងអស់ហ្នឹងហើយដែលអាចបញ្ជាក់ថា ការប៉ះទង្គិចហ្នឹងវាអាចធ្វើឲ្យគាត់ហ្នឹង

ផ្លាស់ប្តូរនូវការគិត ហើយអាចធ្វើឲ្យគាត់ហ្នឹងធ្វើអ្វីៗទៅតាមការយល់ឃើញរបស់គាត់។ ហើយចំពោះបញ្ហា គឺវាមិនអាច -- ខ្ញុំមិនអាចកំណត់បានថាតើអាបញ្ហាហ្នឹងវានៅតែបន្តមកដល់ពេលឥឡូវ ឬក៏បានបាត់ទៅហើយនោះទេបាទ។

**ស៖** សូមអរគុណ។ ដើម្បីទៅមុខឲ្យលឿនបន្តិច ព្រោះថាពេលវេលាទៅមុខលឿន ខ្ញុំសូមឲ្យលោកឆ្លើយដោយខ្លី។ សំណួរសួរថាតើលោកធ្លាប់បានឮជនរងគ្រោះនិយាយអំពីការស្រេកឃ្លានដែលអន្ទងតាមប្រាណពួកគាត់រហូតនេះដោយផ្ទាល់ត្រចៀកដែរឬទេ?

**ឆ៖** បាទដែលឮ។ អ្នកណាក៏មកការត្អូញត្អែរអំពីការស្រេកឃ្លានអន្ទងតាមប្រាណ និងការឈឺចាប់អន្ទងតាមប្រាណហ្នឹងដែរបាទ។

[១៥:២៤:០១]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមចោទសំណួរមួយ ទាក់ទងទៅនឹងក្មេងៗដែលបានរៀបរាប់ថាចំពោះពួកគេជាការលំបាកណាស់ក្នុងការឃើញឪពុកម្តាយរបស់ខ្លួនបាក់កម្លាំង បាត់បង់កម្លាំង ហើយនិងធ្លាក់ទឹកចិត្ត ហើយនិងត្រូវបានគេមើលងាយ ធ្លាក់ខ្លួនឈឺ ហើយស្រេកឃ្លានរហូត។ លោកធ្លាប់ឮជនរងគ្រោះធ្លាប់និយាយអំពីរឿងនេះដែរឬទេ? ហើយធ្លាប់រៀបរាប់ប្រាប់លោកថា គេជាការលំបាកណាស់ចំពោះពួកគេក្នុងការឃើញឪពុកម្តាយគេស្ថិតនៅក្នុងស្ថានភាពយ៉ាងដូច្នេះ?

**ឆ៖** បាទ ខ្ញុំបាទធ្លាប់ឮ ធ្លាប់ឮអ្នកជំងឺមួយចំនួនក៏បានរៀបរាប់ ដោយសារឃើញឪពុកម្តាយដែលមានកំហុសៗ ហើយត្រូវគេធ្វើទារុណកម្ម ហើយពួកគាត់មិនត្រូវអនុញ្ញាតឲ្យយំ ឲ្យបង្ហាញនូវការសោកស្តាយអាណិតអាសូរទៅលើពួកគាត់។ អ៊ីចឹងគឺជាការកៀបសង្កត់មួយ ជាទារុណកម្មផ្លូវចិត្តមួយបន្ថែមទៀតទៅលើពួកគាត់ធ្វើឲ្យគាត់ហ្នឹងពិបាកដែលហៅថា ឈឺចាប់នៅក្នុងទ្រូង ឈឺចាប់នៅក្នុងចិត្តដែលធ្វើឲ្យគាត់ហ្នឹងពិបាកនឹងទ្រាំបាទ។

[១៥:២៥:៤៦]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមនិយាយអំពីខ្មែរដែលចាកចេញទៅនៅប្រទេសក្រៅ។ តើលោកធ្លាប់បានជួបជនរងគ្រោះដែលបានធ្លាប់ឆ្លងកាត់របបខ្មែរក្រហមហើយដែលឥឡូវនេះគាត់រស់នៅបរទេស។ លោកធ្លាប់បានជួបខ្មែរនៅបរទេសនោះទេ?

**ឆ៖** បាទ ខ្ញុំបានជួបតាមរយៈការធ្វើកម្មសិក្សារបស់ខ្ញុំបាទ នៅសកលវិទ្យាល័យ ញូវសៅវែលនៃប្រទេសអូស្ត្រាលី។

**ស៖** តើលោកអាចរៀបរាប់អំពីវិបត្តិផ្លូវចិត្តរបស់គាត់ដែរឬទេ? តើគាត់មានវិបត្តផ្លូវចិត្តអ្វីខ្លះ?

**ឆ៖** បាទ ចំពោះយើងគ្រប់គ្នាយើងតែងយល់ថាបងប្អូនខ្មែរយើងដែលបានទៅរស់នៅប្រទេសផ្សេង ប្រទេសទីបីដែលយើងចាត់ទុកថាជាប្រទេសជាឋានសួគ៌ ជាកន្លែងដែលមានធនធានសម្រាប់ពួកគាត់អ៊ីចឹងពួកគាត់ច្បាស់ជាមានលក្ខណៈប្រសើរជាងអ្នកដែលនៅក្នុងប្រទេសកម្ពុជាយើង។ ខ្ញុំបាទសូមបញ្ជាក់ថា ការឈឺចាប់របស់គាត់ក៏មានដូចជាប្រជាជនកម្ពុជានៅក្នុងប្រទេសដែរ។ ប្រជាជនកម្ពុជានៅក្នុងប្រទេសគឺការឈឺចាប់របស់គាត់ក្រោយពីសម័យខ្មែរក្រហមឬក៏សម័យខ្មែរក្រហម គឺការបាត់បង់នូវសុវត្ថិភាព ជាប់នឹងភាពក្រីក្រ ខ្វះខាតសេវាថែទាំ មានការលំបាកសព្វបែបយ៉ាង សង្គ្រាមនឹងបន្ត។ អ៊ីចឹងវាបន្តឲ្យគាត់រងនឹងការឈឺចាប់។ ប៉ុន្តែចំពោះបងប្អូនខ្មែរយើងនៅបរទេស គាត់អាចមានសុវត្ថិភាពជាងអ្នកដែលរស់នៅក្នុងប្រទេសកម្ពុជា។ គាត់អាចមានទទួលនូវសេវាគាំទ្រផ្នែកសង្គមច្រើន ជាងអ្នកដែលនៅកម្ពុជា ប៉ុន្តែអ្វីដែលគាត់ខ្វះខាតនោះ គឺខ្វះខាតនូវចំណងទំនាក់ទំនងដែលគាត់មាននៅ -- មានជាមួយប្រទេសកម្ពុជា ដូចជាទំនាក់ទំនងវប្បធម៌ សាសនា គាត់មិនមានការកន្លែងដែលទៅគោរពបូជា ដូចជាកន្លែងដែលដូចគាត់នៅប្រទេសផ្សេងទេ។ គាត់មិនអាចនិយាយភាសាបរទេសបាន។ គាត់នៅពេលទៅរកសេវាខាងវេជ្ជសាស្ត្រសេវាផ្សេងៗ ធ្វើឲ្យគាត់មានការលំបាក។

[១៥:២៨:៣០]

ការសិក្សាមួយរបស់សាស្ត្រាចារ្យ ដេវីន ហ៊ិនតុន នៅសហរដ្ឋអាមេរិកនោះ គឺឃើញថាការលំបាកខ្វះខាតខាងគាំទ្រខាងផ្នែកវប្បធម៌ហ្នឹង ហើយដែលធ្វើឲ្យសញ្ញាផ្លូវចិត្តរបស់គាត់ហ្នឹងកើនឡើង ដូចជាមានការខឹងច្រើន និងរោគសញ្ញា ភី.ធី.អេស.ឌី គឺមានការកើនឡើងដោយទាក់ទងទៅនឹងបញ្ហាទាំងអស់ហ្នឹង។

ហើយខ្ញុំសូមបញ្ជាក់មួយទៀតចំពោះអ្នកជំងឺដែលខ្ញុំធ្លាប់ជួបនៅពេលធ្វើកម្មសិក្សានោះ គឺថាគាត់ឈឺចាប់ហ្នឹងគឺត្អូញត្អែរជាប់រហូតអំពីបញ្ហាផ្លូវចិត្តហ្នឹងដែលវេជ្ជបណ្ឌិតឯកទេសផ្លូវចិត្តរបស់អូស្ត្រាលីហ្នឹងមិនអាចព្យាបាលបាន។ គេព្យាបាលដោយថ្នាំ ប៉ុន្តែហាក់ដូចជាមិនមានប្រសិទ្ធភាពទៅលើគាត់។ ប៉ុន្តែចំណុចមួយដែលគាត់បានពិភាក្សាជាមួយ *ខោនសេល័រ* – អ្នកផ្ដល់ប្រឹក្សាខ្មែរនៅទីនោះ គឺគាត់បានសម្រេចចិត្តមកប្រទេសកម្ពុជាមកធ្វើពិធីខាងផ្នែកសាសនាចំពោះឪពុកម្ដាយគាត់ដែលស្លាប់នៅក្នុងសម័យខ្មែរក្រហមនោះ ហើយធ្វើឲ្យគាត់មានអារម្មណ៍ជ្រះថ្លា ធ្វើឲ្យគាត់ហ្នឹងហាក់ដូចជាបានបំពេញកាតព្វកិច្ចចំពោះអ្នកដែលស្លាប់ ហើយជូនពរចំពោះអ្នកដែលស្លាប់បានទៅកាន់សុគតិភពជាដើមហ្នឹង ធ្វើឲ្យគាត់

មានអារម្មណ៍ភ្លឹថ្លា។ នៅពេលដែលគាត់ត្រឡប់ទៅអូស្ត្រាលីនោះវិញ គឺឃើញថាសភាពគាត់មានការប្រែប្រួលហាក់ដូចជារស់រវើក។ អ៊ីចឹងខ្ញុំគិតថា ការដែលនៅឆ្ងាយ នៅបរទេសដែលឆ្ងាយពីវប្បធម៌ ទំនៀមទម្លាប់ចំណីអាហារ ភាសា និងទម្លាប់សព្វបែបយ៉ាងហ្នឹងគឺបន្តឱ្យគាត់មានបញ្ហាផ្លូវចិត្ត។ ហើយខ្ញុំក៏សូមលើកការសិក្សារបស់សាស្ត្រាចារ្យ ហ្រ្កង់ម៉ាសាល នៅសហរដ្ឋអាមេរិកដែរគឺថា ទោះបីជា ២០ ឆ្នាំក្រោយពីការតាំងទីលំនៅៗសហរដ្ឋអាមេរិក ហើយបងប្អូនយើងនៅទីនោះ និងក៏នៅមានអត្រានៃជំងឺធ្លាក់ទឹកចិត្ត និងជំងឺ ភី.ធី.អេស.ឌី ច្រើនខ្ពស់នៅឡើយ។ បាទ សូមអរគុណ។

[១៥:៣០:២៩]

**ស៖** តើលោកផ្ទាល់ តើលោកមានលទ្ធភាពក្នុងការមើលពីចំនួនភាគរយច្បាស់លាស់ ឬក៏ប្រហាក់ប្រហែល? តើចង់ដឹងថាមានមនុស្សខ្មែរយើងនៅបរទេសប៉ុន្មានភាគរយដែលទទួល --មានវិបត្តិផ្លូវចិត្តនៃរបបខ្មែរក្រហមនេះ។ លោកប៉ាន់ស្មានប្រហែលប៉ុន្មានភាគរយដែរ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនដឹងជាសំណួររបៀបម៉េចទេនេះគឺថា ខ្ញុំមិនដឹងថា តើមាន -- ដោយសារគាត់គឺជាជំនាញគួរណាស់តែសួរសំណួរគាត់អំពីការសិក្សាស្រាវជ្រាវផ្នែកខាងវេជ្ជសាស្ត្រ ប៉ុន្តែមិនត្រូវសួរយ៉ាងទូលំទូលាយ ថាគាត់មានយោបល់ ថាម៉េច គាត់យល់ថាម៉េចយ៉ាងដូច្នេះទេ ដូចថាខ្ញុំអត់យល់។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ឥឡូវខ្ញុំសូមសួរម្តងទៀត។ តើក្នុងឋានៈជាអ្នកជំនាញនេះ លោកធ្លាប់បានធ្វើការវាស់វែងភាគរយខ្មែរនៅបរទេស ដែលនៅតែបន្តឈឺចាប់ពីការដែលវិបត្តិផ្លូវចិត្តក្រោយការប៉ះពាល់ ការប៉ះទង្គិចនេះ។ អ៊ីចឹងខ្ញុំចង់សួរថាតើលោកធ្លាប់មានជួបគាត់ទេអ្នកដែលជនរងគ្រោះទាំងអស់នេះ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** ខ្ញុំមិនបានទៅធ្វើការនៅបរទេសទេ។ ខ្ញុំមិនបានទៅធ្វើការស្រាវជ្រាវចំពោះជនជាតិខ្មែរនៅបរទេសទេ ប៉ុន្តែខ្ញុំផ្អែកទៅលើការសិក្សាលក្ខណៈវិទ្យាសាស្ត្ររបស់ស្កូលឡា មួយចំនួននៅ ដែលធ្វើការជាមួយប្រជាជនកម្ពុជា។ ហើយការសិក្សាមួយដែលយើង ដូចខ្ញុំបានជម្រាបជូនអំមិញដូចលោក ហ្រ្កង់

ម៉ាសាល ហ្នឹងគឺក្នុង -- គឺថា២០ឆ្នាំក្រោយពីការតាំងទីលំនៅហើយ គឺគាត់នៅឃើញអត្រាជំងឺ ភី.ធី.អេស.ឌី គឺជាង៦០ភាគរយ និងជំងឺ ឌីប្រេសសិន ជាង៥០ភាគរយនៅក្នុងចំណោមអ្នកដែលគាត់ធ្វើការសិក្សា ប្រហែលជាជិត ១០០០នាក់ហ្នឹង។

[១៥:៣៣:០៩]

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកស្រីមេធាវី។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសព្រះរាជអាជ្ញា!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានគេកាត់ខ្ញុំច្រើនណាស់ ខ្ញុំសូម៥នាទីទៀតបានទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ យើងជៀសវាងគេកាត់ គួររៀបចំសំណួរធ្វើម៉េចកុំឲ្យវា -- ត្រឹមត្រូវ ឲ្យវាជាក់ច្បាស់ហើយនិងសមស្របទៅនឹងការសួរទៅអ្នកជំនាញ។ ហើយជៀសវាងសួរបញ្ហាដែលអាចប្រឈមនឹងការជំទាស់។ អនុញ្ញាត!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកអ្នកជំនាញ តាមបទពិសោធន៍របស់លោកទាក់ទងទៅនឹងជនរងគ្រោះដែលបាននិយាយអំពីទុក្ខវេទនាដែលកើតចេញពីការហាមឃាត់មិនឲ្យប្រតិបត្តិសាសនា ហើយនិងទាក់ទងនឹងបញ្ហាសាសនា ដែលកើតមានឡើងក្នុងសម័យក្រហម។ តើលោកធ្លាប់ស្តាប់ជនរងគ្រោះទាំងអស់នេះដែរឬទេ ហើយបើលោកធ្លាប់ស្តាប់នោះ តើលោកអាចនិយាយអត្ថាធិប្បាយជូនតុលាការបានដែរទេ អំពីបញ្ហារបស់គាត់?

[១៥:៣៤:៣៧]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ ខ្ញុំបានធ្លាប់ឮខ្លះដែរ ដែលពួកគាត់មានប្រសាសន៍ថា យើងធម្មតាប្រជាជនខ្មែរយើងនៅពេលដែលមានបញ្ហាអី គឺតែងតែរុករកនូវជំនួយៗគាត់ចាប់ដំបូងជំនួយខាងផ្នែកផ្លូវសាសនា ខាងផ្នែកជំនឿហ្នឹងហើយ។ អ៊ីចឹងនៅក្នុងសម័យខ្មែរក្រហមហ្នឹងគឺគាត់ខ្វះខាតអាហ្នឹង ប្រជាជននៅក្នុងប្រទេសក្រីក្រមួយដែលមិនមានប្រព័ន្ធសុខាភិបាលគ្រប់គ្រាន់ បញ្ហាជំនឿ បញ្ហាសាសនាហ្នឹងហើយដែល

ជាវិធីសាស្ត្រក្នុងការជួយគាត់។ អ៊ីចឹងគាត់បានមានប្រសាសន៍ថា សូម្បីតែការរកជំនួយខាងផ្នែកជំនឿខាងផ្នែកសាសនា តាមផ្នែកគ្រូមន្តអាគមអីហ្នឹងក៏អត់មានដែរ។ អ៊ីចឹងវាជាការបាត់បង់ ដកគាត់ចេញអំពីអ្វីៗដែលគាត់ធ្លាប់មាន អ្វីៗដែលគាត់ត្រូវរស់នៅ ហើយពីជំនឿទាំងឡាយហ្នឹងបាទ។

**ស៖** ជាចុងក្រោយ គឺថាតាមបទពិសោធន៍របស់លោក លោកបានទទួលជនរងគ្រោះនៃរបបខ្មែរក្រហមហើយ តាមរយៈការត្អូញត្អែររបស់គាត់ និងសំណូមពររបស់គាត់ តើលោកអាចបើតាមលោកនោះ អាចរៀបរាប់ជូនតុលាការបានទេ អំពីតម្រូវការរបស់ពួកគាត់ តម្រូវការផ្នែកការគាំពារផ្លូវចិត្តគាត់នោះ? តើគាត់មានតម្រូវការអ្វីខ្លះ?

[១៥:៣៦:១៤]

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមបញ្ជាក់ថា ដើម្បីព្យាបាលជំងឺផ្លូវចិត្ត ការប៉ះទង្គិចផ្លូវចិត្តបានហ្នឹងមានកត្តាច្រើន។ កត្តាទី១ ដោយសារខ្ញុំបាទជាវេជ្ជបណ្ឌិត អ៊ីចឹងគឺការអាចការព្យាបាលដោយសារការប្រើឱសថ ហើយនិងការផ្តល់ប្រឹក្សា ដើម្បីជួយគាត់ដោះស្រាយអំពីបញ្ហាអារម្មណ៍។ កត្តាទី២ សូមបញ្ជាក់ទាក់ទងទៅនឹងតម្រូវការ។ តម្រូវការរបស់គាត់ សូមយើងត្រូវដឹងថាតើគាត់ត្រូវការអី? ជាគោលការណ៍ជនរងគ្រោះ គឺត្រូវការសេចក្តីសុខ សេចក្តីការ -- ត្រូវការយុត្តិធម៌ ត្រូវការចង់ដឹងការពិត ត្រូវការនូវការគោរពនូវអត្តសញ្ញាណ ត្រូវការនូវការគោរពនូវវប្បធម៌ ត្រូវការនឹងការបង្កើនឱ្យមាននូវធនធានសេដ្ឋកិច្ចឡើងវិញ។ អ៊ីចឹងអានេះ បើសិនជាតម្រូវទាំងអស់នេះនឹងមាន គឺវាជាការចូលរួមនៅក្នុងការធ្វើឱ្យជាសះស្បើយអំពីការប៉ះទង្គិចផ្លូវចិត្ត។

ហើយចំពោះការសិក្សាដែលអង្គការ ធី.ភី.អូ បានធ្វើចំពោះករណី០០១ យើងឃើញថា បងប្អូនដើមបណ្តឹងរដ្ឋប្បវេណី គាត់ចង់បានយុត្តិធម៌ ក្រៅពីបញ្ហាសេវាសុខភាពផ្លូវចិត្ត គាត់ចង់បានយុត្តិធម៌។ គាត់ចង់បានឱកាសនៅក្នុងការចូលរួមនៅក្នុងការសំណង។ គាត់ចង់បានចូលរួមចែករំលែកនៅក្នុងការប្រាប់អំពីរឿងរ៉ាវ ប្រវត្តិរឿងពិតផ្ទាល់ខ្លួន។ គាត់ចង់បានចូលរួមក្នុងការអប់រំ ដើម្បីការពារកុំឱ្យមានដូចថាមានការកើតឡើងនូវរបបប្រល័យពូជសាសន៍ទៀត ហើយអ្នកខ្លះក៏គាត់ចង់និយាយថាគាត់ៗថាចូលរួមហ្នឹងគឺដើម្បីបំពេញកាតព្វកិច្ចក្នុងនាមជាកូនសងគុណចំពោះឪពុកម្តាយដែលបានស្លាប់ ពីព្រោះគាត់ឡើងមកនេះ គឺដើម្បីដាក់ទោសចំពោះជនដៃដល់ដែលគាត់បាន -- ដែលបានធ្វើទៅលើឪពុកម្តាយបងប្អូនក្រុមគ្រួសារគាត់។

[១៥:៣៨:១៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមអរគុណលោកអ្នកជំនាញ។ លោកប្រធាន ខ្ញុំសួរចប់ហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកអ្នកជំនាញ ខ្ញុំមានតែ១៥នាទីទេដើម្បីសួរលោកនេះ។ ហើយខ្ញុំមានសំណួរច្រើនណាស់។ ដូច្នេះខ្ញុំនឹងព្យាយាមជ្រើសរើសសំណួរមួយចំនួនទេ។ ហើយខ្ញុំសូមឲ្យលោកឆ្លើយឲ្យច្បាស់លាស់ ជាក់លាក់ ហើយនិងខ្លី។ អ្វីដែលខ្ញុំចាប់អារម្មណ៍គឺយន្តការផ្លូវចិត្ត ហើយនិងការព្យាបាលជំងឺវិកលចរិត ហើយទាក់ទងនឹងជនរងគ្រោះដែលលោកធ្លាប់ជួប ហើយនិងលោកបានព្យាបាលនៅក្នុងបទពិសោធន៍ដ៏យូរអង្វែងរបស់លោកជាពេទ្យព្យាបាលជំងឺវិកលចរិត។

នៅក្នុងសវនាការនេះ តើការដែលរំឭកអនុស្សាវរីយ៍ជូរចត់ ហើយការឈឺចាប់ និងការតក់ស្លុតរបស់ជនរងគ្រោះជាទូទៅនេះ អាចមានផលប៉ះពាល់ជាអវិជ្ជមាននៅក្នុងរយៈពេលខ្លី ដូចជាការធ្វើឲ្យគាត់កាន់តែឈឺចាប់ឡើង ឆាប់ខឹងឡើង ហើយនិងអាចមានផលប៉ះពាល់ជាវិជ្ជមាន បើសិនជាគេអនុញ្ញាតឲ្យពួកគាត់និយាយចេញមកក្រៅឲ្យបានច្រើន?

[១៥:៣៩:៥៨]

**ឆ៖** បាទសូមអរគុណ។ ខ្ញុំបាទសូមបញ្ជាក់ទៅលើការសិក្សាមួយរបស់អង្គការ ធី.ភី.អូទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០១។ គឺយើងឃើញថា ពួកគាត់ទាំងអស់ហ្នឹងបានបង្ហាញនូវបទពិសោធន៍ដ៏ល្អ ដែលគាត់បានឱកាសក្នុងការចូលមកធ្វើសក្ខីកម្មនុ៎ង។ គឺប្រាកដណាស់ ដំបូងឡើងវាធ្វើឲ្យគាត់ហ្នឹង វាមានអារម្មណ៍នឹកឃើញឡើងវិញអំពីបញ្ហាអារម្មណ៍មិនល្អ គេងមិនលក់ មានការលំបាកតានតឹងក្នុងចិត្តសព្វបែបយ៉ាងទាំងអស់ហ្នឹង ប៉ុន្តែអារម្មណ៍ទាំងអស់ហ្នឹង អាចរសាយទៅវិញនៅពេលដែលគាត់ហ្នឹងធ្វើសក្ខីកម្ម បាននិយាយអំពីរឿងរ៉ាវដែលគាត់មាន ហើយជាពិសេសមួយទៀត គឺគាត់

មានអារម្មណ៍ថា គាត់មានការទទួលស្គាល់ ដឹងឮអំពីអង្គសវនាការដែលអនុញ្ញាតឲ្យគាត់មកនិយាយនេះ ជាការទទួលស្គាល់នូវការឈឺចាប់របស់គាត់។ អ៊ីចឹងករណីទាំងអស់ហ្នឹង គឺជាកត្តាសំខាន់ដែលជួយគាត់ច្រើនណាស់។ ប្រាកដណាស់ ថាវាំខាន់ពីដំបូង ប៉ុន្តែវានៅថ្ងៃមុខ វាអាចជួយគាត់ច្រើន។

[១៥:៤១:០៨]

**សៈ** តើតាមរយៈការចូលរួមជាវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ជាពិសេសគឺថាគាត់មកនិយាយ។ តើតាមរយៈការនិយាយស្តីរបស់គាត់នោះ ជនរងគ្រោះផ្សេងទៀតនោះអាចប្រៀបធៀបខ្លួនទៅនឹងពួកគាត់ទាំងអស់គ្នា ហើយនិងអាចមានអារម្មណ៍ថាខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរ ហើយអ៊ីចឹងនេះគឺជាជំហានមួយក្នុងការធ្វើដំណើរឆ្ពោះទៅការជាសះស្បើយ តើចំពោះអ្នកដែលមិនបានមកផ្តល់សក្ខីកម្មនៅទីនេះ ហើយនិងអ្នកនៅក្រៅនោះ មានលទ្ធផលជាវិជ្ជមាននេះចំពោះពួកគាត់ដែរឬទេ?

**ឆៈ** បាទ ខ្ញុំគិតថាអ្នកដែលបានមកចូលរួមនៅក្នុងការផ្តល់សក្ខីកម្មនេះ អាចជាគំរូល្អរបស់ពួកគាត់។ ជួនកាលពួកគាត់ចង់មកធ្វើសក្ខីកម្មដែរ ប៉ុន្តែដោយសារការភ័យខ្លាច ដោយសារការអារម្មណ៍មិនស្រួលនៅក្នុងផ្លូវចិត្ត ដោយសារការឈឺចាប់អីផ្សេងៗ ដោយការគេចវេះ ដែលខ្ញុំបានជម្រាបជូនពីមុនហ្នឹង ធ្វើគាត់មិនចង់ទេ ប៉ុន្តែនៅពេលដែលគាត់ឃើញនូវគំរូរបស់អ្នកដើមបណ្តឹងមុនៗនោះ ធ្វើឲ្យគាត់ហ្នឹងអាចមានការប្រែប្រួលក្នុងអារម្មណ៍ ធ្វើឲ្យគាត់ហ្នឹងអាចរកវិធីដើម្បីធ្វើការសម្រេចក្នុងការមកចូលរួមនៅក្នុងការធ្វើសក្ខីកម្ម។ អ៊ីចឹងអាហ្នឹងគឺជាដំណើរការមួយល្អដែលជួយគាត់នៅក្នុង -- ឲ្យមានទៅការជាសះស្បើយ និងការផ្សះផ្សា បាទ។

[១៥:៤២:៥៥]

**សៈ** បាទ លោកបាននិយាយអំពីរោគសញ្ញាដែលថាការជៀសវាងមិនព្រមនិយាយអំពីអ្វីមួយ ហើយនិងការបដិសេធមិននិយាយអំពីព្រឹត្តិការណ៍ដែលខ្លួនបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម។ តើក្នុងចំណោមកត្តាទាំងអស់នេះ ដែលជាមូលហេតុនៃការជៀសវាង ឬក៏គេចវេះមិនព្រមនិយាយពីអ្វីមួយនោះជា -- គឺថាជាហាមឃាត់ខ្លួនឯងក្នុងការមិនបញ្ចេញពីការរំភើប ឬក៏មិនយំ ពេលដែលមានអ្នកស្តាប់ ឬក៏ការបញ្ចេញមតិ។ នេះគឺជា តើទាំងអស់នេះ សុទ្ធជាថាជារោគសញ្ញានៃការគេចវេះដែលជាផលប៉ះពាល់ចេញពីរបបខ្មែរក្រហម?

**ឆៈ** បាទ ខ្ញុំសូមបញ្ជាក់ថា ការដែលគាត់គេចវេះគឺជាឱកាសមួយក្នុងការដែលគាត់ហ្នឹងដោះ

ស្រាយចំពោះការឈឺចាប់និងការភ័យខ្លាច។ អ៊ីចឹងនៅពេលដែលគាត់គេចវេះ ធ្វើឲ្យមានអារម្មណ៍ស្រួល។ អ៊ីចឹងគាត់នឹងបន្តការគេចវេះ និងបន្តការជៀសវាងមិននិយាយអំពីបញ្ហាហ្នឹង។ ហើយសូមបញ្ជាក់ថា ជួនកាលរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហម ជួនកាលយើងមិនទាន់បានឃើញភ្លាមទេ។ រោគសញ្ញានៃការគេចវេះ ប៉ុន្តែរោគសញ្ញាហ្នឹងអាចកើតមាននៅពេលដែលគាត់មានជួបព្រឹត្តិការណ៍អីដែលស្រដៀង ធ្វើឲ្យគាត់នឹកឃើញ ហើយធ្វើឲ្យគាត់ហ្នឹងគេចវេះតែម្តង។ អ៊ីចឹងជួនកាលយើងមើលថាព្រឹត្តិការណ៍ដែលគាត់មាន សញ្ញាដែលគាត់មានឥឡូវ មិនមែនជាសញ្ញាដែលទាក់ទងនឹងសម័យខ្មែរក្រហម ប៉ុន្តែយើងមើលវាអាចសម័យខ្មែរក្រហមហ្នឹង ជាសញ្ញាមួយដែលកើតមានសម្រាប់ទៅហើយដែលវាមិនទាន់ចេញ ប៉ុន្តែនៅពេលដែលមាន*ទ្រីហ្គឺ* – ដែលមានសញ្ញារំញោចធ្វើឲ្យសញ្ញាហ្នឹងកើតឡើង។ អ៊ីចឹងជួនកាលយើងត្រូវចំណាយពេលឲ្យបានច្រើនបន្តិចដើម្បីសួរគាត់ ដើម្បីទើបយើងអាចដឹងថា តើការគេចវេះហ្នឹងវាអាចបណ្តាលមកពីព្រឹត្តិការណ៍ថ្មី ឬក៏ព្រឹត្តិការណ៍សម័យខ្មែរក្រហមនោះ បាទ។

[១៥:៤៥:២៤]

**សៈ** បាទ សូមអរគុណ។ តើមានកត្តាណាមួយដែលមានតួនាទីធ្ងន់ធ្ងរ ដែលធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងទាក់ទងទៅនឹងការ -- វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច។ ឧទាហរណ៍ដូចជា ការមិនយល់ពីរបបហ្នឹង ឬក៏ការដែលរបបនយោបាយហ្នឹងគ្មានន័យចំពោះជនរងគ្រោះ។ ឧទាហរណ៍ថា ស្លាប់ដោយគ្មានន័យ ហើយនិងឈឺចាប់ដោយគ្មានន័យ។ តើទាំងអស់នេះៗ សុទ្ធតែជាកត្តាដែលធ្វើឲ្យរោគសញ្ញានៃការឈឺចាប់ ឬក៏ការឈឺចាប់របស់ជនរងគ្រោះខ្មែរក្រហមនោះនៅតែបន្តរហូតដល់រាល់ថ្ងៃថា ធ្វើឲ្យកាន់តែធ្ងន់ធ្ងរទៅៗ?

**ឆៈ** បាទសូមអរគុណ។ សូមបញ្ជាក់ថា ក្រៅពីការព្យាបាលផ្លូវចិត្ត ក្រៅពីបំពេញនៅតម្រូវការរបស់ជនរងគ្រោះ កត្តាសំខាន់មួយទៀត គឺអត្ថន័យ។ អត្ថន័យដែលគាត់ឲ្យចំពោះហេតុការណ៍ដែលកើតឡើងក្នុងសម័យខ្មែរក្រហម ឬក៏អត្ថន័យនៃអង្គសវនាការនេះជាដើម។

[១៥:៤៦:៥០]

ខ្ញុំឃើញការសិក្សាមួយរបស់លោក ហ្បៀល ដែលគាត់សិក្សាអំពីបញ្ហាផ្លូវចិត្ត និងការចំណង់ចង់សងសឹក គឺថាគាត់ឃើញថា អ្នកដែលមានបញ្ហាផ្លូវចិត្ត ហើយនិងមានចំណង់ចង់សងសឹកហ្នឹង មានបំណងចង់សងសឹកហ្នឹង គឺសញ្ញានេះវាទាក់ទងទៅនឹងការដែលគាត់មិនឲ្យតម្លៃ មិនយល់អំពីប្រព័ន្ធតុលាការ មិនយល់អំពីអត្ថន័យនៃតុលាការ គាត់យល់នូវអត្ថន័យថា ការដែលគាត់កាត់ទោស ដូចថាមាន

លក្ខណៈមិនសមស្របឬក៏មានលក្ខណៈដែលមិនប្រក្រតី។ អ៊ីចឹងទាំងអស់ហ្នឹង អត្ថន័យដែលគាត់ឲ្យទៅលើតុលាការ ឬក៏រឿងរ៉ាវដែលកើតឡើងហ្នឹងវាហាក់ដូចជា គ្មានន័យ មិនមានអ្នកណាជួយដោះស្រាយ។ អ៊ីចឹងវានឹងបន្តនៅបញ្ហាផ្លូវចិត្តរបស់គាត់។ អ៊ីចឹង អត្ថន័យដែលគាត់ឲ្យហ្នឹង វាអាចជួយឲ្យគាត់ឈានទៅរកការជាសះស្បើយ ឬក៏អាចឲ្យគាត់ហ្នឹងបន្តនូវការឈឺចាប់។ ដូចខ្ញុំបានជម្រាបថាការចង់ចេះតែសងសឹកហ្នឹង ដោយសារគាត់អត្ថន័យរបស់គាត់ហ្នឹងបកស្រាយវាមិនសមស្រប។

[១៥:៤៨:០៨]

**ស៖** បាទ សូមអរគុណ ខ្ញុំនៅសល់សំណួរបីទៀត។ តើអ្នកដែលបាត់បង់ញាតិមិត្តរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមអាចមានអារម្មណ៍ថា ខ្លួនមានកំហុសថា ដោយសារតែខ្លួននៅរស់រៀនមានជីវិតដោយសារមិនបានស្លាប់ជាមួយបងប្អូនរបស់ខ្លួន ឬក៏មិនបានសង្គ្រោះជីវិតរបស់ពួកគេដែលស្លាប់ទៅនោះ?

**ឆ៖** បាទ ជាទូទៅ គឺយើងឃើញមានរោគសញ្ញានេះដែរ ចំពោះបងប្អូនមួយចំនួន ហើយខ្ញុំបានសូមបង្ហាញទៅលើការសិក្សាមួយដែលធ្វើដោយមណ្ឌលការពារប្រឆាំងនឹង -- ព្យាបាលជំងឺទារុណកម្មនៅក្នុងទីក្រុងបែរឡាំង ដែលធ្វើការសិក្សានៅកម្ពុជាយើងហ្នឹង គឺឃើញថា គឺថាបញ្ហាមានការសោកស្ដាយ ខកខឹងចំពោះខ្លួនឯង ដោយការមិនបានការពារបងប្អូនហ្នឹង គឺច្រើនចំពោះ មានទំនាក់ទំនងចំពោះអ្នកដែលមានសាច់ញាតិជិតស្និទ្ធស្លាប់ ដូចជា ប្ដី ឬប្រពន្ធ ឬក៏កូន ឬក៏ឪពុកម្ដាយ។ យើងឃើញថា វាមានទំនាក់ទំនងហ្នឹងខ្លាំងបាទ។

**ស៖** បាទ សូមអរគុណ។ តើផលវិបាកចំពោះជនរងគ្រោះ ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងម៉េចដែរ បើមានការបដិសេធមិនទទួលស្គាល់កំហុសរបស់អ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ គឺថាពុំមានអ្នកណាទទួលស្គាល់ការខុសត្រូវរបស់ខ្លួន ហើយបោះ ជះកំហុសទៅលើតែអង្គការមួយនោះ តើការដែលការបដិសេធមិនរកយុត្តិធម៌នេះ ធ្វើឲ្យជនរងគ្រោះមានអារម្មណ៍យ៉ាងម៉េចដែរ?

[១៥:៥០:១២]

**ឆ៖** បាទ សូមអរគុណ។ ដូចខ្ញុំបានជម្រាបអ៊ីចឹង ផ្នែកមួយនៃការព្យាបាលហ្នឹងគឺទៅលើតម្រូវការរបស់គាត់។ ហើយយើងបានសិក្សាទៅលើដើមបណ្ដឹងនៅករណី០០១ហ្នឹង គឺគាត់ចង់បានយុត្តិធម៌ចង់បានការពិត។ អ៊ីចឹងបើសិនជាយុត្តិធម៌ ការពិត រឿងរ៉ាវដែលកើតមានទៅលើបងប្អូនហ្នឹងត្រូវបានបំភ្លឺ បកស្រាយ អ៊ីចឹងគឺយើងឃើញថាវានឹងជាការចូលរួមចំណែកនៅក្នុងការជាសះស្បើយ។

ក្នុងការសិក្សាមួយ ខ្ញុំលើករបស់លោក សូនីស នៅក្នុងឆ្នាំ២០១២ សិក្សាទៅលើប្រជាជនហ្នឹង គឺថាអ្នកដែលទទួលអារម្មណ៍ថានឹងបានយុត្តិធម៌ច្រើន គាត់មានបញ្ហាផ្លូវចិត្តតិចជាងអ្នកដែលទទួលអារម្មណ៍ថាមិនបានយុត្តិធម៌។ អ៊ីចឹងកត្តាយុត្តិធម៌ កត្តាការពិតនេះ គឺជាកត្តាសំខាន់ក្នុងការចូលរួមចំណែកដើម្បីឲ្យគាត់ជាសះស្បើយ។

**ស៖** តើការបដិសេធមិនទទួលខុសត្រូវរបស់អ្នកដឹកនាំនោះ អាចជួយសម្រាល ឬក៏ការប៉ះប៉ូវដោយសារការមកនិយាយនៅទីនេះ ដូចដែលលោកបានលើកឡើងហើយ គឺថាការបង្ហាញពីអង្គហេតុដើម្បីឈានចូលទៅដល់ការកាត់សេចក្ដីនេះ ថាតើការដែលជនជាប់ចោទមកនិយាយអ៊ីចឹងធ្វើឲ្យគាត់ធូរស្រាយទេ ជនរងគ្រោះទាំងអស់នុ៎ង?

[១៥:៥១:៤៨]

**ឆ៖** បាទ ការនិយាយហ្នឹងបានធូរស្រាលមួយកម្រិត ប៉ុន្តែឲ្យបានជាការសះស្បើយអំពី*ត្រូម៉ា*តែម្ដងគឺខ្ញុំគិតថាមិនមានភាពងាយស្រួលទេ។ ពីព្រោះគាត់នៅតែផ្ដោតអារម្មណ៍ទៅលើបញ្ហាដែលកើតមាន គាត់នៅតែឆ្ងល់ចំពោះរឿងរ៉ាវដែលកើតមាន គាត់នៅតែមិនដឹងច្បាស់អំពីរឿងរ៉ាវដែលកើតមាន។ អ៊ីចឹងករណីនឹងបន្តឲ្យមានការឈឺចាប់ខាងផ្លូវចិត្តនៅតែកើតមានដដែល។

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ។ តើចំពោះជនរងគ្រោះនូវការដែលជនជាប់ចោទត្រូវបានកាត់ក្ដីនៅក្នុងជីវិតនេះ ជាជាងការកាត់ក្ដី ឬក៏ការផ្ដន្ទាទោសតាមសាសនានៅជាតិក្រោយនោះ តើលោកយល់យ៉ាងម៉េចដែរ សារៈសំខាន់នៃការកាត់ក្ដីនៅជាតិនេះឲ្យហើយនេះ ជាជាងការកាត់ក្ដីតាមបែបសាសនានៅជាតិក្រោយ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកអ្នកជំនាញ! -- អ៎ះ! លោកមេធាវីការពារក្ដីលោក នួន ជា!

[១៥:៥៣:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំទើបតែដឹងថា ឥឡូវនេះអ្នកជំនាញគាត់ក្លាយទៅជាអ្នកជំនាញខាងសាសនា ខាងពុទ្ធសាសនាស្រេចទៅហើយ។ ដូច្នេះគិតថាសំណួរដែលសួរហ្នឹងគឺហួសពីសមត្ថភាពរបស់អ្នកជំនាញនេះហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក កូប៉េ។ ហើយសេចក្ដីជំទាស់ហ្នឹងមានលក្ខណៈសមស្របណាស់ ហើយអ្នកជំនាញមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញានេះទេ។

ហើយៗអស់ម៉ោងហើយលោកតំណាងសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។

[១៥:៥៤:១៧]

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្បាឯល៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

ចប់ហើយ! អស់ម៉ោងហើយ ព្រោះម៉ោងពេលវេលាសម្រាប់លោក លោកអំមិញសុំបីសំណួរ លោកឡើងបួនសំណួរហើយ។ មិនអនុញ្ញាតទេ! ប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា!

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្បាឯល៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់អរគុណអ្នកជំនាញ ដែលគាត់បានមកទីតែប៉ុណ្ណោះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មិនបាច់ទេៗ! ឥឡូវពេលវេលាអស់ហើយ។ សូមអញ្ជើញលោក កូប៉េ!

[១៥:៥៤:៥៧]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមើលទៅនាឡិកា ឥឡូវហ្នឹងគឺនៅខ្វះ៧នាទីទៀត គឺដល់ម៉ោងបួនហើយ។ ហើយយើងចំណាយពេលអស់ច្រើនរួចមកហើយ។ កាលពីដើមមក គឺខ្ញុំបានលើកឡើងចំណុចមួយគឺថា ដោយសារតែមេធាវីការពារក្ដីមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសាកសួរទៅលើអ្នកជំនាញនេះ។ ប៉ុន្តែឥឡូវបន្ទាប់ ពីបានស្ដាប់ទៅធ្វើឲ្យខ្ញុំមាននូវមូលដ្ឋានគ្រប់គ្រាន់ហើយខ្ញុំអាចដូចថាបង្កើតបានជាសំណើរបស់ខ្ញុំបាន។ អ្វីដែលខ្ញុំចង់សួរដេញដោលបើសិនជាយើងនិយាយក្នុងលក្ខណៈទូទៅគឺខ្ញុំចង់ឲ្យមានការបង្កើត ឬក៏ការសម្រេចមួយថា អ្នកជំនាញគាត់មានអាណាគតិចំពោះជនជាប់

ចោទ គឺគាត់លម្អៀងប្រឆាំងទៅនឹងជនជាប់ចោទ។ ដូច្នេះខ្ញុំចង់បានគោលដៅទាំងអស់នេះ។

ទី២ គឺខ្ញុំចង់រកឲ្យឃើញថា តើអ្នកជំនាញហ្នឹង គាត់មានសមត្ថភាព ឬក៏មានគុណវុឌ្ឍិផ្នែកហ្នឹង ជំនាញរបស់គាត់ឬក៏អត់? ហើយខ្ញុំបានពិនិត្យទៅលើប្រវត្តិរូបសង្ខេបរបស់អ្នកជំនាញ ហើយមេធាវីការពារក្ដីហាក់ដូចជាសង្ស័យយ៉ាងខ្លាំង ថាតើគាត់អាចមានសមត្ថភាពជាអ្នកជំនាញឬក៏អត់។ ហើយខ្ញុំនឹងសួរទៅលើបញ្ហានេះ។

ហើយចំណុចទី៣ គឺយើងចង់សួរអ្នកជំនាញអំពីសំណួរទាក់ទងទៅនឹងវិធីសាស្ត្រដែលគាត់ប្រើប្រាស់នៅក្នុងការអនុវត្តការងាររបស់គាត់ ហើយដើម្បីឲ្យគាត់អាចឆ្លើយបានទាក់ទងទៅនឹងសំណួរដែលគាត់បានឆ្លើយពីរួចមកហើយ។ ឧទាហរណ៍ដូចថាតើគាត់ធ្លាប់ជួបអ្នកជំងឺប៉ុន្មាននាក់? តើគាត់ធ្លាប់ព្យាបាលអ្នកជំងឺប៉ុន្មាននាក់? តើគាត់ធ្លាប់ជួបជាមួយនឹងអ្នកតំណាងជនរងគ្រោះប៉ុន្មានអីប៉ុន្មាន? អានេះគឺជាវិធីសាស្ត្រដែលខ្ញុំចង់សាកសួរគាត់ដើម្បីឲ្យដឹងអំពីអ្វីដែលគាត់បានឆ្លើយនៅពេលរសៀលនេះ។

[១៥:៥៦:៥៥]

ហើយឥឡូវនេះអ្វីដែលខ្ញុំអាចនិយាយបានគឺថា ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើអត្ថបទក៏ដូចជាការបោះពុម្ពផ្សាយដែលខាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង។ ហើយខ្ញុំចង់ធ្វើការសាកសួរទៅដល់អ្នកជំនាញអំពីបញ្ហាទាំងអស់នេះ ព្រោះថាអ្នកជំនាញក៏ជាអ្នកនិពន្ធមួយរូបនៅក្នុងអត្ថបទនេះផងដែរ។ ខ្ញុំគិតថាដើម្បីជាប្រយោជន៍យុត្តិធម៌ ក៏ដូចជាការស្វែងរកការពិត គឺខ្ញុំអាចសួរសំណួរទៅលើអ្នកជំនាញអំពីអត្ថបទដែលគាត់សរសេរ ក៏ដូចជាអត្ថបទដែលគាត់ទើបតែបានលើកឡើងមកនិយាយនៅពេលមុននេះ ហើយនិងអត្ថបទដែលបានបញ្ចូលទៅក្នុងសំណុំរឿងផងដែរ។ ហើយខ្ញុំបានបញ្ជាក់ថាកាលពីសប្ដាហ៍មុន គឺខាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំទៅអង្គជំនុំជម្រះដើម្បីដាក់នូវឯកសារទាំងអស់នេះចូលទៅក្នុងសំណុំរឿង ហើយអាចបញ្ជូនទៅឲ្យអ្នកជំនាញដើម្បីឲ្យគាត់បានអានមុន។ ដូច្នេះឥឡូវនេះ ខ្ញុំប្រើប្រាស់ពេលវេលាដែល ខ្ញុំមានប្រហែលជា៥ ទៅ១០នាទី អស់ទៅហើយ។ ប៉ុន្តែអ្វីដែលខ្ញុំអាចសន្និដ្ឋានគឺថាខ្ញុំត្រូវការពេលវេលាច្រើនដើម្បីចោទសួរសំណួរទៅដល់លោក សុធារ៉ា ដែលជាអ្នកជំនាញ។

[១៥:៥៨:២០]

គឺខ្ញុំមានបញ្ហា -- គឺថាដោយសារ ដូចដែលព្រះរាជអាជ្ញាបានលើកឡើងថាខាងមេធាវីការពារក្ដីលើកសំណើហ្នឹងយឺត ប៉ុន្តែយើងបានបញ្ជូនកាលពីម្សិលមិញរួចទៅហើយ។ ហើយខ្ញុំសង្ឃឹមថា ប្រសិន

បើយើងមានមេធាវីច្រើនអាចថាមេធាវី ១០-២០នាក់នៅក្នុងក្រុមហ្នឹងគឺយើងអាចធ្វើការងារបានល្អបានលឿនជាងនេះ។ ប៉ុន្តែមិនមែនដូច្នេះទេ។ ដូច្នេះ ឥឡូវនេះខ្ញុំសូមស្នើសុំដល់អង្គជំនុំជម្រះមេត្តាផ្អាកនូវការផ្តល់សក្ខីកម្មរបស់អ្នកជំនាញដើម្បីបន្តទៅថ្ងៃស្អែកតទៀត ដើម្បីខាងមេធាវីការពារក្តីអាចនឹងធ្វើការសួរដេញដោលបានគ្រប់គ្រាន់ទៅលើអ្នកជំនាញដោយសារតែវាជាចំណុចដ៏សំខាន់មួយសម្រាប់ក្រុមមេធាវីការពារក្តី។

**ប្រធានអង្គជំនុំ៖**

ទី១ លោក កូប៉េ តើលោកត្រូវការពេលវេលាប្រហែលជាប៉ុន្មានទៅក្នុងការសួរដេញដោលចំពោះអ្នកជំនាញរូបនេះ?

[១៥:៥៩:២៣]

**លោក វិុចទ័រ កូប៉េះ**

លោកប្រធានយើងបានបញ្ជាក់នៅក្នុងអ៊ីម៉ែលរបស់យើងរួចទៅហើយគឺថាវាអាស្រ័យទៅលើចម្លើយដែលអ្នកជំនាញគាត់បានផ្តល់ប្រហែលជាយើងត្រូវការ១ថ្ងៃពេញ។ ប៉ុន្តែខ្ញុំគិតថាវាមានចម្លើយជាច្រើនដែលអ្នកជំនាញបានផ្តល់រួចទៅហើយ។ ហើយប្រហែលជាមិនពាក់ព័ន្ធទៅនឹងការស្វែងរកការពិតនោះ។ ដូច្នេះខ្ញុំគិតថាវាអាស្រ័យទៅលើចម្លើយដែលអ្នកជំនាញឆ្លើយមកខាងយើងខ្ញុំ។ ប៉ុន្តែខ្ញុំសូមនិយាយថា ប្រហែលជាចន្លោះពីកន្លះថ្ងៃទៅមួយថ្ងៃពេញលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន យ៉ាងម៉េចដែរ?

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ចំពោះយើងទាំងអស់គ្នា បើសិនជាប្រធានបទដែលមេធាវី កូប៉េទាំងអស់ហ្នឹងគាត់និយាយសព្វអស់ហើយហ្នឹង ព្រោះគាត់និយាយគ្រប់ប្រធានបទអស់ហើយ យើងត្រូវការប្រហែលជា ១៥ ទៅ ២០នាទីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោក សុធារ៉ា តើលោកមានពេលវេលាសម្រាប់មកផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកដែរឬទេ ព្រឹក ឬល្ងាចនៅថ្ងៃស្អែក?

[១៦:០១:០០]

**លោក ឈឹម សុធារ៉ា៖**

ថ្ងៃស្អែកព្រឹក ខ្ញុំបាទរវល់ ប៉ុន្តែល្ងាចខ្ញុំបាទអាចមកបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសូមឆ្លើយទៅនឹងអំណះអំណាងដែលបានលើកឡើងដោយសហភាតាមេធាវីការពារក្តីលោក នួន ជា ដែលគាត់និយាយថា គោលបំណងរបស់គាត់គឺចង់បង្ហាញថា អ្នកជំនាញនេះកាន់ជើងម្ខាងៗ ហើយនិងមានមិនមានគុណវុឌ្ឍិ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ថាអ្នកជំនាញនេះនៅក្នុងបញ្ជីយើងតាំងពីខែមេសា ឆ្នាំ២០១១ ម្ល៉េះ ហើយច្រើនសប្តាហ៍មកហើយដែលគាត់ត្រូវបានកោះហៅមកផ្តល់សក្ខីកម្មនៅទីនេះ ហើយអ៊ីចឹងគាត់ដឹងហើយ អ៊ីចឹងហើយមានរឿងហេតុអីដែលត្រូវដំឡើងពេលវេលាឲ្យគាត់ ព្រោះថាគាត់ដឹងព័ត៌មានអស់ហើយៗគាត់អាចសិក្សាពីសំណួររបស់គាត់មុន។

[១៦:០២:០១]

ខ្ញុំយល់ថាគាត់មានសំណួរច្រើន ហើយគាត់អាច មិនអាចសួរចប់ ក៏ប៉ុន្តែនៅកន្លែងយើងនេះអ្នកណាក៏ខ្វះពេលវេលាដែរ ហើយអ្នកណាក៏ត្រូវរឹតត្បិតពេលវេលាដែរ ព្រោះថាពេលវេលាសុទ្ធតែមានកំណត់។ អ៊ីចឹងយើងគិតថាគួរតែចោទសំណួរទៅតាមពេលវេលាកំណត់ឲ្យ ហើយខ្ញុំគិតថាសហភាតារបស់ខ្ញុំនឹងមិនបានទៅមើលនៅក្នុងអ៊ីនធីហ្វេសទេ។ ហើយអ៊ីចឹងគាត់មិនអាចលើកពីឯកសារដែលគាត់មិនបានដាក់ចូលក្នុងអ៊ីនធីហ្វេសទេ។ អ៊ីចឹងគាត់ក៏ពុំមានលទ្ធភាពក្នុងការចោទសួរ ចោទសំណួរទៅលើឯកសារដែលគាត់មិនបានដាក់ចូលអ៊ីនធីហ្វេសដែរ។ ហើយជាទីបញ្ចប់ខ្ញុំសូមបន្ថែមថាសហភាតារបស់ខ្ញុំចង់សុំពេលវេលាវែង ហើយសូមនៅពេលនាទីចុងក្រោយនេះគាត់ដឹងតាំងពីយូរណាស់ហើយថាអ្នកជំនាញនេះនឹងមក ហើយគាត់ស្គាល់អ្នកជំនាញនេះទៀត។ អ៊ីចឹងសំណូមពររបស់គាត់នេះមិនមានមូលដ្ឋានអ្វីទេ ហើយអ៊ីចឹងមិនមានមូលហេតុណាដែលត្រូវផ្តល់ពេលវេលាបន្ថែមឲ្យគាត់ទេ។

[១៦:០៣:០៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ខ្ញុំនិយាយដោយសង្ខេបទេ។ ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណីបានកោះបានផ្ដល់ជូនតារាងរបស់ខ្លួនទាក់ទងទៅនឹងការផលប៉ះពាល់របស់ជនរងគ្រោះ ហើយដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងបទឧក្រិដ្ឋដែលចោទប្រកាន់។ ហើយគាត់បានផ្ដល់ឯកសារទាំងអស់តាំងពីថ្ងៃទី០៣ ឧសភា ឆ្នាំ២០១២ ហើយបន្ទាប់មកទៀត ២០១៣ (សូមទោស) ហើយបន្ទាប់មកទៀត កម្មវិធីដែលដើមបណ្ដឹងរដ្ឋប្បវេណីមួយទៀតនៅពាក់កណ្ដាលខែឧសភាដែរ។ ហើយបន្ទាប់មកទៀត ម្សិលមិញនេះយើងបានទទួលអ៊ីម៉ែលមួយដ៏វែងដែលជំទាស់អំពីរយៈពេលដែលផ្ដល់ជូនភាគី។ ហើយអ៊ីចឹងបានន័យថាខាងការពារក្ដីអាចធ្វើតាំងពីថ្ងៃទី០៣ ឧសភា។ អ៊ីចឹងនៅពេលដែលនិយាយថា មិនគ្រប់គ្រាន់ ហើយរហូតដល់ថ្ងៃនេះសូមពេលវេលាថែមនោះមួយថ្ងៃ។ អ៊ីចឹងវាមិនមានសមាមាត្រគ្នាសោះ។ ភាគីទាំងអស់គ្នាសុំសួរភាគីនេះតាមពេលវេលាកំណត់របស់តុលាការ។ ហើយយើងមាន យើងខំប្រឹងរឹតត្បិតសួរយ៉ាងនេះ យើងលះបង់សំណួរមួយចំនួនចោល ឧទាហរណ៍ដូចជាការសិក្សារបស់លោកអ្នកជំនាញ ហើយនិងគុណវុឌ្ឍិរបស់គាត់នេះជាដើមនេះ។ ហើយអ៊ីចឹងខ្ញុំគិតថាមិនមានមូលដ្ឋានអ្វីទេ មិនសមហេតុផលទេ ហើយមិនមានភាពសមាមាត្រទេដែលផ្ដល់ទៅឲ្យខាងការពារក្ដី ពេលវេលាវែង។ ឧទាហរណ៍ថា សូម្បីតែកន្លះថ្ងៃហ្នឹងក៏វែងដែរ។ អ៊ីចឹងយើងអាចគិតថា យើងអាចផ្ដល់ពេលបន្ថែមឲ្យគាត់ត្រឹមកន្លះម៉ោង ៣០នាទីអីប៉ុនន៉ុងទេ ដល់ថ្នាក់ថាដល់កន្លះថ្ងៃ ឬមួយថ្ងៃនោះ ច្រើនហួសហេតុពេកហើយ។

[១៦:០៥:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៤:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ហើយបន្ទាប់ពីបានស្ដាប់នូវសំណើរបស់ក្រុមមេធាវីការពារក្ដីលោក នួន ជា ហើយនិងមតិយោបល់របស់ភាគីនានា ហើយនិងក្រោយពីបានពិចារណា អង្គជំនុំជម្រះនឹងសម្រេចថា នឹងផ្ដល់ជូននូវពេលវេលាសម្រាប់មេធាវីទាំងពីរក្រុមក្នុងការសួរដេញដោលចំពោះអ្នកជំនាញរូបនេះនៅវេលារសៀលនៅថ្ងៃស្អែក ដោយនៅក្នុងពេលដំបូងនៃពេលរសៀលថ្ងៃស្អែកទាំងពីរវគ្គនោះ គឺអង្គជំនុំជម្រះនឹងផ្ដល់ជូនពេលវេលាចំនួន២០នាទី ជូនទៅសហព្រះរាជអាជ្ញា ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងក្នុងការតាំងសំណួរបន្ថែមចំពោះអ្នកជំនាញរូបនេះ។ ហើយពេលវេលាសល់ប៉ុន្មានគឺអង្គជំនុំជម្រះ

ផ្តល់ជូនទៅក្រុមមេធាវីការពារក្តីទាំងពីរក្រុម។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំគិតថា បើសិនជាលោកប្រធានអំមិញនេះជាសំណួររបស់លោកប្រធាន អ៊ីចឹងខាងព្រះរាជអាជ្ញា មានបំណងប្រើប្រាស់ពេលវេលាទាំង ២០នាទីនេះតែម្តងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ អរគុណលោកអ្នកជំនាញ ហើយដំណើរការស្តាប់សក្ខីកម្មរបស់លោកមិនបានចប់តាមការគ្រោងទុកទេ ដោយមានបញ្ហាជាច្រើនដែលត្រូវសួរ តាំងសំណួរពីភាគីដើម្បីបញ្ចប់នូវសក្ខីកម្មរបស់លោក ហើយពេលសមស្របដែលលោកអាចចូលរួមនៅក្នុងការផ្តល់សក្ខីកម្មបន្តបញ្ចប់បាននៅថ្ងៃស្អែក វេលារសៀលនោះ។ ដូច្នេះអង្គជំនុំជម្រះសម្រេចថាការបន្តស្តាប់សក្ខីកម្មរបស់លោកបញ្ចប់ធ្វើនៅរសៀលថ្ងៃស្អែក។ បាទ ដោយចាប់ផ្តើមពីម៉ោងមួយសាមសិបនាទី ដូចថ្ងៃនេះដែរ។ អ៊ីចឹងអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃស្អែក នៅវេលារសៀលបាទ។

ហើយសវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី០៦ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបី និងសាមសិបនាទីព្រឹក។

[១៦:១៦:៥០]

ហើយនៅពេលព្រឹកថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងបន្តសវនាការស្តាប់សក្ខីកម្ម សាក្សី ស៊ីដនី ស្ទេនប៊ឺក តាមមធ្យោបាយសោតទស្សន៍ពីសហរដ្ឋអាមេរិក ហើយនៅពេលរសៀល គឺស្តាប់សក្ខីកម្មអ្នកជំនាញ ឈឹម សុផារ៉ា ដូចបាន -- អង្គជំនុំជម្រះបានសម្រេចអម្បាញ់មិញនេះ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកអ្នកជំនាញរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅដែលគាត់ចង់ទៅបានហើយ ហើយនិងឲ្យសម្របសម្រួល អញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅថ្ងៃស្អែក នៅវេលារសៀលនៅម៉ោងមួយនិងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីរូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមនៅ

សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបីនិងសាមសិបនាទី។ ហើយដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលមានរៀបចំឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយដូចសព្វដង។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៨ នាទី)*